ព្រះ
ត្រៃបិដកឋាលី
និង
សេចក្តីប្រែជាភាសាខ្មែរ
សុត្តន្តបិដក
ខុទ្ទកនិកាយ ខុទ្ទកបាឋ, ធម្មបទគាថា
ឯទាន, ឥតិវុត្តក

๕๒



ពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ
๓-ស ๒๕๐๐

ឯកសារគម្ពីរព្រះត្រៃបិដកស្កានេះ
ត្រូវបានថតចេញពី ច្បាប់គម្ពីរព្រះត្រៃបិដកជប៉ុន ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះ ចាប់ពីភាគ៥១ ដល់ ភាគ១១០
ត្រូវបានវៀបចំធ្វើទៅឡើងដោយ គេហទំព័រ៥000ឆ្នាំ បូជា
ចំពោះព្រះពុទ្ធសាសនា សម្រាប់ជាធម្មទាន ។

ផ្តល់សៀវភៅគម្ពីរព្រះត្រៃបិដកសម្រាប់ការងារ
ដោយ ឧបាសិកា កាំង ហ្គិចណៃ ។

គ្រប់គ្រងគម្រោង (ទូទៅ និងផ្នែកបច្ចេកទេស)
ដោយ ឧបាសក ស្រុង-ចាន់ណា ។

ត្រួតពិនិត្យឡើងវិញ
ដោយ ចន-ស្រីស្រស់ ។


ថតស្កានដោយ
ភ្នួនប្រុស ម៉ាន់ សាវ៉ែត

www.5000-years.org

ក្រោមការឧបត្ថម្ភយ៉ាងក្រៃលែងអំពីៈ

- ឧបាសិកា កាំង ហ៊ួចណៃ (ភ្នំពេញ)
- ឧបាសក ដុត លីស្រុង និង ឧបាសិកា លី សុខា ព្រមទាំងបុត្រ (ភ្នំពេញ)
- ឧបាសក សន ចន និង ឧបាសិកា អ៊ូច សាទៀង ព្រមទាំងបុត្រ (បាត់ដំបង)
- ឧបាសក ជា ស៊ុវត្ថានា និងឧបាសិកា ឃុន សូនីម៉ា ព្រមទាំងបុត្រី ជា សុមេធាធីតា (ស.ទ.អ)
- លោក ជីម-ជា និងលោកស្រី រតនំ ស្រីមុំ (ភ្នំពេញ)
- ឧបាសក ផែង យឿន (កូរ៉ែ)
- លោក ស៊ុក ចាន់សេរី (បន្ទាយមានជ័យ)
- ឧបាសិកា យ៉ា វ៉ានី (បន្ទាយមានជ័យ)
- ប្អូនស្រី យ៉ា សុភៈ (បន្ទាយមានជ័យ)
- ឧបាសិកា កោ សេង (ភ្នំពេញ)
- លោកស្រី ប៉ាន សុគន្ធានីន និងស្វាមី ព្រមទាំងបុត្រ (ភ្នំពេញ)
- ឧបាសក ស្រុង ចាន់ណា និង ឧបាសិកា ចន ស្រីស្រស់
  ព្រមទាំងបុត្រ ចាន់ណា សុធានធីរាជ, ចាន់ណា សុធានធិរោធ (ភ្នំពេញ)
- លោកស្រី ស្រុង ចាន់រស្មី និង ស្វាមី ព្រមទាំងបុត្រ (ភ្នំពេញ)
- កញ្ញា ស្រុង ចាន់រតនា (ភ្នំពេញ)
- លោក ស្រុង ឃូហេង (ភ្នំពេញ)
- លោក នង សុផល (កូរ៉ែ)
- ប្អូនស្រី សុខ អេង (កំពង់ចាម)
- កញ្ញា ចន កក្កដា (បាត់ដំបង)
- លោកស្រី ចន សត្យា និងលោក ឡូត សេរីសំភ ព្រមទាំងបុត្រ (ភ្នំពេញ)
- លោក ចន រចនា (បាត់ដំបង)
- កញ្ញា ស៊ែ សុផានី (បាត់ដំបង)
- កញ្ញា យឿម សុផានី (បាត់ដំបង)
- លោក ម៉ៅ គន្ធា និងលោកស្រី ធៀង សេដ្ឋា (បាត់ដំបង)
- លោក សៅ សារ៉ុម (បាត់ដំបង)
- ព្រះតេជព្រះគុណ ជុំ សារៈ (ព្រះចៅអធិការវត្ត សម សាន្ត ខេត្តបាត់ដំបង)
- ឧបាសិកា វ៉ាន់ លុយ និងស្វាមី ព្រមទាំងបុត្រ (ភ្នំពេញ)
- លោកស្រី ហួ ច័ន្ទសុវណ្ណ និងស្វាមី ព្រមទាំងបុត្រ (ស.ទ.អ)

ព្រះ
វិន័យបិដក
និង
សេចក្តីប្រៀបធៀបសាសន៍ខ្មែរ
សុត្តន្តបិដក ខុទ្ទកនិកាយ
ខុទ្ទកបាឋ, ធម្មបទគាថា, ខុទាន
បឋមភាគ
៥២



ពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ

៣.ស. ២.៥០០

ឧទ្ទិសកថា

យើងខ្ញុំ សូមផ្តង់ស្មារតីស្ងប់ព្រះធម៌ឧទ្ទិសជូនជនជាតិខ្មែរ ។
ឥឡូវ យើងខ្ញុំអាចជូនគម្ពីរព្រះត្រៃបិដកនេះ ទៅអ្នកកាន់ព្រះពុទ្ធសាសនាជនជាតិខ្មែរបានហើយ ។
ព្រះធម៌នៃព្រះពុទ្ធជាម្ចាស់នេះ ត្រូវបានស្ងប់ព្រះចេញពីជម្រៅដួងចិត្តនៃអ្នកកាន់ព្រះពុទ្ធសាសនា
ជនជាតិជប៉ុន ។

このカンボジア版南伝大蔵経を
カンボジアの佛教徒へ
贈ることができることに感謝します。
これが日本の佛教徒の心です。

It is with a deep sense of gratitude that I present the translation of the complete TRIPITAKA to Cambodian Buddhists on behalf of the Japanese Buddhist community.

អារម្ភកថា

ជូនចំពោះជនជាតិខ្មែរ ជាទីរាប់អាន !

ជូនចំពោះជនជាតិខ្មែរដែលកាន់ព្រះពុទ្ធសាសនា ជាទីគោរព !

គម្ពីរព្រះត្រៃបិដកខ្មែរនេះ ត្រូវបាន " ក្រុមជំនុំព្រះត្រៃបិដក " នៃពុទ្ធសាសនបណ្ឌិត្យ នៅភ្នំពេញ បកប្រែពីភាសាបាលីមកជាភាសាខ្មែរ តាំងពីឆ្នាំ ១៩៣០ ទៅឆ្នាំ ១៩៦៨ គឺត្រូវចំណាយពេល ៣៩ ឆ្នាំ ទើបបានសម្រេចហើយសព្វគ្រប់ ។ នេះពិតជាកំណប់ព្រះធម៌របស់ព្រះពុទ្ធសាសនាខ្មែរ ហើយក៏ជាកំណប់វប្បធម៌ខាងផ្នែកបោះពុម្ពរបស់ជនជាតិខ្មែរផងដែរ ។ យើងខ្ញុំ ពុទ្ធសាសនិកជាតិជប៉ុន មានសន្តានចិត្តរីករាយនឹងបោះពុម្ពជាថ្មីឡើងវិញ ដោយសង្ឃឹមថា ព្រះពុទ្ធសាសនាខ្មែរក៏នឹងរុងរឿងឡើងវិញដែរ ។

នេះគឺជាអំណោយពីជម្រៅដួងចិត្ត ជូនទៅដល់ជនជាតិខ្មែរទាំងអស់ ព្រមទាំងមនុស្សជាតិទូទៅ នៅក្នុងពិភពលោកនេះ ដែលមានចិត្តស្រឡាញ់សន្តិភាព ។

ខ្មែរបានរងសោកនាដកម្មដែលមិនធ្លាប់មានពីមុនមក ។ ម្យ៉ាងទៀត ព្រះពុទ្ធសាសនាខ្មែរ ក៏ត្រូវរន្ធត់រាយយ៉ាងខ្លាំង ក៏ប៉ុន្តែឥឡូវនេះ យើងទាំងអស់គ្នា បានឈានជើងកន្លងផុតពីសេចក្តីទុក្ខសោកដ៏ធ្ងន់ធ្ងរនេះ ចាកផុតពីអំពើយោរយៅ បញ្ចប់គំនុំគុំគួន ដើរតាមពុទ្ធដីកាព្រះបរមគ្រូ ខិតខំព្យាយាមធ្វើឱ្យមានសន្តិភាពក្នុងពិភពលោក ។

ការណ៍ដែលយើងខ្ញុំជូនគម្ពីរព្រះត្រៃបិដកពេលនេះ គឺជានិមិត្តរូបនៃការប្តេជ្ញាចិត្តរបស់អ្នកកាន់ព្រះពុទ្ធសាសនាជនជាតិជប៉ុនថា យើងខ្ញុំធ្វើសហប្រតិបត្តិការដើម្បីសន្តិភាពក្នុងពិភពលោក ដើម្បីទុកជាភស្តុតាងនៃចំណងមេត្រីភាព និងមិត្តភាពរវាងប្រជាជាតិជប៉ុន និងប្រជាជាតិខ្មែរ ។

ថ្ងៃនក្ខត្តឫក្ស កក្កដា ឆ្នាំ ១៩៩៤

សមាគមជំនួយដល់ការបោះពុម្ពព្រះត្រៃបិដកឡើងវិញ

អ្នកតំណាងចាត់ការ The Rev. Seikyo Muchaku

ប្រធានការិយាល័យ The Rev. Eiitsu Shinohara

អ្នកចាត់ការ

The Rev. Zendo Matsunaga The Rev. Jitsujo Arima The Rev. Yoshimichi Ito
The Rev. Keiichi Watai The Rev. Gijun Sugitani The Rev. Shincho Shigeta
The Rev. Risho Maeda The Rev. Kyoshi Nakajima Mr. Rokusuke Ei

『トリピタカ』復刻進呈にあたって

親愛なるカンボジアの皆さん！
敬愛するカンボジアの仏教徒の皆さん！

カンボジア版『トリピタカ』は、プノンペンの仏教研究所が、仏教界の英知を集め、1930年から1968年まで、39年の歳月をかけて翻訳し、分類し、集大成して完成されました。まさにカンボジア仏教の法宝であると共に、カンボジア出版文化の至宝です。日本仏教徒の有志は、カンボジア仏教の復興再生を願いつつ、これを復刻刊行し、贈らせていただきます。

これはカンボジア仏教徒のみならず、カンボジア全人民、否、平和を愛する地球上のすべての人々への、心からの贈り物です。

カンボジアは、古今未曾有の悲劇を体験しました。カンボジア仏教もこの受難の時代に壊滅的な打撃を受けました。しかし、今はその悲しみを乗りこえ、瞋りを離れ、怨みを怨し、ブッダの教えに従い、世界平和の実現に努力するときです。

この本の贈呈は、日本の仏教徒も共々に、世界平和のために努力することを誓うしるしであり、相互の連帯と友情の証なのです。

合掌

1994年７月吉日

カンボジア版トリピタカ（南伝大蔵経）復刻救援委員会

世話人代表	無着　成恭	世話人	松永　然道	有馬　実成
事務局長	篠原　鋭一		伊藤　佳通	渡井　奎一
			杉谷　義純	茂田　真澄
			前田　利勝	中島　教之
			永　　六輔	

Acknowledgment

Dear Cambodian friends and respected members of the Cambodian Buddhist community,

It is a matter of great joy that the translation into Cambodian of the Pali Tripitaka has been completed and published. The Tripitaka Commisson of the Buddhist Institute, Phnom Penh, launched the translation project in 1930 and completed the translation, after 39 years of effort, in 1968.

The Cambodian translation of this great work will not only become a cherished treasure of the Cambodian Buddhist community but will also be an important milestone in the history of publication in Cambodia.

The revival and prosperity of Buddhism in Cambodia are the ardent wish of the Japanese Buddhist community, it is in this spirit that we have completed this important project and now present the entire work to the Cambodian Buddhist community, it is a gift not only to the Buddhist community in Cambodia but also to all Cambodian people and all peace-loving people in the world.

Cambodia experienced great tragedies in modern times, and the Cambodian Buddhist community also underwent severe trials and suffered crushing blows during this period. But now a time has come to surmount grief and anger, to forgive, and to start working again for world peace.

This great work is a symbol of the Japanese Buddhist community's resolve to work with our Cambodian brothers and sisters toward world peace and is a testimony to the friendship between our people.

With hands joined in reverence.
July 1994

TRIPITAKA PUBLISHING SUPPORT COMMITTEE
Project Manager : The Rev. Seikyo Muchaku
Secretary General : The Rev. Eiitsu Shinohara
Management Team :
The Rev. Zendo Matsunaga The Rev. Jitsujo Arima The Rev. Yoshimichi Ito
The Rev. Keiichi Watai The Rev. Gijun Sugitani The Rev. Shincho Shigeta
The Rev. Risho Maeda The Rev. Kyoshi Nakajima Mr. Rokusuke Ei

សុត្តន្តបិដក ខុទ្ទកនិកាយ

ខុទ្ទកបាឋ ធម្មបទគាថា ឧទាន

បឋមភាគ

៥២

៣. ស. ២.៥០០

សុត្តន្តបិដកេ

ខុទ្ទកនិកាយស្ស ខុទ្ទកបាឋោ

បឋមោ ភាគោ

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

ខុទ្ទកបាឋោ សរណាគមនំ[1]

[១]ពុទ្ធំ សរណំ គច្ឆាមិ ធម្មំ សរណំ គច្ឆាមិ សង្ឃំ សរណំ គច្ឆាមិ ។ ទុតិយម្បិ ពុទ្ធំ សរណំ គច្ឆាមិ ទុតិយម្បិ ធម្មំ សរណំ គច្ឆាមិ ទុតិយម្បិ សង្ឃំ សរណំ គច្ឆាមិ ។ តតិយម្បិ ពុទ្ធំ សរណំ គច្ឆាមិ តតិយម្បិ ធម្មំ សរណំ គច្ឆាមិ តតិយម្បិ សង្ឃំ សរណំ គច្ឆាមិ ។

សរណាគមនំ[2] និដ្ឋិតំ ។

ខុទ្ទកបាឋោ ទសសិក្ខាបទំ

[២] ថាណាតិបាតា វេរមណី សិក្ខាបទំ សមាទិយាមិ ។ អទិន្នាទានា វេរមណី សិក្ខាបទំ សមាទិយាមិ ។

---

១ ម.ម. សរណគមនំ ។ ២ ម.ម. សរណគមនំ ។

សុត្តន្តបិដក

ខុទ្ទកនិកាយ ខុទ្ទកបាឋ

ភាគទី ១

សូមនមស្ការព្រះមានព្រះភាគអរហន្តសម្មាសម្ពុទ្ធព្រះអង្គនោះ ។

ខុទ្ទកបាឋ សរណាគមន៍

[១] ខ្ញុំព្រះករុណា សូមដល់នូវព្រះពុទ្ធ ជាទីរឭក ខ្ញុំព្រះករុណា សូមដល់នូវព្រះធម៌ ជាទីរឭក ខ្ញុំព្រះករុណា សូមដល់នូវព្រះសង្ឃ ជាទីរឭក ។ ខ្ញុំព្រះករុណា សូមដល់នូវព្រះពុទ្ធ ជាទីរឭក ជាគំរប់ពីរដងផង ខ្ញុំព្រះករុណា សូមដល់នូវព្រះធម៌ ជាទីរឭក ជាគំរប់ពីរដងផង ខ្ញុំព្រះករុណា សូមដល់នូវព្រះសង្ឃ ជាទីរឭក ជាគំរប់ពីរដងផង ។ ខ្ញុំព្រះករុណា សូមដល់នូវព្រះពុទ្ធ ជាទីរឭក ជាគំរប់បីដងផង ខ្ញុំព្រះករុណា សូមដល់នូវព្រះធម៌ ជាទីរឭក ជាគំរប់បីដងផង ខ្ញុំព្រះករុណា សូមដល់នូវព្រះសង្ឃ ជាទីរឭក ជាគំរប់បីដងផង ។

ចប់ សរណាគមន៍ ។

ខុទ្ទកបាឋ សិក្ខាបទ ១០

[២] ខ្ញុំព្រះករុណា សូមសមាទាន នូវសិក្ខាបទគឺចេតនាជាហេតុវៀរចាកការសម្លាប់សត្វ ។ ខ្ញុំព្រះករុណា សូមសមាទាន នូវសិក្ខាបទគឺចេតនាជាហេតុវៀរចាកការកាន់យក នូវវត្ថុដែលគេមិនបានឲ្យ ។

អត្រហ្មចរិយេ វេរមណីសិក្ខាបទំ សមាទិយោមិ ។ មុសាវាទា វេរមណីសិក្ខាបទំ សមាទិយោមិ ។ សុរាមេរយមជ្ជប្បមាទដ្ឋានា វេរមណីសិក្ខាបទំ សមាទិយោមិ ។ វិកាលភោជនា វេរមណីសិក្ខាបទំ សមាទិយោមិ ។ នច្ចគីតវាទិតវិសូកទស្សនា វេរមណីសិក្ខាបទំ សមាទិយោមិ ។ មាលាគន្ធវិលេបនធារណមណ្ឌនវិភូសនដ្ឋានា វេរមណីសិក្ខាបទំ សមាទិយោមិ ។ ឧច្ចាសយនមហាសយនា វេរមណីសិក្ខាបទំ សមាទិយោមិ ។ ជាតរូបរជតប្បដិគ្គហណា វេរមណីសិក្ខាបទំ សមាទិយោមិ ។

ទសសិក្ខាបទំ និដ្ឋិតំ ។

ខុទ្ទកបាឋបាឡិ

[៣] អត្ថិ នមស្សិំ តាយេ តោសា លោមា ឧទា

ខ្ញុំព្រះករុណា សូមសមាទាន នូវសិក្ខាបទគឺចេតនាជាហេតុវៀរចាកការប្រព្រឹត្តិនូវធម៌មិនប្រសើរ ។ ខ្ញុំព្រះករុណា សូមសមាទាន នូវសិក្ខាបទគឺចេតនាជាហេតុវៀរចាកការពោលនូវពាក្យកុហក ។ ខ្ញុំព្រះករុណា សូមសមាទាន នូវសិក្ខាបទគឺចេតនាជាហេតុវៀរចាកហេតុជាទីតាំងនៃសេចក្តីប្រមាទ គឺការផឹកនូវទឹកស្រវឹង គឺសុរានិងមេរ័យ ។ ខ្ញុំព្រះករុណា សូមសមាទាន នូវសិក្ខាបទគឺចេតនាជាហេតុវៀរចាកការបរិភោគនូវភោជនាហារក្នុងកាលខុស ។ ខ្ញុំព្រះករុណា សូមសមាទាន នូវសិក្ខាបទគឺចេតនាជាហេតុវៀរចាកការ រាំ ច្រៀង ប្រគំនិងការមើលល្បែងផ្សេងៗ ដែលជាសត្រូវដល់កុសលធម៌ ។ ខ្ញុំព្រះករុណា សូមសមាទាន នូវសិក្ខាបទគឺចេតនាជាហេតុវៀរចាកការទ្រទ្រង់ការប្រដាប់និងការតាក់តែងសម្អិតសម្អាងកាយ ដោយផ្កាកម្រង គ្រឿងក្រអូបនិងគ្រឿងលាបផ្សេងៗ ។ ខ្ញុំព្រះករុណា សូមសមាទាន នូវសិក្ខាបទគឺចេតនាជាហេតុវៀរចាកសេនាសនៈដ៏ខ្ពស់ (ហួសប្រមាណ) និងសេនាសនៈដ៏ប្រសើរ ។ ខ្ញុំព្រះករុណា សូមសមាទាន នូវសិក្ខាបទគឺចេតនាជាហេតុវៀរចាកការគាន់យក នូវមាសនិងប្រាក់ ។

ចប់ សិក្ខាបទ ១០ ។

ខុទ្ទកបាឋបាឡិ អាការៈ ៣២

(៣) កុដ្ឋកាយនេះ មានសក់ រោម ក្រចក

ឧត្តា តថោ មំសំ ភុញ្ជ(๑) អដ្ឋិ(๒) អដ្ឋិមិញ្ជំ វត្តុំ
ហាឧយំ យកាឧំ កាឡោមកំ បិហាកំ បច្ឆាសំ អន្តំ
អន្តគុណំ ឧទរិយំ ករីសំ បិត្តំ សេម្ហំ បុព្ពោ លោ-
ហិតំ សេទោ មេទោ អស្សុ វសា ខេឡោ សិង្ឃា-
ឯិកា លសិកា មុត្តំ(๓) មត្ថកេ មត្ថលុង្គន្តិ(๔) ។

ខុទ្ទកបាឋេ ឧទ្ទិដ្ឋោ ។

ខុទ្ទកបាឋេ សាមណេរបញ្ហា

[๔] ឯកកង្គាម កឹ សព្ពេ សត្តា អាហារដ្ឋិតិកា ។ ទ្វេ
ជាម កឹ(๕)ជាមញ្ច រូបញ្ច ។ តីណិ ជាម កឹ(๖)តិសេ្សា
វេទនា ។ ចត្តារិ ជាម កឹ ចត្តារិ អរិយសច្ចានិ ។
បញ្ច ជាម កឹ បញ្ចុទានក្ខន្ធា ។ ឆ ជាម កឹ ឆ
អជ្ឈត្តិកានិ អាយតនានិ ។ សត្ត ជាម កឹ សត្ត
ពោជ្ឈង្គា ។ អដ្ឋ ជាម កឹ អរិយោ អដ្ឋង្គិកោ មគ្គោ ។
ឧវ ជាម កឹ ឧវ សត្តាវាសា ។ ឧស ជាម កឹ
ឧសហង្គេហិ សមង្គិកតោ អរហាតិ វុច្ចតិតិ ។

សាមណេរបញ្ហា ឧទ្ទិដ្ឋា ។

---

๑ ខ.ម. ភុញ្ជ ។ ๒ .ម. អដ្ឋិ ។ ๓ ម. មុត្តំ ។ មត្ថកេ មត្ថលុង្គន្តិ ជាហិ ហោន្តិ ។ ๔ ខ.ម. មត្ថលុង្គំ ។ ๕ ខ. ឯត្តន្តរេ ទ្វេតិ ជាហិ ទិស្សតិ ។ ๖ ខ. ឯត្តន្តរេ តីណីតិ ជាហិ ទិស្សតិ ។

ឆ្នេញ្ញ សែ្បក សាច់ សរសៃ ឆ្អឹង ខួរក្បាលឆ្អឹង ពាក បេះដូង ថ្លើម
ក្រពះ ក្រពេះ ស្លួត ពោះវៀនធំ ពោះវៀនតូច អាហារថ្មី អាហារ
ចាស់ ប្រមាត់ សេ្លស្ន ខ្ទុះ ឈាម ញើស ខ្លាញ់ខាប់ ទឹកភ្នែក
ខ្លាញ់ក្រមុំ ទឹកមាត់ ទឹកសម្បារ ទឹករំអិល ទឹកមូត្រ ខួរក្បាល ។

ចប់ អាការៈ ៣២ ។

ខុទ្ទកបាឋ សាមណេរបញ្ហា

[៤] ធម្មជាតឈ្មោះតែ ១ គឺអ្វី គឺសត្វទាំងអស់ តាំងនៅដោយ
សារអាហារ ។ ធម្មជាតឈ្មោះតែពីរគឺអ្វី គឺនាមនឹងរូប ។ ធម្មជាតឈ្មោះ
តែ ៣ គឺអ្វី គឺវេទនា ៣ ។ ធម្មជាតឈ្មោះតែ ៤ គឺអ្វី គឺអរិយសច្ច ៤ ។
ធម្មជាតឈ្មោះតែ ៥ គឺអ្វី គឺឧបាទានក្ខន្ធ ៥ ។ ធម្មជាតឈ្មោះតែ ៦ គឺអ្វី
គឺអាយតនៈខាងក្នុង ៦ ។ ធម្មជាតឈ្មោះតែ ៧ គឺអ្វី គឺពោជ្ឈង្គ ៧ ។
ធម្មជាតឈ្មោះតែ ៨ គឺអ្វី គឺអរិយមគ្គប្រកបដោយអង្គ ៨ ។ ធម្មជាតឈ្មោះ
តែ ៩ គឺអ្វី គឺសត្តាវាសៈ ៩ ។ ធម្មជាតឈ្មោះតែ ១០ គឺអ្វី គឺបុគ្គល
ដែលហៅថា ព្រះអរហន្ត ប្រកបដោយអង្គ ១០ ។

ចប់ សាមណេរបញ្ហា ។

(๕) ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ អថខោ អញ្ញតរា ទេវតា អភិក្កន្តាយ រត្តិយា អភិក្កន្តវណ្ណា កេវលកប្បំ ជេតវនំ ឱភាសេត្វា យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ អដ្ឋាសិ ។ ឯកមន្តំ ឋិតា ខោ សា ទេវតា ភគវន្តំ គាថាយ អជ្ឈភាសិ ។

(๖) ពហូ ទេវា មនុស្សា ច មង្គលានិ អចិន្តយុំ
អាកង្ខមានា សោត្ថានំ ព្រូហិ មង្គលមុត្តមំ ។
អសេវនា ច ពាលានំ បណ្ឌិតានញ្ច សេវនា
បូជា ច បូជនីយានំ(๑) ឯតម្មង្គលមុត្តមំ ។
បដិរូបទេសវាសោ(๒) ច បុព្ពេ ច កតបុញ្ញតា
អត្តសម្មាបណីធិ ច ឯតម្មង្គលមុត្តមំ ។
ពាហុសច្ចញ្ច សិប្បញ្ច វិនយោ ច សុសិក្ខិតោ
សុភាសិតា ច យា វាចា ឯតម្មង្គលមុត្តមំ ។

๑ ឧ.ម. បូជនេយ្យានំ ។ ๒ ឧ.ម. បតិរូបទេសវាសោ ។

(៥) ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅ ក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ គ្រានោះឯង ទេវតា ១ អង្គ កាលរាត្រីបឋមយាម កន្លងទៅហើយ មានរស្មីដ៏ល្អ ញុំាងវត្តជេតពនទាំងមូលឲ្យភ្លឺស្វាង ហើយចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ក្រាបថ្វាយបង្គំព្រះមានព្រះភាគហើយ បឋិតនៅក្នុងទីសមគួរ ។ លុះទេវតានោះ បឋិតនៅ ក្នុងទីសមគួរហើយ ទើបក្រាបទូលព្រះមានព្រះភាគ ដោយគាថា ។

(៦) ទេវតានឹងមនុស្សច្រើនឯណាយជារាប្រាថ្នាវេលាសួស្តី ចានតិរវេលាមង្គលច្រើនឯណាយ សូមព្រះអង្គសំដែងប្រាប់នូវមង្គលដ៏ឧត្តម ។

(ព្រះមានព្រះភាគទ្រង់ត្រាស់ថា) ការមិនសេពគប់ពាលជនច្រើនឯណាយ ១ ការសេពគប់បណ្ឌិតជនច្រើនឯណាយ ១ ការបូជាចំពោះបុគ្គលដែលគួរបូជាច្រើនឯណាយ ១ នេះជាមង្គល ដ៏ឧត្តម ។

ការនៅក្នុងប្រទេស ដ៏សមគួរ ១ ការធ្វើនៃបុគ្គលបានធ្វើបុណ្យពុំក្រហើយក្នុងកាលមុន ១ ការជំរុញខ្លួនប្រពៃ ១ នេះជាមង្គលដ៏ឧត្តម ។

ការធ្វើនៃបុគ្គលបានស្តាប់ បានរៀនច្រើន ១ សិល្បៈគឺសេចក្តីឆ្លៀវឆ្លាសក្នុងហត្ថកម្ម របស់អ្នកបួសនឹងគ្រហស្ថ ១ វិនយដែលបុគ្គលសិក្សាប្រពៃ ១ វាចាដែលបុគ្គលពោលល្អ ១ នេះជាមង្គល ដ៏ឧត្តម ។

ขุทฺทกปาเ มงฺคลสุตฺตំ

มาตาปิตุอุปฏฺ‌ฐานំ បុត្តទារស្ស សង្គហោ

អនាកុលា ច កម្មន្តា ឯតម្មង្គលមុត្តមំ ។

ទានញ្ច ធម្មចរិយោ ច ញាតកានញ្ច សង្គហោ

អនវជ្ជានិ កម្មានិ ឯតម្មង្គលមុត្តមំ ។

អារតី វิរតី(๑) បាបា មជ្ជបានា ច សញ្ញមោ

អប្បមាទោ ច ធម្មេសុ ឯតម្មង្គលមុត្តមំ ។

គារវោ ច និវាតោ ច សន្តុដ្ឋី ច កតញ្ញុតា

កាលេន ធម្មស្សវនំ ឯតម្មង្គលមុត្តមំ ។

ខន្តី ច សោវចស្សតា សមណានញ្ច ទស្សនំ

កាលេន ធម្មសាកច្ឆា ឯតម្មង្គលមុត្តមំ ។

តបោ ច ព្រហ្មចរិយញ្ច អរិយសច្ចានទស្សនំ

និព្ពានសច្ឆិកិរិយោ ច ឯតម្មង្គលមុត្តមំ ។

---

๑. ម. អារតិ វិរតិ ។

ការបំរើមាតាបិតា ១ សេចក្តីសង្រ្គោះដល់បុត្រនឹងភរិយា ១ ការងារ
ចំណេញ ដែលមិនច្របូកច្របល់ ១ នេះជាមង្គល ដ៏ខ្ពង់ខ្ពស់ ។
ការបរិច្ចាគទាន ១ ការប្រព្រឹត្តិធម៌ ១ សេចក្តីសង្រ្គោះញាតិចំណេញ
១ ការងារចំណេញ ដែលមិនមានទោស ១ នេះជាមង្គល
ដ៏ខ្ពង់ខ្ពស់ ។
ការមិនត្រេកអរក្នុងបាបនឹងការវៀរចាកបាប ១ សេចក្តីសង្រួមចាក
ការផឹកទឹកស្រវឹង ១ សេចក្តីមិនប្រមាទ ក្នុងធម៌ចំណេញ ១
នេះជាមង្គល ដ៏ខ្ពង់ខ្ពស់ ។
សេចក្តីគោរព ១ សេចក្តីនុនលំទោន ១ សេចក្តីត្រេកអរតាមមាន
តាមបាន ១ កាពជាអ្នកដឹងនូវគុណគារៈ ដែលអ្នកដទៃធ្វើហើយ ១
ការស្តាប់នូវធម៌តាមកាល ១ នេះជាមង្គល ដ៏ខ្ពង់ខ្ពស់ ។
សេចក្តីអត់ធន់ ១ ការៈនៃបុគ្គលដែលគេប្រដៅបានដោយងាយ ១
ការជួបប្រទះនូវសមណៈចំណេញ ១ ការសន្ទនាទៅវិញទៅមក
នូវធម៌តាមកាល ១ នេះជាមង្គល ដ៏ខ្ពង់ខ្ពស់ ។
សេចក្តីព្យាយាមដុតនូវបាបធម៌ ១ ការប្រព្រឹត្តិនូវធម៌ដ៏ប្រសើរ ១
ការយើញនូវអរិយសច្ចចំណេញ ១ ការធ្វើឲ្យជាក់ច្បាស់នូវព្រះ
និព្វាន ១ នេះជាមង្គល ដ៏ខ្ពង់ខ្ពស់ ។

ឥច្ចេវស្ស លោកធម្មេហិ ចិត្តំ យស្ស ន កម្បតិ
អសោកំ វិរជំ ខេមំ ឯតម្បិ្ត្លមុត្តមំ ។
ឯតាទិសានិ កត្វាន សព្ពត្ថមបរាជិតា
សព្ពត្ថ សោត្ថិំ គច្ឆន្តិ តន្តេសំ មង្គលមុត្តមន្តិ[1] ។

មង្គលសុត្តំ និដ្ឋិតំ ។

ខុទ្ទកបាឋោ រតនសុត្តំ

[៧] យានីធ ភូតានិ សមាគតានិ
ភុម្មានិ វា យានិ វ អន្តលិក្ខេ
សព្ពេវ ភូតា សុមនា ភវន្តុ
អថោបិ សក្កច្ច សុណន្តុ ភាសិតំ
តស្មា ហិ ភូតា និសាមេថ សព្ពេ
មេត្តំ ករោថ មានុសិយា បជាយ
ទិវា ច រត្តោ ច ហរន្តិ យេ ពលិំ
តស្មា ហិ នេ រក្ខថ អប្បមត្តា ។

---

๑ ឧ.ម. មង្គលមុត្តមំ ។

ចិត្តនៃបុគ្គលណា ដែលលោកធម៌តាំងខ្លាយ ពាល់ត្រូវហើយ មិនរម្ភើបញាប់ញ័រ ๑ ការមិនមានសេចក្តីសោក ๑ ធុលីគឺកិលេសក្រាសហើយ ๑ ចិត្តក្សេមក្សាន្ត ๑ នេះជាមង្គល ដ៏ខ្ពង់ខ្ពស់ ។ ទេវតានឹងមនុស្សតាំងខ្លាយ ធ្វើនូវមង្គលតាំងខ្លាយ ប្រាកដដូច្នេះហើយ ជាអ្នកមិនចាលចាញ់ ក្នុងទីតាំងពួន តែងដល់នូវសិរីសួស្តីក្នុងទីតាំងពួន នេះជាមង្គល ដ៏ខ្ពង់ខ្ពស់ របស់ទេវតានឹងមនុស្សតាំងខ្លាយនោះ ។

ចប់ មង្គលសូត្រ ។

ខុទ្ទកបាឋ រតនសូត្រ

[๗] ពួកភូតណា ឋិតនៅលើផែនដីក្តី ពួកភូតណា ឋិតនៅក្នុងដីអាកាសក្តី ដែលមកជួបជុំ ក្នុងទីនេះ ពួកភូតតាំងអស់នោះចូរមានចិត្តល្អ មួយទៀត ចូរស្តាប់នូវភាសិតដោយគោរព ព្រោះហេតុនោះ អ្នកតាំងខ្លាយ ជាភូតតាំងអស់ ចូរស្តាប់ (នូវព្រះបរិត្ត) ចូរធ្វើនូវមេត្តាចិត្តដល់ពពួកសត្វជាមនុស្សជាតិ មនុស្សតាំងខ្លាយណា តែងនាំបកនូវពលី ក្នុងពេលថ្ងៃ នឹងពេលយប់ ព្រោះហេតុនោះ សូមអ្នកតាំងខ្លាយ កុំប្រហែសឡើយ រក្សានូវមនុស្សតាំងនោះ ។

យំ កិញ្ចិ វិត្តំ ឥធ វា ហុរំ វា
សគ្គេសុ វា យំ រតនំ បណីតំ
ន នោ សមំ អត្ថិ តថាគតេន
ឥទម្បិ ពុទ្ធេ រតនំ បណីតំ
ឯតេន សច្ចេន សុវត្ថិ ហោតុ ។
ខយំ វិរាគំ អមតំ បណីតំ
យទជ្ឈគា សក្យមុនី សមាហិតោ
ន តេន ធម្មេន សមត្ថិ កិញ្ចិ
ឥទម្បិ ធម្មេ រតនំ បណីតំ
ឯតេន សច្ចេន សុវត្ថិ ហោតុ ។
យម្ពុទ្ធសេដ្ឋោ បរិវណ្ណយី សុចឹ
សមាធិមានន្តរិកញ្ញមាហុ
សមាធិនា តេន សមោ ន វិជ្ជតិ
ឥទម្បិ ធម្មេ រតនំ បណីតំ
ឯតេន សច្ចេន សុវត្ថិ ហោតុ ។
យេ បុគ្គលា អដ្ឋ សតំ បសដ្ឋា

ទុកជាឃាវ រតនសូត្រ

ទ្រព្យណាមួយ ក្នុងលោកនេះក្តី ក្នុងលោកខាងមុខក្តី រតនៈវិសេស ក្នុងមេឃក្តី ទ្រព្យនឹងរតនៈណានោះឯង ស្មើដោយព្រះតថាគត មិនមានឡើយ រតនៈគឺព្រះពុទ្ធនេះឯង ជារតនៈដ៏ឧត្តម ដោយសច្ចៈនេះ សូមមានសេចក្តីសួស្តី ។

ព្រះសក្យមុនី ទ្រង់មានព្រះទ័យដ៏តស៊ូមាំ ឋានត្រាស់ដឹងហើយនូវព្រះធម៌ណា ជាទីប្រាសចាកធូលី ជាទីប្រាសចាកកិលេស ជាធម៌មិនស្លាប់ ជាធម៌ឧត្តម រតនៈនឹមួយស្មើដោយព្រះធម៌នោះមិនមាន រតនៈគឺព្រះធម៌នេះឯង ជារតនៈដ៏ឧត្តម ដោយពាក្យសច្ចៈនេះ សូមមានសេចក្តីសួស្តី ។

ព្រះពុទ្ធជាបុគ្គលប្រសើរ ទ្រង់សរសើរនូវសមាធិណា ថាជាធម៌ដ៏ស្អាត បណ្តាលឲ្យតាំងខ្លួន ពោលហើយនូវសមាធិណា ថាជាធម៌ឲ្យផល ដោយលំដាប់ សមាធិឯទៀតស្មើដោយសមាធិនោះមិនមានឡើយ រតនៈគឺព្រះធម៌នេះឯង ជារតនៈដ៏ឧត្តម ដោយពាក្យសច្ចៈនេះ សូមមានសេចក្តីសួស្តី ។

បុគ្គលតាំងខ្លួនណា ៨ពួក ដែលពួកសប្បុរស សរសើរហើយ

ចត្តារិ ឋានានិ យុគានិ ហោន្តិ
តេ ឧក្កដ្ឋោឡោយ្យា សុកតស្ស សាវកា
ឯតេសុ និដ្ឋានិ មហប្ផលានិ
វិនមន្តិ សង្ឃេ រតនំ បណីតំ
ឯតេន សច្ចេន សុវត្ថិ ហោតុ ។
យេ សុប្បយុត្តា មនសា ទឡ្ហេន
និក្កាមិនោ គោតមសាសនម្ហិ
តេ បត្តិបត្តា អមតំ វិគយ្ហ
លទ្ធា មុធា និព្ពុតិំ ភុញ្ជមានា
វិនមន្តិ សង្ឃេ រតនំ បណីតំ
ឯតេន សច្ចេន សុវត្ថិ ហោតុ ។
យថិន្ទខីលោ បឋវិំ សិតោ សិយា
ចតុព្ភិ វាតេភិ(๑) អសម្បកម្បិយោ
តថូបមំ សប្បុរិសំ វទាមិ
យោ អរិយសច្ចានិ អវេច្ច បស្សតិ

๑ ម.ម. ភិជ្ជតិ ។

រាប់ជាគូមាន ៤ គូ បុគ្គលទាំង៨ឦរាយនោះ ជាសាវ័កបស់ព្រះសុគត លោកគួរដល់ទក្ខិណាទាន ទានទាំងឦរាយ ដែលបុគ្គលឲ្យហើយ ចំពោះទក្ខិណេយ្យបុគ្គលទាំងឦរាយនោះ ជាទានមានផលច្រើន រតនៈគឺព្រះសង្ឃនេះឯង ជារតនៈដ៏ឧត្តម ដោយពាក្យសច្ចៈនេះ សូមមានសិរីសួស្តី ។

អរិយបុគ្គលទាំងឦរាយណា ក្នុងសាសនា នៃព្រះសម្ពុទ្ធព្រះនាមគោតម ប្រកបត្រូវល្អហើយ មានចិត្តខ្ជាប់ខ្ជួន ឥតមានសេចក្តីក្រាថ្នាឡើយ អរិយបុគ្គលទាំងឦរាយនោះ ដល់ហើយនូវអរហត្តផល សម្រេចហើយនូវព្រះនិព្វានជានូវតារលត់តែសោះ ដោយទេ (ឥតមានទៀងជួរឡើយ) ហើយទទួលនូវផលរតនៈគឺព្រះសង្ឃនេះឯង ជារតនៈដ៏ឧត្តម ដោយពាក្យសច្ចៈនេះ សូមមានសិរីសួស្តី ។

សេសរតោល ដែលគេបោះភ្ជាប់នឹងផែនដី ជារបស់មិនកំរើកញាប់ញ័រដោយខ្យល់ព្យុះ ដែលបក់មកអំពីទិសទាំង ៤ យ៉ាងណាមិញ អ្នកណាពិចារណាឃើញ នូវអរិយសច្ចទាំងឦរាយ

ឥធេវ្ហ សង្ឃេ រតនំ បណីតំ
យំកេន សច្ចេន សុវត្ថិ ហោតុ ។
យេ អរិយសង្ឃាតិ វិភាវយន្តិ
តម្ហីរុបញ្ញេន សុនេសិតានិ
តិវង្គបិ តេ ហោន្តិ កុសប្បមត្តា(១)
ន តេ ភវំ អដ្ឋមមាទិយន្តិ(២)
ឥធេវ្ហ សង្ឃេ រតនំ បណីតំ
យំកេន សច្ចេន សុវត្ថិ ហោតុ ។
សហាវស្ស ទស្សនសម្បទាយ
តយេស្សុ ធម្មា ឆមាតា ភវន្តិ
សក្កាយទិដ្ឋិ វិចិកិច្ឆិតញ្ច
សីលព្ពតំ វាបិ យទត្ថិ កិញ្ចិ
បហីនា តាយេតិ ច វិប្បមុត្តោ

---

១ ម. ភូសម្បមត្តា ។ ២ ឧ. ម. អដ្ឋមំ ភវទិយន្តិ ។

តថាគតហៅអ្នកនោះ ថាជាសប្បុរស (មិនញាប់ញ័រដោយលោក-
ធម៌ទាំង៨ប្រការ) ដូចសស្សរគោលដូច្នោះឯង រតនៈគឺព្រះសង្ឃនេះ
ឯង ជារតនៈដ៏ខ្ពង់ខ្ពស់ ដោយពាក្យសច្ចៈនេះ សូមមានសិរីសួស្តី ។
អរិយបុគ្គលទាំង៤ប្រភេទណា ធ្វើឲ្យជាក់ច្បាស់ នូវអរិយសច្ចៈទាំង
៤ប្រការ ដែលព្រះតថាគត ព្រះអង្គមានប្រាជ្ញាដ៏ជ្រាលជ្រៅ
សំដែងប្រពៃហើយ អរិយបុគ្គលទាំងនោះ ទុកជាប្រមាទដ៏លើស
លប់ក៏ដោយ អរិយបុគ្គលទាំងនោះ គង់មិនយកកំណើតជាគំរប់៨
គឺមិនកើតទៀតហួសពី ៧ ជាតិឡើយ រតនៈគឺព្រះសង្ឃនេះឯង
ជារតនៈដ៏ខ្ពង់ខ្ពស់ ដោយពាក្យសច្ចៈនេះ សូមមានសិរីសួស្តី ។
(សំយោជនក្លេស៣ យ៉ាងគឺ)សក្កាយទិដ្ឋិ វិចិកិច្ឆា និងសីលព្វត-
បរាមាសៈណាមួយ ធម៌ទាំង៣ប្រការ ៣នោះ សោតាបន្នបុគ្គលនោះ
បានលះបង់ហើយ ជាមួយនឹងទស្សនសម្បទា គឺសោតាបត្តិមគ្គ
មួយទៀត សោតាបន្នបុគ្គល រួចស្រឡះចាកអបាយទាំង ៤ ផង

สุตฺตนฺตปิฏกโต ขุทฺทกนิกายสฺส ขุทฺทกปาโฐ

ยา ตาทิสี ตาทิสเก อกาฬโก ตาทิสี[๑]

ฉนฺทสฺมิ สงฺฆสฺส ยสนฺธโร ปณีตสี

ปโสน สงฺเฆน สุปาตุ เหตุ ฯ

ตาทิญฺหิ สา ทกฺขิ ตาทิเกสุ[๒] ตาทิสกา

ตายเน ปาตายุน[๓] เตสา ปา

อกาฬโก สา ตสฺส ปฏิจฺฉาย[๔]

อกาฬตา นิฏฺฐปนสฺส ปุตฺตา

ฉนฺทสฺมิ สงฺฆสฺส ยสนฺธโร ปณีตสี

ปโสน สงฺเฆน สุปาตุ เหตุ ฯ

วนปฺปกุโฏ ยถา ผุสฺสิตคฺเค

ตีหูนมาสา ปมมสฺมึ ตีเห

ตถูปมี ธมฺมวรา อเนสยี

นิพฺพานคามี ปรมี หิตาย

ฉนฺทสฺมิ พุทฺธ ยสนฺธโร ปณีตสี

ปโสน สงฺเฆน สุปาตุ เหตุ ฯ

---

๑ ม. อกาฬกตุ ฯ ๒ ม. กมฺมกเภตา ฯ ๓ ส.ม. ภิกฺขาจรา ฯ ๔ ฉ. ปฏิจฺฉาทาย ฯ

មិនអាចធ្វើនូវអតិដ្ឋាន[1] ពាំនឹងឮយ៉ាងណា រតនៈគឺព្រះសង្ឃនេះ ឯង ជារតនៈដ៏ឧត្តម ដោយពាក្យសច្ចៈនេះ សូមមានសិរីសួស្តី ។ ប្រសិនបើ សោតាបន្នបុគ្គលនោះ ធ្វើនូវបាបកម្មដោយកាយវាចា ឬដោយចិត្តក៏ដោយ (ព្រោះសេចក្តីភ្លាំងភ្លាត់) សោតាបន្នបុគ្គលនោះ មិនដែលបិទបាំងនូវបាបកម្មនោះទេឬ ការៈនៃបុគ្គលមានផ្លូវនៃ ព្រះនិព្វានឃើញហើយ ជាបុគ្គលមិនដែលបិទបាំងបាបកម្ម ព្រះ ពុទ្ធពាំនឹងឮយ៉ាង បានត្រាស់សំដែងហើយ រតនៈគឺព្រះសង្ឃនេះឯង ជារតនៈដ៏ឧត្តម ដោយពាក្យសច្ចៈនេះ សូមមានសិរីសួស្តី ។ គុម្ពឈើក្នុងព្រៃ មានត្រយូលួតលាស់ ក្នុងខាងដើមគិម្ហរដូវគឺខែ ក្តៅ យ៉ាងណាមិញ ព្រះពុទ្ធ បានត្រាស់សំដែងហើយនូវធម៌ ដ៏ប្រសើរ ជាធម៌អាចញុំាងសត្វពាំនឹងឮយ៉ាង ឲ្យដល់នូវព្រះនិព្វាន ដើម្បីប្រយោជន៍ដ៏ឧត្តម ដូចជាគុម្ពឈើ មានក្នុងព្រៃ ដូច្នោះឯង រតនៈគឺព្រះពុទ្ធនេះឯង ជារតនៈដ៏ឧត្តម ដោយពាក្យសច្ចៈនេះ សូមមានសិរីសួស្តី ។

---

១. សំដៅយកអនន្តរិយកម្ម ៥ ដែលការបែរចិត្តទៅកាន់មាសនាងទៃ ។

ขุทฺทกปาฐ รตนสุตฺต

วเร วรญฺญู วรเทา วรหเร
อนุตฺตเร ธมฺมวรํ อเทสยิ
อิทมฺปิ พุทฺเธ รตนํ ปณีตํ
เอเตน สจฺเจน สุวตฺถิ โหตุ ฯ
ขีณาสวา วิรชา วิมุตฺตา [๑]ติณฺณา สมฺปุรา
วิรตฺตจิตฺตา ภวเนกเกหิ [๒]อาสฺสี
เต ขีณเสนา วิชิตุภยาสา
ตถาคตสฺสาทิปทา ทยาวา
อิทมฺปิ สงฺเฆ รตนํ ปณีตํ
เอเตน สจฺเจน สุวตฺถิ โหตุ ฯ
ยาวตีธ ภูตานิ สมาคตานิ
ภุมฺมานิ วา ยานิ ว อนฺตลิกฺเข
ตถาคตํ เทวมนุสฺสปูชิตํ
พุทฺธึ นมสฺสาม สุวตฺถิ โหตุ ฯ

---

๑ ม. ติณฺณ ฯ ๒ ว. วิรตฺตจิตฺตา อายตึเก ฯ

๒.ទុកជាបី រតនសូត្រ

ព្រះសម្មាសម្ពុទ្ធ ជាបុគ្គលប្រសើរ ទ្រង់ជ្រាបនូវធម៌ដ៏ប្រសើរ ទ្រង់ប្រទាននូវធម៌ដ៏ប្រសើរ ទ្រង់នាំមកនូវធម៌ដ៏ប្រសើរ ព្រះអង្គប្រសើរ ឥតមានអ្នកណាមួយស្មើ ទ្រង់ត្រាស់សំដែងហើយ នូវធម៌ដ៏ប្រសើរ រតនៈគឺព្រះពុទ្ធនេះឯង ជារតនៈដ៏ឧត្តម ដោយ ពាក្យសច្ចៈនេះ សូមមានសិរីសួស្តី ។

កម្មចាស់ (របស់អរិយបុគ្គលណា) អស់ហើយ កម្មថ្មី រមែង មិនកើតក្រោកដ អរិយបុគ្គលទាំងឡាយណាមានចិត្តនឿយណាយ ហើយកន្ធត់តពតទៅ អរិយបុគ្គលទាំងឡាយនោះ មានពួជអស់ ហើយ មានធន៖គឺសេចក្តីប៉ុនប៉ងកន្ធត់ចិត្ត មិនរុះបំរើនឡើង ជា អ្នកមានប្រាជ្ញា តែងរលត់ទៅ ដូចប្រទីប ដែលរលត់ទៅនេះ រតនៈគឺព្រះសង្ឃនេះឯង ជារតន ដ៏ឧត្តម ដោយពាក្យសច្ចៈនេះ សូមមានសិរីសួស្តី ។

ពួកភូតណា ឋិតនៅលើផែនដីក្តី ពួកភូតណា ឋិតនៅក្នុងដំ អាកាសក្តី ដែលមកប្រជុំគ្នា កន្ធត់នេះ យើងទាំងឡាយសូម នមស្ការនូវព្រះពុទ្ធជាម្ចាស់ ទ្រង់បានត្រាស់មកហើយដូចគ្នាដែល ទេវតានិងមនុស្សតែងបូជា សូមមានសិរីសួស្តី ។

យានីធ ភូតានិ សមាគតានិ
ភុម្មានិ វា យានិ វ អន្តលិក្ខេ
តថាគតំ នេរមនុស្សបូជិតំ
ពុទ្ធំ នមស្សាម សុវត្ថិ ហោតុ ។
យានីធ ភូតានិ សមាគតានិ
ភុម្មានិ វា យានិ វ អន្តលិក្ខេ
តថាគតំ នេរមនុស្សបូជិតំ
ធម្មំ នមស្សាម សុវត្ថិ ហោតុ ។

រតនសុត្តំ និដ្ឋិតំ ។

ខុទ្ទកបាឋបាឡិ តិរោកុដ្ដកណ្ឌំ

[៨] មត្តាសុខបរិហ្ហារា បសេ្ស ចេ វិបុលំ សុខំ
ចជេ មត្តាសុខំ ធីរោ សមេ្បស្សំ វិបុលំ សុខំ ។
តិរោកុដ្ដេសុ តិដ្ឋន្តិ សន្ធិសិង្ឃាដកេសុ ច
ទ្វារពាហាសុ តិដ្ឋន្តិ អាគន្ត្វាន សកំ ឃរំ ។

ពួកភូតណា ឋិតនៅលើផែនដីក្តី ពួកភូតណា ឋិតនៅឰដ៏អាកាសក្តី ដែលមកប្រជុំគ្នា ក្នុងទីនេះ យើងទាំងឡាយសូមនមស្ការនូវព្រះធម៌ដែលមានមកហើយដូចគ្នា ដែលមនុស្សនឹងទេវតាតែងបូជា សូមមានសិរីសួស្តី ។

ពួកភូតណា ឋិតនៅលើផែនដីក្តី ពួកភូតណា ឋិតនៅ ឰដ៏អាកាសក្តី ដែលមកប្រជុំគ្នា ក្នុងទីនេះ យើងទាំងឡាយ សូមនមស្ការ នូវព្រះសង្ឃ ដែលមានមកហើយដូចគ្នា ដែលទេវតានឹងមនុស្សតែងបូជា សូមមានសិរីសួស្តី ។

ចប់ រតនសូត្រ ។

ខុទ្ទកបាឋ តិរោកុដ្ដកណ្ឌ

(៨) បើបុគ្គលឃើញសុខធំទូលាយ ព្រោះលះសុខមានប្រមាណតិចចេញ អ្នកមានប្រាជ្ញា គប្បីលះសុខមានប្រមាណតិចចេញ ។

ប្រែតទាំងឡាយ មកកាន់ផ្ទះនៃញាតិ ដោយគិតថា ផ្ទះរបស់ខ្លួនហើយឈរនៅដីតខាងក្រៅជញ្ជាំងទាំងឡាយខ្លះ នាំផ្លូវបែកជា ៤ នឹងផ្លូវបែកជា ៣ ទាំងឡាយខ្លះ ដីតទ្វារក្រៅនឹងទ្វារផ្ទះទាំងឡាយខ្លះ ។

ขุទฺทกปาเ តិភេកុត្តរកណ្ឌំ

បហូតេ[๑] អន្នបានម្ហិ ๑ផ្លេភោជ្ជេ ๒បដ្ឋិតេ
ន តេសំ កោចិ សរតិ សត្តានំ តម្ហបច្ចយោ ฯ
ឯវំ ឧឧន្តិ ញាតីនំ យេ ហោន្តិ អនុកម្បកា
សុចិំ បណីតំ កាលេន កប្បិយំ បានភោជនំ
ឥទំ វោ ញាតីនំ ហោតុ សុខិតា ហោន្តុ ញាតយោ ฯ
តេ ច តត្ថ សមាគន្ត្វា ញាតិបេតា សមាគតា
បហូតេ អន្នបានម្ហិ សក្កច្ចំ អនុមោទរេ
ចិរំ ជីវន្តុ នោ ញាតី យេសំ ហេតុ លភាមសេ
អម្ហាកញ្ច កតា បូជា ទាយកា ច អនិប្ផលា
ន ហិ តត្ថ កសិ អត្ថិ គោរក្ខេត្ថ ន វិជ្ជតិ
វណិជ្ជា តាទិសី នត្ថិ ហិរញ្ញេន កយោ កយំ[๒]

---

๑ ខ. បហូតេ ฯ ๒ ខ. កយក្កយំ ฯ ម. កយោ កយំ ฯ

កាលបើបាយទឹក ប៉ង្អែមនឹងចំអបមានគ្រប់គ្រាន់ ដែលពួកញាតិ
អាត់តែងទុកហើយ មិនមាន ញាតិណាមួយ នឹកដល់ប្រេតទាំង
ឡាយនោះ ព្រោះតម្នាបស់សត្វទាំងឡាយ ជាបច្ច័យ ។ ញាតិ
ទាំងឡាយណា ជាអ្នកអនុគ្រោះ ញាតិទាំងឡាយនោះ រមែង
ទុទ្ទិសឲ្យនូវទឹកនឹងកោដន៎ដ៏ម៉ត់ចត់ ដ៏ប្រសើរ ជារបស់គួរតាមកាល
ដល់ញាតិទាំងឡាយ យ៉ាងនេះថា ទាននេះ ចូរមានដល់ញាតិ
ទាំងឡាយ សូមញាតិទាំងឡាយ បានដល់នូវសេចក្តីសុខ ។
ចំណែក ប្រេតជាញាតិ ជាអ្នកមកប្រជុំគ្នាទាំងនោះ មកជួបជុំគ្នា
ហើយ ក្នុងមន្ទីរឲ្យទាននោះ កាលបើបាយនឹងទឹក មានល្មមគ្រាន់
ក៏អនុមោទនា ដោយគោរពថា យើងទាំងឡាយ បានសម្បត្តិនេះ
ព្រោះហេតុនៃញាតិទាំងឡាយណា សូមពួកញាតិរបស់យើងទាំង
ឡាយនោះ រស់នៅយឺនយូរ ការបូជាដែលញាតិទាំងឡាយធ្វើហើយ
ដល់យើងទាំងឡាយក្តី ញាតិទាំងឡាយ ជាអ្នកឲ្យទានក្តី មិនមែនជា
ឥតផលទេ្បីយ តសិកម្មក៏មិនមានក្នុងភូមិនៃប្រេតនោះ គោរក្ខកម្ម
ក៏មិនមានក្នុងភូមិនៃប្រេតនោះ ពាណិជ្ជកម្មដែលជាហេតុបានសម្បត្តិ
បែបដូច្នោះក៏មិនមាន ការលក់ដូរផ្សាស់ផ្តូរ ដោយប្រាក់ក៏មិនមាន

ឥតោ និន្នេន យោគេន្តិ ចេតា ភាលភតា តហិំ ។

ទុន្តតេ[1] ទមកំ រុដ្ឋំ[2] យថា និន្នំ បវត្តតិ

ឯវមេវ ឥតោ និន្នំ ចេតានំ ទុបភប្បតិ ។

យថា ភរវមហា បុរា បរិបូរេន្តិ សាគរំ

ឯវមេវ ឥតោ និន្នំ ចេតានំ ទុបភប្បតិ ។

អធាសិ មេ អភាសិ មេ ញាតិមិត្តា សខា ច មេ

ចេតានំ ទក្ខិណំ ទជ្ជា បុព្ពេ ភតមនុស្សរំ ។

ន ហិ រុណ្ណំ វា សោចេតា វា យោវញ្ញា[3] បរិហាយតិ

ន តំ ចេតាទមត្ថាយ ឯវំ តិដ្ឋតិ ញាតយោ ។

---

១ ម.ម. ទន្តមែ ។ ២ ម. រដ្ឋំ ។ ៣ ម.ម. យោបញ្ញ ។

បុគ្គលទាំងឡាយ ធ្វើកាលកិរិយា លះលោកនេះទៅហើយ រមែងញុំាងអត្តភាពឲ្យប្រព្រឹត្តទៅ ក្នុងប្រេតវិស័យនោះ ដោយផលទានដែលញាតិទាំងឡាយឧទ្ទិសឲ្យហើយអំពីលោកនេះ ។ ទឹកធ្លាក់ចុះលើទីទួល រមែងហូរទៅកាន់ទីតាបដូចម្តេចមិញ ទានដែលបុគ្គលឲ្យហើយអំពីលោកនេះ រមែងសម្រេចផល ដល់ប្រេតទាំងឡាយ ដូច្នេះដែរ ។ ផ្លូវទឹកមានទន្លេនិងស្ទឹងជាដើម ដ៏ពេញ រមែងញុំាងសាគរឲ្យពេញ ប្រៀបដូចម្តេចមិញ ទានដែលបុគ្គលឲ្យហើយអំពីលោកនេះ រមែងសម្រេចផល ដល់ប្រេតទាំងឡាយ ដូច្នោះដែរ ។ បុគ្គលកាលរឭកយើញនូវឧបការគុណ ដែលលោកធ្វើទុកដល់ខ្លួន ក្នុងកាលមុនថា អ្នកនេះបានឲ្យរបស់នេះដល់អញ អ្នកនេះបានធ្វើគុណនេះ ដល់អញ ជនទាំងឡាយនោះ ជាញាតិមិត្រ ជាសំឡាញ់របស់អញដូច្នេះហើយ គួរឲ្យទក្ខិណាទាន ចំពោះប្រេតទាំងឡាយ ។ ការយំសោកសោនឹងការខ្សឹកខ្សួលដទៃណា មិនមានប្រយោជន៍ឡើយ ការយំជាដើមនោះ មិនសម្រេចប្រយោជន៍ ដល់ប្រេតទាំងឡាយទេ ញាតិទាំងឡាយ រមែងឋិតនៅយ៉ាងនោះដដែល ឥតបានដឹងបានឮឡើយ ។

អយញ្ច ខោ ឧត្តិណោ ឥច្ចា សន្ធ្យមិ សុបតិដ្ឋិតា
ឥឃរត្តំ ហិតាយស្ស ហានសោ ឧបកប្បតិ ។
សោ ញាតិធម្មោ ច អយំ ឯឧសន្ធិតោ
បេតានបូជា[1] ច កតា ឧឡារា
ពលញ្ច ភិក្ខូនមនុប្បទិន្នំ
តុម្ហេហិ បុញ្ញំ បសុតំ អនប្បកន្តិ[2] ។

តិកេកុទ្ធកណ្ឌំ ឥដ្ឋិតំ ។

ខុទ្ទកប្បាឋេ ឥធិកណ្ឌំ

[៩] ឥធ ឥធេតិ បុរិសោ តម្ហីវេ ឧទកដ្ឋំកេ[3]
អត្តេ កិច្ចេ សមុប្បន្នេ អត្តាយ មេ អវិស្សតិ
ភវតោ វា ឧប្បត្តិស្ស ភោគតោ បីឥតិស្ស វា
ឥណាស្ស វា បមោក្ខាយ ឧត្តិស្ស អាបទាសុ វា

---

១ ឧ. បេតានំ បូជា ។ ២ ឧ. អនប្បកំ ។ ៣ ឧ. ឧទកត្តិកេ ។ អដ្ឋកថាយំ ឥមិទំសោយេវ ហោតិ ។

លុះតែទក្ខិណាទាននេះ ដែលបុគ្គលបានឲ្យហើយ ដំកល់ទុកប្រពៃ
ហើយ ក្នុងសង្ឃ ទើបសម្រេចផលដោយរួសរាន់ ដើម្បីប្រយោជន៍
ដល់ប្រេតនោះ អស់កាលជាអង្វែង ។ ញាតិធម៌នោះឈ្មោះថា
មហាបពិត្រ បានសំដែងជាវបបយ៉ាងហើយ ការបូជាដ៏ថ្លៃថ្លា
បំពោះប្រេតពាំងឡាយ ឈ្មោះថា បានធ្វើហើយផង កំលាំងកាយ
នៃកិក្ខុពាំងឡាយ ឈ្មោះថា បានបំពេញឲ្យហើយផង បុណ្យឈ្មោះ
ថា បានសន្សំទុក មិនមែនតិចឡើយផង ។

ចប់ តិរោកុដ្ឋវណ្ណ ។

ខុទ្ទកបាឋ ឥធិកណ្ឌ

(๙) បុរសកប់កំណប់ទ្រព្យទុកក្នុងទីជ្រៅ ជាទីបំផុតនៃទឹក ដោយគិតថា កាលបើតិច្ច ដែលត្រូវការតិចឡើងហើយ ទ្រព្យនេះងឹងបានជាប្រយោជន៍ ដល់អាត្មាអញ ដែលត្រូវពួកបច្ចាមិត្រពោលបង្អាប់ងឹងបានដោះខ្លួនចេញពីស្តេច ឬ ត្រូវចោរបៀតបៀនងឹងបានដោះខ្លួនចេញពីចោរងឹងបានដោះបំណុល ឬ ក្នុងពេលទុរភិក្ស ឬ កំក្នុងកាលអន្តរាយពាំងឡាយ

ឯតទត្ថាយ លោកស្មឹ ឯឯ ជាម ឯឯយ្យតំ ។

តាវស្សុ ឯមាតោ សន្តោ តម្ហីវេ ខុទកគន្ធិកោ

ន សញ្ញោ សព្ពធាយេវ[1] តស្ស តំ ខុបកប្បតិ

ឯឯ ឯ ហាជា ចវតិ សញ្ញោ ឯស្ស វិមុយ្ហតិ

ជាតា ឯ អបជាមេន្តិ យក្ខោ ឯបិ មារន្តិ ឯំ

អប្បិយោ ឯបិ ធាយោធា ខុទ្ធន្តិ អបស្សតោ

យធា បុញ្ញក្ខយោ ហោតិ សព្ពមេតំ វិនស្សតិ ។

យស្ស ធានេន សីលេន សញ្ញមេន[2] ទមេន ច

ឯឯ សុឯមាតោ ហោតិ ឥត្ថិយោ បុរិសស្ស ឯ

ខេតិយម្ហិ ច[3]សន្ថេ ឯ បុក្កលេ អតិថីសុ ឯ

មាតរិ បិតរិ ឯបិ[4] អថោ ជេដ្ឋម្ហិ ភាតរិ

ឯសោ ឯឯ សុឯមាតោ អាជេយ្យោ អនុតាមិតោ

បហាយ តមធីយេសុ ឯតំ អាធាយ តច្ចតិ

---

១ ឧ.ម. ឯវ ។ ២ ឧ.ម. សំយមេន ។ ៣ ឧ. ។ ។ ៤ ម. ឯបិ ។

ធម្មតាកំណប់ដែលគេកប់ទុកក្នុងលោក ដើម្បីប្រយោជន៍នេះឯង ។ កំណប់ដែលបុគ្គលកប់ ក្នុងទីស្រែ មានទីបំផុតទល់នឹងទឹក ដល់ម្ល៉ោះ កំណប់ទ្រព្យទាំងអស់នោះ ក៏មិនសម្រេចដល់បុគ្គលនោះសព្វកាលទេ ដ្បិតថា កំណប់ទ្រព្យ រមែងឃ្លាតទៅចាកទីខ្លះ សេចក្តីចំណាំរបស់បុគ្គលនោះ រមែងវង្វេងទៅខ្លះ នាគទាំងឡាយ រមែងនាំដញ្ជូនទៅខ្លះ ពុំនោះសោត ពួកយក្សនាំយកទ្រព្យនោះទៅខ្លះ អ្នកទទួលមតិកដែលមិនជាទីស្រឡាញ់ រមែងគាស់យកនូវកំណប់ទ្រព្យនោះ កាលខ្លួនមិនបានឃើញខ្លះ ខ្លួនអស់បុណ្យទៅវិលាណា កំណប់ទ្រព្យទាំងអស់នោះ រមែងវិនាសបាត់បង់ទៅក្នុងវេលានោះ ។ កំណប់ទ្រព្យដែលស្ត្រី ឬ បុរសណា បានតប់ទុកល្អហើយ ដោយទាន សីល ដោយការសង្រួម នឹងដោយការទូន្មានខ្លួន ក្នុងចេតិយ ឬក្នុងសង្ឃ ឬក្នុងបុគ្គល ឬក្នុងពួកភ្ញៀវ ឬមួយក្នុងមាតា ក្នុងបិតា ឬថា ក្នុងបងប្រុស-ស្រីដែលជាច្បង កំណប់ទ្រព្យនុ៎ះ ចាត់ជាកំណប់ទ្រព្យដែលតប់ទុកប្រពៃហើយនរណា ។ មិនគប្បីផ្លាស់ប្តូរបានជាកំណប់ទ្រព្យ ដែលជាប់តាមខ្លួនទៅ គាលពោគៈទាំងឡាយដែលខ្លួនត្រូវលះបង់ហើយទៅ ខ្លួនរមែងគាន់តែនយកកំណប់ទ្រព្យគឺបុណ្យនុ៎ះទៅ

ขอขมาพระอธิการณ์

อสาธารณภยมฺเปสุ อโจรมหาวเนฺ[(๑)] นิจฺจ ฯ

ตายิกาย ฉวีหาร ปุพฺพาจริย เยหิ นิจฺจ อนุตาปิโตหิ

ปิสุน เตหิมนุสฺสานิ สพฺพกาเยน เตหิ นิจฺจ

ยาวนฺโต เตหิภิกฺขเว สพฺเพเตสน ขมาปิโต ฯ

สุวณฺณกา สุสรกา สุสณฺฐานา สุรูปกา

อาธิปจฺจ[(๒)] ปริวารา สพฺเพเตสน ขมาปิโต ฯ

ปเตสรฏฺเ ฯสฺสริย ตกฺกาวตฺถุสุจิ ปิย

เตหิรชฺชมฺปิ ทิพฺพสุ สพฺเพเตสน ขมาปิโต ฯ

มหานุสฺสโก ย สมฺปตฺโต เตหิเลาเกา ย ยา รตี

ยา ย ทิพฺพาน สมฺปตฺติ สพฺเพเตสน ขมาปิโต ฯ

นิพฺพานสมฺปาปกมฺม เยหิเมสา เต ย ยมฺปุพฺเพ

ปิฏฺฐิปิปฺผลิสีสกาเย สพฺเพเตสน ขมาปิโต ฯ

---

๑ ฉ.ม. อโจกาหรณ ฯ ๒ ฉ.ม. อธิปจฺจ ฯ

កំណប់ទ្រព្យគឺបុណ្យ មិនទូទៅ ដល់ពួកជនដទៃ ជារបស់ដែលចោរលួចទៅមិនបាន ។ កំណប់ទ្រព្យ គឺបុណ្យណា ជាប់តាមខ្លួនទៅបាន អ្នកប្រាជ្ញ គួរធ្វើនូវកំណប់ទ្រព្យគឺបុណ្យនោះ កំណប់ទ្រព្យ គឺបុណ្យនុ៎ះ ឲ្យនូវសេចក្តីប្រាថ្នាគ្រប់យ៉ាង ដល់ទេវតានឹងមនុស្សទាំងពួង ពួកទេវតានឹងមនុស្សទាំងពួង ប្រាថ្នាណាស់នូវផលណា ។ ផលទាំងពួងនោះ ។ រមែងបានដោយកំណប់ទ្រព្យគឺបុណ្យនុ៎ះ ។ ភាពជាអ្នកមានសម្បុរផូរផង់ មានសំឡេងពីរោះ ទ្រង់ទ្រាយល្អ រូបល្អ ជាអធិបតី មានយសបរិវារ ផលទាំងអស់ រមែងបានដោយកំណប់ទ្រព្យគឺបុណ្យនុ៎ះ ។ ភាពជាស្តេចប្រទេសកាជ ឥស្សរិយយស សេចក្តីសុខរបស់ស្តេចចក្រពត្តិ ជាទីស្រឡាញ់ ភាពជាស្តេចនៃទេវតា ក្នុងទេពនិកាយទាំងពួង ផលទាំងអស់ រមែងបានដោយកំណប់ទ្រព្យគឺបុណ្យនុ៎ះ ។ សម្បត្តិជារបស់មនុស្សណាមួយ សេចក្តីត្រេកអរ ក្នុងទេវលោកណាមួយ សម្បត្តិគឺព្រះនិព្វានណាមួយ សម្បត្តិទាំងអស់ រមែងបានដោយកំណប់ទ្រព្យគឺបុណ្យនុ៎ះ ។ ភាពនៃបុគ្គលគាលអស្រ័យមិត្តសម្បទា បើប្រកបសេចក្តីព្យាយាម ដោយឧបាយដែលត្រូវ ជាអ្នកស្វាគ់ក្នុងវិជ្ជា និងវិមុត្តិ ឥដ្ឋផលទាំងអស់ បានដោយកំណប់ទ្រព្យគឺបុណ្យនោះ ។

បដិសម្ភិទា វិមោក្ខា[๑]ច យោ ច សាវកបារមី
បច្ចេកពោធិ ពុទ្ធភូមិ សព្ពមេតេន លព្ភតិ ។
ឯវំ មហត្ថិកា[๒]ឯសា យនិនំ បុញ្ញសម្បទា
តស្មា ឥរ បសំសន្តិ បណ្ឌិតា កតបុញ្ញតន្តិ ។

និធិកណ្ឌំ[๓] និដ្ឋិតំ ។

ខុទ្ទកបាឋបាឡិ ករណីយមេត្តសុត្តំ

[๑๐]ករណីយមត្ថកុសលេន យន្តំ សន្តំ បទំ អភិសមេច្ច
សក្កោ ឧជុ ច សុហុជុ ច សុវចោ ចស្ស មុទុ អនតិមានី
សន្តុស្សកោ ច សុភរោ ច អប្បកិច្ចោ ច សល្លហុកវុត្តី
សន្តិន្ទ្រិយោ ច និបកោ ច អប្បគព្ភោ កុលេសុ អនណុគិទ្ធោ
ន ច ខុទ្ទំសមាចរេ[๔] កិញ្ចិ យេន វិញ្ញូ បរេ ឧបវទេយ្យុំ

---

๑ ម. វិមោក្ខា ។ ๒ ម. មហិទ្ធិកា ។ ๓ ឧ.ម. និធិកណ្ឌសុត្តំ ។ ๔ ឧ.ម.ន ច ខុទ្ទមាចរេ ។

បដិសម្ភិទា វិមោក្ខ សាវកបារមីញាណ បច្ចេកពោធិញាណនឹងពុទ្ធ-
ភូមិណា ។ ឥដ្ឋផលទាំងអស់ រមែងបានដោយកំណត់ទ្រព្យគឺបុណ្យ
+
នុ៎ះ ។ បុញ្ញសម្បទានេះ ឲ្យសំរេចប្រយោជន៍ដ៏ធំ ដោយប្រការដូច្នេះ
ព្រោះហេតុនោះ អ្នកប្រាជ្ញទាំងឡាយ ជាធីរជន ទើបសរសើរ
នូវភាពនៃបុគ្គលជាអ្នកមានបុណ្យធ្វើទុកហើយ ។

ចប់ ធនិកសូត្រ ។

ខុទ្ទកបាឋ ករណីយមេត្តសូត្រ

(๑๐) កិច្ចណា (ដែលព្រះអរិយៈ) បានត្រាស់ដឹងនូវបទដ៏ស្ងប់រម្ងាប់
គឺព្រះនិព្វាន (បានធ្វើហើយ) កិច្ចនោះ កុលបុត្រអ្នកឈ្លាស
ក្នុងប្រយោជន៍គួរធ្វើ (កុលបុត្រនោះ) ជាអ្នកអាចហ៊ានផង ត្រង់ដោយ
កាយទំនងវាចាផង ត្រង់ល្អដោយចិត្តផង គេប្រដៅងាយផង មាន
សុភាពទន់ភ្លន់ផង មិនមានមានះដ៏ក្រៃលែងផង សន្តោសផង គេ
ចិញ្ចឹមងាយផង មានកិច្ចតូរៈតិចផង ប្រព្រឹត្តស្រាលត្រម (មាន
បរិក្ខារតិច) ផង មានឥន្ទ្រិយស្រគត់ស្រគំផង មានប្រាជ្ញាចាស់ផង
មិនឃើសឃ្នង់ផង មិនជាប់ដំពាក់ក្នុងត្រកូលទាំងឡាយផង វិញ្ញូជន
ទាំងឡាយ គួរតិះដៀលជនទាំងឡាយដទៃ ដោយកម្មណា
មិនគួរប្រព្រឹត្តធ្វើ នូវកម្មនោះ ដែលជាកម្មណាមក សូម្បីតិចតួច

สุขิโน วา เขมิโน โหนฺตุ สพฺเพ สตฺตา ภวนฺตุ สุขิตตฺตา

เย เกจิ ปาณภูตตฺถิ ตสา วา ถาวรา วา[๑]อนวเสสา

ทีฆา วา เย มหนฺตา วา[๒]มชฺฌิมา รสฺสกา อณุกถูลา

ทิฏฺา วา เย จ อทิฏฺา เย จ ทูเร วสนฺติ อวิทูเร

ภูตา วา สมฺภเวสี วา สพฺเพ สตฺตา ภวนฺตุ สุขิตตฺตา ฯ

น ปเร ปรํ นิกุพฺเพถ นาติมญฺเถ กตฺถจิ[๓]นํ กิญฺจิ[๔]

พฺยาโรสนา ปฏิฆสญฺา นาญฺมญฺสฺส ทุกฺขมิจฺเฉยฺย ฯ

มาตา ยถา นิยํ ปุตฺตํ อายุสา เอกปุตฺตมนุรกฺเข

เอวมฺปิ สพฺพภูเตสุ มานสมฺภาวเย อปริมาณํ ฯ

---

๑ ม. ว ฯ ๒ ปาฬิ. ฉตฺติ ฯ ๓ ม. กตฺถจิ ว ฯ ๔ ขุ. กญฺจิ ฯ

(ហើយគួរផ្សាយមេត្តាចិត្ត បំពោះពពួកសត្វថា) សត្វទាំងឡាយ ទាំងពួង សូមឲ្យមានសេចក្តីសុខ ឲ្យមានសេចក្តីក្សេម ឲ្យមានខ្លួនដល់នូវសេចក្តីសុខចុះ សត្វមានដរាតទាំងឡាយណាមួយឥតមានសេសសល់ ទោះសត្វមានសេចក្តីគក់សូត គឺនៅមានតណ្ហាក្តី មាំមួនគឺឥតមានតណ្ហាក្តី សត្វទាំងឡាយណា មានកាយវែងក្តី ធំក្តី មានកាយយ៉ាងកណ្តាលក្តី ខ្លីក្តី មានកាយស្គម ឬ ជាត់ក្តី សត្វទាំងឡាយណា ដែលយើងឃើញហើយក្តី មិនឃើញហើយក្តី សត្វទាំងឡាយណា នៅក្នុងទីឆ្ងាយក្តី ក្នុងទីដិតក្តី ដែលកើតរួចមកហើយក្តី ដែលកំពុងស្វែងរកទីកើតក្តី សត្វទាំងអស់ (នោះ) ចូរមានខ្លួនជាសុខចុះ ។ សត្វដទៃមិនគួរកំហែងបៀតបៀនទូវសត្វដទៃឡើយ មិនគួរមើលងាយគេតិចតួចក្នុងទីណាមួយឡើយ មិនគួរប្រាថ្នាទូវសេចក្តីទុក្ខដល់គ្នាទឹងគ្នា ព្រោះសេចក្តីក្រេវក្រោធទឹងសេចក្តីចំអែកចង់ឈ្លោះ ក្នុងចិត្តឡើយ ។ មាតាថ្នមរក្សាបុត្រដែលកើតអំពីខ្លួន ជាកូនតែមួយដោយអាយុ (ស្មើដោយជីវិត) យ៉ាងណាមិញ បុគ្គលគួរចំរើនមេត្តាចិត្តមិនមានប្រមាណ បំពោះសត្វទាំងឡាយទាំងពួង យ៉ាងនោះឯង ។

សុត្តន្តបិដកេ ខុទ្ទកនិកាយស្ស ខុទ្ទកបាឋោ

មេត្តញ្ច សព្ពលោកស្មិំ មានសម្ភាវយេ អបរិមាណំ
ទុទ្ធំ អនោ ច តិរិយញ្ច អសម្ពាធំ អវេរំ អសបត្តំ(๑) ។
តិដ្ឋញ្ចរំ ឯសិន្នោ វា សយានោ វា យាវ តស្ស វិគតមិទ្ធោ
ឯតំ សតិំ អធិដ្ឋេយ្យ ព្រហ្មមេតំ វិហារំ ឥធមាហុ(๒) ។
និដ្ឋំ អនុបគម្ម សីលវា ទស្សនេន សម្បន្នោ
កាមេសុ វិនេយ្យ(๓) គេធំ ន ហិ ជាតុគព្ភសេយ្យំ បុនរេតីតិ ។

មេត្តសុត្តំ និដ្ឋិតំ ។

ខុទ្ទកបាឋោ សមត្តោ(๔) ។

---

๑ ម. អវេរមសបត្តំ ។ ๒ ម. វិហារមធិដ្ឋហេ ។ ๓ ម. វិនេយ្យ ។ ๔ ទ.ម. ខុទ្ទកបាឋបញ្ចករណំ និដ្ឋិតំ ។

បុគ្គលគួរចំរើនមេត្តាចិត្ត មិនមានប្រមាណ ជាធម៌មិនចង្អៀត មិនមានពៀរ មិនមានសត្រូវ ទៅកាន់លោកទាំងអស់ គឺកន្លងទីខាងលើផង ខាងក្រោមផង ខាងទទឹងគឺត្រង់កណ្តាលផង ។ (បុគ្គលអ្នកចំរើនមេត្តាចិត្តនោះ) ទោះឈរក្តី ដើរក្តី អង្គុយក្តី ដេកក្តី ជាអ្នកមានសេចក្តីងោកងក់ ទៅប្រាសហើយ គឺជាអ្នកមិនដេកលក់ អស់កាលត្រឹមណា គួរដំកល់នូវសតិនោះ អស់កាលត្រឹមនោះ បណ្ឌិតពោលថ្លាយ នូវព្រហ្មវិហារ+ទុំៈថាជាព្រហ្មវិហារ ក្នុងសាសនានេះ ។ (បុគ្គលដែលមានមេត្តាព្រហ្មវិហារ) មិនជាប់នឹងទិដ្ឋិ ជាអ្នកមានសីល ប្រកបដោយទស្សនសម្បត្តិ គឺសោតាបត្តិមគ្គ (តទៅទៀត) បន្ទោបង់នូវសេចក្តីជាប់ចំពាក់ ក្នុងកាមទាំងឡាយ ហើយ រមែងមិនមកកាន់គភ៌សេយ្យាទៀតឡើយ ។

ចប់ មេត្តសូត្រ ។

ចប់ ខុទ្ទកបាឋ ។

ขุទ្ទកនិកាយស្ស ធម្មបទគាថា

ឧមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

[๑๑] មនោបុព្ពង្គមា ធម្មា មនោសេដ្ឋា មនោមយោ

មនសា ចេ បទុដ្ឋេន ភាសតិ វា ករោតិ វា

តតោ នំ ទុក្ខមន្វេតិ ចក្កំវ វហតោ បទំ ។

មនោបុព្ពង្គមា ធម្មា មនោសេដ្ឋា មនោមយោ

មនសា ចេ បសន្នេន ភាសតិ វា ករោតិ វា

តតោ នំ សុខមន្វេតិ ឆាយោវ អនុបាយិនី ។

អក្កោច្ឆិ មំ អវធិ មំ អជិនិ(๑)មំ អហាសិ មេ

យេ ច(๒) តំ ឧបនយ្ហន្តិ វេរំ តេសំ ន សម្មតិ ។

អក្កោច្ឆិ មំ អវធិ មំ អជិនិ មំ អហាសិ មេ

---

๑ ម. អនីនំ ។ ๒ ម. បសព្ភ វត្តុំ ។

សុត្តន្តបិដក

ខុទ្ទកនិកាយ ធម្មបទគាថា

សូមនមស្ការព្រះមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ព្រះអង្គនោះ ។

(១១) *ធម្មទាំងឡាយ មានចិត្តជាប្រធាន មានចិត្តប្រសើរបំផុត (មានចិត្តជាធំ) សម្រេចអំពីចិត្ត បើបុគ្គលមានចិត្តត្រូវទោស[1] ប្រទូស្តហើយ ពោលក្តី ធ្វើក្តី (នូវទុច្ចរិត) ព្រោះទុច្ចរិតទាំងនោះ ទុក្ខ រមែងជាប់តាមបុគ្គលនោះទៅ ដូចកង់រទេះរំលងតាមជានដើងគោដែលកំពុងអូសទៅ ។*

ធម្មទាំងឡាយ មានចិត្តជាប្រធាន មានចិត្តប្រសើរបំផុត សម្រេចអំពីចិត្ត បើបុគ្គលមានចិត្តជ្រះថ្លា[2]ហើយ ពោលក្តី ធ្វើក្តី (នូវសុចរិត) ព្រោះសុចរិតទាំងនោះ សុខរមែងជាប់តាមបុគ្គលនោះទៅ ដូចស្រមោលអន្ទោលតាមប្រាណ ។

អ្នកឯណោះ បានដេរអញ អ្នកឯណោះ បានវាយអញ អ្នកឯណោះ បានផ្តាញ់អញ អ្នកឯណោះ បានលួចយកទ្រព្យរបស់អញទៅហើយ បើអ្នកណា ចងសេចក្តីក្រោធបែបនោះទុក (ដូច្នេះ) ពៀររបស់អ្នកនោះ មិនរម្ងាប់ឡើយ ។

អ្នកឯណោះ បានដេរអញ អ្នកឯណោះ បានវាយអញ អ្នកឯណោះ បានផ្តាញ់អញ អ្នកឯណោះ បានលួចយកទ្រព្យរបស់អញទៅហើយ

---

[1] ធម្មទាំងពោលឬធ្វើនូវបក្តីសេសនៃចិត្តមានអកុសលជាដើម នៃសត្វលួសមកធ្វើចិត្តឲ្យក្រៀវ ។

[2] ត្រេះថ្លាដោយគុណមានអនភិជ្ឈាជាដើម ។ អដ្ឋកថា ។

យេ ច តំ ឧបនយ្ហន្តិ[1] វេរំ តេសូបសម្មតិ ។

ន ហិ វេរេន វេរានិ សម្មន្តីធ កុទាចនំ

អវេរេន ច សម្មន្តិ ឯស ធម្មោ សនន្តនោ ។

បរេ ច ន[2] វិជានន្តិ មយមេត្ថ យមាមសេ[3]

យេ ច តត្ថ វិជានន្តិ តតោ សម្មន្តិ មេធគា ។

សុភានុបស្សឺ វិហរន្តំ ឥន្ទ្រិយេសុ អសំវុតំ

ភោជនម្ហិ អមត្តញ្ញុំ កុសីតំ ហីនវីរិយំ

តំ វេ បសហតី មារោ វាតោ រុក្ខំវ ទុព្ពលំ ។

អសុភានុបស្សឺ វិហរន្តំ ឥន្ទ្រិយេសុ សុសំវុតំ

ភោជនម្ហិ ច មត្តញ្ញុំ សទ្ធំ អារទ្ធវីរិយំ

តំ វេ នប្បសហតី[4] មារោ វាតោ សេលំវ បព្ពតំ ។

---

๑ ឧ.ម ឧបនយ្ហន្តិ ។ ๒ ម, ឧ ច ។ ๓ ឧ. ម. យមាមសេ ។ ๔ ម. ឧ បសហតិ ។

បើអ្នកណា មិនចង់សេចក្តីក្រោធបែបនោះទុក (ដូច្នេះ)ពៀរបស់អ្នក
នោះទើបរម្ងាប់ឃាន ។ ពិតមែន តាំងពីកាលណាមក ក្នុងលោកនេះ
ពៀរតាំងឡាយ មិនរម្ងាប់ ដោយពៀរទេឡើយ ពៀរតាំងឡាយតែង
រម្ងាប់ ដោយមិនមានពៀរ នេះជាបវេណីធម៌ ។ ជនតាំងឡាយ
ដទៃ (ក្រៅអំពីបណ្ឌិត) តែងមិនដឹងខ្លួនថា យើងតាំងឡាយនឹង
វិនាសក្នុងកណ្តាលនៃពួកនេះ ដូច្នេះឡើយ ចំណែកជនតាំងឡាយ
ណា ក្នុងពួកនេះ ដឹងខ្លួនថា យើងតាំងឡាយ នឹងវិនាសក្នុង
កណ្តាលនៃពួកនេះ ដូច្នេះ ការឈ្លោះប្រកែកតាំងឡាយ រមែងរម្ងាប់
អំពីជនតាំងឡាយនោះ ។

បុគ្គលដែលយល់ឃើញនូវអារម្មណ៍ថាល្អ មិនសង្រួមក្នុងឥន្ទ្រិយតាំង
ឡាយ មិនដឹងប្រមាណក្នុងកោជន ខ្ជិលច្រអូស មានព្យាយាមផ្សុះ
ផ្សាយ កិលេសមារ រមែងគ្របសង្កត់បុគ្គលនោះឯង ដូចខ្យល់ដែល
គ្របសង្កត់ដើមឈើទន់ខ្សោយដូច្នោះ ។ ឯបុគ្គល ដែលយល់ឃើញ
នូវអារម្មណ៍ថាមិនល្អ សង្រួមប្រពៃក្នុងឥន្ទ្រិយតាំងឡាយ ដឹងប្រមាណ
ក្នុងកោជន មានសទ្ធា ប្រារព្ធព្យាយាម កិលេសមារតែងគ្របសង្កត់
បុគ្គលនោះមិនបាន ដូចខ្យល់គ្របសង្កត់ភ្នំថ្មតាន់មិនបានដូច្នោះ ។

ធម្មបទគាថាយ បឋមោ យមកវគ្គោ

អនិក្កសាវោ កាសាវំ យោ វន្តំ បរិទហេស្សតិ

អបេតោ ទមសច្ចេន ន សោ កាសាវមរហតិ ។

យោ ច វន្តកសាវស្ស សីលេសុ សុសមាហិតោ

ឧបេតោ ទមសច្ចេន ស វេ កាសាវមរហតិ ។

អសារេ សារមតិនោ សារេ ចាសារទស្សិនោ

តេ សារំ នាធិគច្ឆន្តិ មិច្ឆាសង្កប្បគោចរា ។

សារញ្ច សារតោ ញត្វា អសារញ្ច អសារតោ

តេ សារំ អធិគច្ឆន្តិ សម្មាសង្កប្បគោចរា ។

យថា អគារំ ទុច្ឆន្នំ វុដ្ឋី(១)សមតិវិជ្ឈតិ

ឯវំ អភាវិតំ ចិត្តំ រាគោ សមតិវិជ្ឈតិ ។

---

๑ ទ.វុដ្ឋិ ។

ធម្មបទគាថា យមកវគ្គ ទី ១

អ្នកណា នៅមានទឹកចិត្តគឺកិលេស (កិលេសន្ធាន) ជាអ្នកចុះបង់គារៈខ្ជួនខ្ជាន នូវឥន្ទ្រិយទាំងឥសិប: ហើយស្លៀកដណ្តប់សំពត់កាសាវៈ អ្នកនោះមិនគួរនឹងស្លៀកដណ្តប់សំពត់កាសាវៈទេ ។ លុះតែអ្នកណា មានទឹកចិត្តគឺកិលេស ខ្ចាក់ចោលអស់ហើយ ជាអ្នកមានចិត្តដម្កល់មាំ ក្នុងចតុប្បារិសុទ្ធិសីល ប្រកបដោយគារៈខ្ជួនខ្ជាន នូវឥន្ទ្រិយទាំងឥសិប: អ្នកនោះឯង ទើបគួរនឹងស្លៀកដណ្តប់សំពត់កាសាវៈបាន ។

ជនពាលខ្លាយ ដែលយល់ឃើញ ក្នុងធម៌មានទ្វឹម ថាជាធម៌មិនមានទ្វឹមផង ជាអ្នកមានតម្រិះខុសជាអារម្មណ៍ រមែងមិនបាននូវធម៌ដែលមានទ្វឹមទេ ។ ជនពាលខ្លាយ ដែលយល់ឃើញ នូវធម៌មានទ្វឹម ថាជាធម៌មានទ្វឹមផង យល់ឃើញ នូវធម៌គ្មានទ្វឹម ថាជាធម៌គ្មានទ្វឹមផង ជាអ្នកមានតម្រិះត្រូវ ជាអារម្មណ៍ រមែងបាននូវធម៌ដែលមានទ្វឹម ។

ផ្លូវដែលប្រកបដោយហើយ ដំណាក់កើតក្តៅ រមែងលេចរហូតយ៉ាងណាមិញ ចិត្តដែលបុគ្គលមិនបានអប់រំទុកហើយ រាគៈរមែងចាក់ផ្សាតយ៉ាងនោះឯង ។

យថា អគារំ សុឆន្នំ វុដ្ឋី ន សមតិវិជ្ឈតិ

ឯវំ សុភាវិតំ ចិត្តំ រាគោ ន សមតិវិជ្ឈតិ ។

៩ឆ សោចតិ បេច្ច សោចតិ ធាបការី ឧភយត្ថ សោចតិ

សោ សោចតិ សោ វិហញ្ញតិ ទិស្វា កម្មកិលិដ្ឋមត្តនោ ។

៩ឆ មោទតិ បេច្ច មោទតិ កតបុញ្ញោ ឧភយត្ថ មោទតិ

សោ មោទតិ សោ បមោទតិ ទិស្វា កម្មវិសុទ្ធិមត្តនោ ។

៩ឆ តប្បតិ បេច្ច តប្បតិ ធាបការី ឧភយត្ថ តប្បតិ

ធាបំ មេ កតន្តិ តប្បតិ កិយ្យា តប្បតិ ទុគ្គតឹ គតោ ។

៩ឆ នន្ទតិ បេច្ច នន្ទតិ កតបុញ្ញោ ឧភយត្ថ នន្ទតិ

បុញ្ញំ មេ កតន្តិ នន្ទតិ កិយ្យា នន្ទតិ សុគតឹ គតោ ។

ផ្តុំដែលប្រាសហើយ ដំណាក់ទឹកក្តៅ រមែងមិនលេចរហូត យ៉ាងណាមិញ បិត្តដែលបុគ្គលបានរម្ងាប់ទុកល្អហើយ ពាក្យរមែងមិនចាក់ជោតបាន យ៉ាងនោះឯង ។ បុគ្គលអ្នកធ្វើបាប តែងសោកស្តាយក្នុងលោកទាំងពីរ គឺសោកស្តាយ ក្នុងលោកនេះ ១ ក្នុងលោកខាងមុខ ១ បុគ្គលនោះ រមែងសោកស្តាយ ក្តៅក្រហាយ ព្រោះឃើញអំពើសៅហ្មងរបស់ខ្លួន ។

បុគ្គលអ្នកធ្វើបុណ្យទុក រមែងរីករាយ ក្នុងលោកទាំងពីរ គឺរីករាយក្នុងលោកនេះ ១ រីករាយក្នុងលោកខាងមុខ ១ បុគ្គលនោះ រមែងរីករាយស្រស់ស្រាយ ព្រោះឃើញអំពើបរិសុទ្ធរបស់ខ្លួន ។ បុគ្គលអ្នកធ្វើអំពើបាប តែងក្តៅក្រហាយ ក្នុងលោកទាំងពីរ គឺក្តៅក្រហាយក្នុងលោកនេះ ១ ក្តៅក្រហាយក្នុងលោកខាងមុខ ១ បុគ្គលនោះ រមែងក្តៅក្រហាយដោយគិតឃើញថា បាបអញបានធ្វើហើយ លុះធ្វើមរណកាលទៅកាន់ទុគ្គតិ ក៏ឆ្ងាយតែក្តៅក្រហាយដ៏ក្រៃលែង ។

បុគ្គលអ្នកធ្វើបុណ្យទុក រមែងត្រេកអរ ក្នុងលោកទាំងពីរគឺត្រេកអរក្នុងលោកនេះ ១ ត្រេកអរក្នុងលោកខាងមុខ ១ បុគ្គលនោះរមែងត្រេកអរដោយគិតឃើញថា បុណ្យអញបានធ្វើហើយ លុះធ្វើមរណកាលទៅកាន់សុគតិ ក៏ឆ្ងាយតែត្រេកអរដ៏ក្រៃលែង ។

ពហុម្បិ ចេ សហិតំ ភាសមានោ
ន តក្ករោ ហោតិ នរោ បមត្តោ
គោឝោវ តាវ ឝ្ឝតិ ឝលាយំ បរេសំ
ន ភាគវា សាមញ្ញស្ស ហោតិ ។

អប្បម្បិ ចេ សហិតំ ភាសមានោ
ធម្មស្ស ហោតិ អនុធម្មចារី
រាគញ្ច ទោសញ្ច បហាយ មោហំ
សម្មប្បជានោ សុវិមុត្តចិត្តោ
អនុបាទិយានោ ឥធ វា ហុរំ វា
ស ភាគវា សាមញ្ញស្ស ហោតិ ។

យមកវគ្គោ បឋមោ ។

ធម្មបទគាថាយ ទុតិយោ អប្បមាទវគ្គោ

[๑๒] អប្បមាទោ អមតំបទំ បមាទោ មច្ចុនោ បទំ
អប្បមត្តា ន មីយន្តិ យេ បមត្តា យថា មតា
ឯតំ[๑] វិសេសតោ ញត្វា អប្បមាទម្ហិ បណ្ឌិតា

๑ ប. ឯវំ ។

បើនរជននោះ ពោលពាក្យប្រកបដោយប្រយោជន៍សូម្បីច្រើន តែជាអ្នកប្រមាទ មិនធ្វើតាមពាក្យនោះ រមែងជាអ្នកមិនមានបំណែកសាមញ្ញផលឡើយ ដូចអ្នករក្សាគោ កាលរាប់គោប្រគល់ឲ្យអ្នកដទៃហើយ (ជាអ្នកមិនបានបរិភោគនូវបញ្ចគោរស) ដូច្នោះឯង ។ បើនរជននោះ ពោលពាក្យប្រកបដោយប្រយោជន៍សូម្បីបន្តិចបន្តួច តែជាអ្នកប្រព្រឹត្តនូវធម៌ មិនសមគួរដល់ធម៌ បានលះបង់រាគៈ ទោសៈ នឹងមោហៈ ជាអ្នកដឹងនូវធម៌ ដែលគួរតំណាត់តាមហេតុ មានចិត្តដកផុតអំពីសេចក្តីសៅហ្មង មិនមានសេចក្តីប្រកាន់មាំ ក្នុងលោកនេះនឹងលោកខាងមុខ នរជននោះ រមែងជាអ្នកបានបំណែកសាមញ្ញផល ។

ចប់ យមកវគ្គ ទី១ ។

ធម្មបទគាថា អប្បមាទវគ្គទី២

(๒๑) សេចក្តីមិនប្រមាទ[๑] ជាផ្លូវនៃសេចក្តីមិនស្លាប់[๒] សេចក្តីប្រមាទជាផ្លូវនៃសេចក្តីស្លាប់ ជនទាំងឡាយ ដែលមិនប្រមាទហើយ[๓] ឈ្មោះថា មិនស្លាប់ ជនទាំងឡាយ ដែលប្រមាទហើយ ទុកដូចជាមនុស្សស្លាប់ទៅហើយ ។ ពួកបណ្ឌិត បានត្រាស់នូវដំណើរនេះ ដោយប៉ុណ្ណេះ (ទើបបានទៅ) ក្នុងសេចក្តីមិនប្រមាទ

---

๑ ជាឧដ្ឋលក្ខណប្រែយ៉ាត្ថ ពាក្យនេះជាឈ្មោះស្មារតី ដែលជាតាំងប្រុងដោយច្បាស់ ។
๒ ពាក្យថា មិនស្លាប់នេះ ជាឈ្មោះព្រះនិព្វាន ព្រោះព្រះនិព្វានរមែងមានភាពជាមិនស្លាប់ ។
๓ ជាឧដ្ឋលក្ខណប្រែយ៉ាត្ថ ពាក្យនេះជាឈ្មោះនៃការលះបង់ស្មារតី ។

អប្បមាទេ បមោទន្តិ អរិយានំ គោចរេ រតា

តេ ឈាយិនោ សាតតិកា និច្চំ ទឬ្ហបរក្កមា

ផុសន្តិ ធីរា និព្ពានំ យោគក្ខេមំ អនុត្តរំ ។

ទិដ្ឋានុគោ សតីមតោ សុចិកម្មស្ស និសម្មការិនោ

(១)

សញ្ញតស្ស ច ធម្មជីវិនោ អប្បមត្តស្ស យសោភិវឌ្ឍតិ ។

ទិដ្ឋានេនប្បមាទេន សញ្ញមេន[២]ទមេន ច[៣]

ទីបំ កយិរាថ មេធាវី យំ ឱឃោ នាភិកីរតិ ។

បមាទមនុយុញ្ជន្តិ ពាលា ទុម្មេធិនោ ជនា

អប្បមាទញ្ច មេធាវី ធនំ សេដ្ឋំវ រក្ខតិ ។

មា បមាទមនុយុញ្ជេថ មា កាមរតិសន្ថវំ

អប្បមត្តោ ហិ ឈាយន្តោ បប្បោតិ វិបុលំ សុខំ ។

---

๑ ម. បសាទោ ទត្តំ ។ ๒ ប. សំយមេន ។ ๓ ទ. ភ ។

រីឯកាយ ក្នុងសេចក្តីមិនប្រមាទ បណ្ឌិតទាំងនោះ ជាអ្នកត្រេកអរ ក្នុងធម៌ជាគោចរ[1] នៃអរិយបុគ្គលទាំងឡាយ មានការពិនិត្យ ជាប្រក្រតី មានឫយាមជាប់តគ្នា មានសេចក្តីប្រឹងប្រែងមាំមួនជានិច្ច ជាអ្នកមានប្រាជ្ញា តែងប៉ះពាល់នូវព្រះនិព្វានជាទីក្សេមក្សាន្តចាកយោគៈ ជាគុណជាតដ៏ប្រសើរបំផុត ។ យស[2] តែងចំរើនកុះករ ដល់បុគ្គលអ្នកមានសេចក្តីប្រឹងប្រែង មានស្មារតី មានការងារស្អាត (ឥតទោស) ជាអ្នកពិចារណា រួចហើយទើបធ្វើ ជាអ្នកសង្រួម រស់នៅដោយធម៌ មិនមានសេចក្តីប្រមាទ។ អ្នកប្រាជ្ញ គប្បីសាងគោះ គឺអរហត្តផល ជាគោះដែលដំនន់គឺកិលេសដ៏ទន្ទឹងមិនបាន ដោយសេចក្តីប្រឹងប្រែងផង ដោយសេចក្តីមិនប្រមាទផង ដោយការសង្រួមក្នុងចតុប្បារិសុទ្ធិសីលផង ដោយការទូន្មានឥន្ទ្រិយផង ។ ពួកជនពាលអប្បឥតប្រាជ្ញា តែងប្រកបរឿយ ។ នូវសេចក្តីប្រមាទ ចំណែកអ្នកប្រាជ្ញ រមែងរក្សាទុកនូវសេចក្តីមិនប្រមាទ ដូចគ្រឿងយ៉ាងប្រសើរ ។ អ្នកចាំងឡាយ ចូរកុំប្រកបរឿយ។ នូវសេចក្តីប្រមាទ ចូរកុំប្រកបរឿយ ។ នូវសេចក្តីកាយ ត្រេកអរក្នុងកាមឡើយ ដ្បិតបុគ្គលអ្នកមិនប្រមាទ ទំសឆ្អែតពិនិត្យ រមែងបានសេចក្តីសុខដ៏ធូលាយ ។

---

๑ ភោគិបក្ខំយធម្មា៣៧ទាំងឡាយក្នុងពោធិបក្ខិយធម៌៧ហៅថា គោចរនៃអរិយៈ ។ ๒ ភាវដ៏ធំ, ភោគសម្បត្តិ, សេចក្តីភាប់អាន, កិត្តិសព្ទដ៏ពីរោះ គុណទាំងនេះរួមហៅថា យស ។

ធម្មបទគាថាយ ទុតិយោ អប្បមាទវគ្គោ

បមាទំ អប្បមាទេន យទា[1] នុទតិ បណ្ឌិតោ

បញ្ញាបាសាទមារុយ្ហ អសោកោ សោកិនិំ បជំ

បព្ពតដ្ឋោវ ភុម្មដ្ឋេ ធីរោ ពាលេ អវេក្ខតិ ។

អប្បមត្តោ បមត្តេសុ សុត្តេសុ ពហុជាគរោ

អពលស្សំវ សីឃស្សោ ហិត្វា យាតិ សុមេធសោ ។

អប្បមាទេន មឃវា ទេវានំ សេដ្ឋតំ គតោ

អប្បមាទំ បសំសន្តិ បមាទោ គរហិតោ សទា ។

អប្បមាទរតោ ភិក្ខុ បមាទេ ភយទស្សិ វា

សញ្ញោជនំ អណុំ ថូលំ ឌហំ អគ្គីវ គច្ឆតិ ។

---

๑ ម. នុទតិ ។

ធម្មបទគាថា អប្បមាទវគ្គ ទី២

តាលណា បណ្ឌិត បន្ទោបង់នូវសេចក្តីប្រមាទ ដោយសេចក្តីមិនប្រមាទ តាលណោះ លោកនឹងឡើងគាន់ប្រាសាទគឺបញ្ញាជាបុគ្គលមិនសោក រមែងឃើញពួកសត្វដែលមានសោក ដរាជនតែងឃើញពួកជនពាល ដូចបុគ្គលដែលឈរលើកំពូលភ្នំ ហើយក្រឡេកមើលពួកជនដែលឋិតនៅលើផែនដី ដូច្នោះឯង ។

បណ្ឌិតមានប្រាជ្ញាមុះមុត តាលពួកបុគ្គលកំពុងប្រមាទ លោកមិនប្រមាទ តាលពួកបុគ្គលកំពុងដេកលក់ លោកភ្ញាក់ឮកច្រើន លោករមែងលះបង់ចោលនូវបុគ្គលបែបនោះ ដូចសេះលឿន ដែលទៅចោលនូវសេះ មានកំឡាំងទន់ខាប ដូច្នោះឯង ។

មឃមានព ដល់នូវភាពជាបុគ្គលប្រសើរបំផុត ជាធំទៅតាំងឡាយ ព្រោះតែសេចក្តីមិនប្រមាទ អ្នកប្រាជ្ញតាំងឡាយ តែងសរសើរនូវសេចក្តីមិនប្រមាទ តួនតិះដៀលនូវសេចក្តីប្រមាទ សព្វៗកាល ។

តិក្ខិអ្នកត្រែតអរ ក្នុងសេចក្តីមិនប្រមាទ ឬរើញភ័យ ក្នុងសេចក្តីប្រមាទ តែងដុតចោលសំយោជនៈ តាំងតូច តាំងធំ ដូចភ្លើងឆេះ (កាលនូវតំណេចតាំងតូចតាំងធំ) ដូច្នោះឯង ។

អប្បមាទរតោ ភិក្ខុ បមាទេ ភយទស្សិ វា

អភព្វោ បរិហានាយ និព្ពានស្សេវ សន្តិកេ ។

អប្បមាទវគ្គោ ទុតិយោ ។

ធម្មបទគាថាយ តតិយោ បិត្តវគ្គោ

[๑๗] ផន្ទនំ ចបលំ ចិត្តំ ទុរក្ខំ ទុន្និវារយំ

ទុជ្ជុំ ករោតិ មេធាវី ទុសុការោវ[๑] តេជនំ ។

ឯវំជវោ ផលេ ចិត្តោ យទិកាមោ តទុដ្ឋគោ

បរិផន្ទកិតំ ចិត្តំ មារធេយ្យំ បហាតវេ ។

ទុន្និក្ខមាសុ លហុនោ យត្ថ កាមនិបាតិនោ

ចិត្តស្សុ ទមថោ សាធុ ចិត្តំ ទន្តំ សុខាវហំ ។

๑ ម. ឧសុការោវ ។

ភិក្ខុអ្នកត្រេកអរ ក្នុងសេចក្តីមិនប្រមាទ ឃើញភ័យ ក្នុងសេចក្តីប្រមាទ ជាអ្នកមិនគួរនឹងសាបសូន្យចាកគុណធម៌ ឈ្មោះថា ឋិត នៅក្នុងទីជិតនៃព្រះនិព្វាន ។

ចប់ អប្បមាទវគ្គ ទី ២ ។

ធម្មបទគាថា បិត្តវគ្គ ទី ៣

[១៣] អ្នកប្រាជ្ញ តែងធ្វើចិត្តដែលញាប់ញ័រ ឃ្លេងឃ្លាង រក្សាបាន ដោយកម្រ ហាមឃាត់បានដោយលំបាក ឲ្យជាចិត្តត្រង់បាន ដូចអ្នក ធ្វើព្រួញ ពត់ព្រួញឲ្យត្រង់ ។ ចិត្តនេះដែលបុគ្គលលើកឡើងចាក អាលយ័គឺតាមគុណ ៥ ចោះទៅក្នុងវិបស្សនាកម្មដ្ឋាន ដើម្បីលះបង់ នូវវដ្តៈជាទីទៅនៃមារ រមែងញាប់ញ័រ ដូចត្រីដែលគេលើកឡើង ចាកទីទៅគឺទឹក ចោះទៅលើគោក ដូច្នោះឯង ។

តារក្ខន្ទានចិត្ត ដែលសង្កត់សង្កិន បានដោយលំបាក ជាធម្មជាត រហ័ស មានប្រក្រតីធ្លាក់ចុះទៅតាមសេចក្តីប្រាថ្នា ក្នុងអារម្មណ៍ណា មួយ រមែងជាគុណញុំាងប្រយោជន៍ឲ្យសម្រេច (ព្រោះថា) ចិត្ត ដែលហ្វឹកហ្វឺនបានហើយ រមែងនាំមកនូវសេចក្តីសុខ ។

ធម្មបទគាថាយ តតិយោ ចិត្តវគ្គោ

សុទុទ្ទសំ សុនិបុណំ យត្ថ កាមនិវាតិនំ
ចិត្តំ រក្ខេថ មេធាវី ចិត្តំ គុត្តំ សុខាវហំ ។
ទូរង្គមំ ឯកចរំ[1] អសរីរំ គុហាសយំ
យេ ចិត្តំ សញ្ញមេស្សន្តិ មោក្ខន្តិ មារពន្ធនា ។
អនវដ្ឋិតចិត្តស្ស សទ្ធម្មំ អវិជានតោ
បរិប្លវបសាទស្ស បញ្ញា ន បរិបូរតិ ។
អនវស្សុតចិត្តស្ស អនន្វាហតចេតសោ
បុញ្ញបាបប្បហីនស្ស នត្ថិ ជាគរតោ ភយំ ។
កុម្ភូបមំ កាយមិមំ វិទិត្វា
នគរូបមំ ចិត្តមិទំ ឋបេត្វា
យោធេថ មារំ បញ្ញាវុធេន
ជិតញ្ច រក្ខេ អនិវេសនោ សិយា ។

---

๑ ម ឯកចរំ ។

អ្នកមានប្រាជ្ញា គួរការក្សាចិត្តដែលឃើញដោយកម្រៃត្រៃពេក ដែលល្អិតពេកណាស់ មានប្រក្រតីធ្លាក់ចុះទៅតាមសេចក្តីប្រាថ្នា ក្នុងអារម្មណ៍ណាមួយ (ព្រោះថា) ចិត្តដែលគេការក្សាបានហើយ រមែងនាំមកនូវសេចក្តីសុខ ។

អ្នកតាំងធ្លាយណា នឹងសង្រួមចិត្តដែលទៅធ្លាយ ជាចិត្តគ្រាប់ទៅតែឯង មិនមានសត្រូវ: មានគូហាគឺមហាភូតរូប ៤ ជាទីអាស្រ័យនៅ អ្នកតាំងនោះឯង រមែងរួចចាកចំណងនៃមារ ។

ប្រាជ្ញា រមែងមិនបរិបូណ៌ដល់បុគ្គលដែលមានចិត្តមិនខ្ជាប់ខ្ជួន មិនដឹងច្បាស់នូវព្រះសទ្ធម្ម មានសេចក្តីជ្រះថ្លាអណ្តែតទៅ ។ ភ័យរមែងមិនមាន ដល់បុគ្គលអ្នកមានចិត្តមិនទន្ទឹកដោយរាគៈ: មានចិត្តដែលទោសៈទាំងឡាប់មិនបាន មានបុណ្យនឹងបាបលះចោលហើយភ្ញាក់រឭកជានិច្ច ។ បុគ្គលគប្បីដឹងច្បាស់នូវកាយនេះថា ដូចជាផ្ទាំង គប្បីបំផ្លាញនូវចិត្តនេះឲ្យដូចជាបុរេចារនគរ គប្បីចម្បាំងនូវមារដោយអាវុធ គឺបញ្ញា គប្បីរក្សាទុកនូវធម៌ ដែលខ្លួនឈ្នះហើយ មិនគប្បីជាអ្នកដំអក់នៅ (ក្នុងធម៌នោះ) ឡើយ ។

អបិនំ វតយំ តាយេរ បឋវឹ អធិសេស្សតិ

ឆុទ្ធោ អបេតវិញ្ញាណោ និរត្ថំវ តាលវន្ថុំ ។

និសោ និសំ យន្តំ តាយិរ វេរ ភ បន វេរិនំ

មិច្ឆាបណិហិតំ ចិត្តំ អាមិយោ នំ តតោ តាវ ។

ន តំ មាតា បិតា តាយិរ អញ្ញេ ភបិច ញាតកា

សម្មាបណិហិតំ ចិត្តំ សេយ្យសោ នំ តតោ តាវ ។

ចិត្តវគ្គោ តតិយោ ។

ធម្មបទគាថាយ បតុគ្គោ ប្បវគ្គោ

[๑๔] តោ ๔មំ បឋវឹ វិជេស្សតិ យមលោកញ្ច ๔មំ សទេវកំ

(๑)

តោ ធម្មបទំ សុទេសិតំ កុសលោ បុប្ផមិវ បចេស្សតិ ។

---

๑ ម. បុប្ផមិវប្បចេស្សតិ ។

ឧបាសក មិនយូរប៉ុន្មានទេតើ កាយនេះ មានវិញ្ញាណទៅប្រាស គេយកទៅចោលផុតហើយ មុខដ៏ឆើតស្អាតស្តឹងលើផែនដី ដូចជាអង្កត់ទស រកប្រយោជន៍គ្មាន ។

ចោរក្រឡេកឃើញចោរផងគ្នា ឬក៏ បុគ្គលមានពៀរ ក្រឡេកឃើញបុគ្គលមានពៀរផងគ្នា គប្បីធ្វើនូវសេចក្តីវិនាសណាមួយ ដល់គ្នាចិត្តដែលបុគ្គលតាំងទុកខុសហើយ រមែងធ្វើបុគ្គលនោះ ឲ្យអាក្រក់ក្រៃលែងជាងសេចក្តីវិនាសនោះទៅទៀត ។

មាតាបិតា មិនគប្បីធ្វើហេតុនោះបាន ឬជនទាំងឡាយដទៃជាញាតិមិនគប្បីធ្វើនូវហេតុនោះបាន ចំណែកខាងចិត្ត ដែលបុគ្គលតាំងទុកត្រូវហើយ រមែងធ្វើបុគ្គលនោះ ឲ្យប្រសើរជាងហេតុនោះបាន ។

ចប់ ចិត្តវគ្គទី៣ ។

ធម្មបទគាថា បុប្ផវគ្គទី៤

(១៤)អ្នកណាទំដំធ្វើចង្ក្រានូវផែនដីនេះ ទឹមយមលោកគឺអាយកូមិ ៤ ទឹមមនុស្សលោកនេះព្រមទាំងទេវលោកបាន អ្នកណាទំធ្វើសរសៃនូវចំណែកនៃធម៌ ដែលព្រះតថាគត សំដែងប្រពៃហើយ ដូចជាលោការដែលឈ្មោះសៃ ធ្វើសរសៃនូវផ្កាដូច្នោះឯង ។

សេយ្យថាបិ បុប្ផរាសិម្ហា យោ យោ លភតិ ឧត្តរិ ។ ឯវំ សត្តេសុ កតានិ
សេយ្យថាបិ ឧប្ផលបទុមនាឡាទីសុ យំ យំ បុប្ផំ លភតិ ឧត្តរិ ឧបរិ ពហុតរំ
ឯវមេវំ តាយ ទេសិតំ ធម្មំ
អវិជានន្តា អតិសយ្ហនាយ
ឆន្ទាទយោ បាទេសុ បមុញ្ចតោ(១)
អនេស្សនំ អទ្ទក្ខាតិ ឯវមត្ថោ ។
បុប្ផានិ ហេវ បចិនន្តំ(២) ព្យាសត្តមនសំ(៣) នរំ
សុត្តំ គាមំ មហោឃោវ មច្ចុ អាគម្ម តិដ្ឋតិ ។
បុប្ផានិ ហេវ បចិនន្តំ ព្យាសត្តមនសំ នរំ
អតិត្តំយេវ កាមេសុ អន្តកោ កុរុតេ វសំ ។
យថាបិ ភមរោ បុប្ផំ វណ្ណគន្ធំ អហេឋយំ(៤)
បលេតិ រសមាទាយ ឯវំ គាមេ មុនី ចរេ ។

---

๑ ម. សព្ពកាមំ ។ ๒ ម. បចិនន្តំ ។ ๓ ម. ព្យាសត្តមានសំ ។
๔ ម. វណ្ណគន្ធមហេឋយំ ។

ធម្មបទគាថា ឃុប្ផវគ្គទី ៤

ព្រះសេក្ខបុគ្គល នឹងដឹងច្បាស់នូវផែនដីគឺអត្តភាពនេះ នឹងយមលោកគឺអបាយភូមិ ៤ នឹងមនុស្សលោកនេះព្រមទាំងទេវលោកបាន ព្រះសេក្ខបុគ្គល នឹងជ្រើសរើសនូវចំណែកនៃធម៌ ដែលព្រះតថាគតសំដែងប្រៀបហើយ ដូចមាលាការ ដែលឈ្មោះវៃ ជ្រើសរើសនូវផ្កាដូច្នោះ ។

ភិក្ខុ កាលដឹងច្បាស់នូវកាយនេះថា ដូចជាដុំពពុះទឹក ដឹងច្បាស់នូវកាយនេះថា មានសភាពដូចព្រេញថ្ងៃ គប្បីកាត់នូវផ្កាដាប្រធាននៃមារគឺវដ្ដៈ ៣ ទៅកាន់ស្ថានដាច់មិនឃើញនៃមច្ចុរាជ ។

មច្ចុគឺសេចក្ដីស្លាប់ តែងកៀរយកទៅនូវជនអ្នកមានចិត្តជាប់ដំពាក់ក្នុងអារម្មណ៍ផ្សេង ។ តំពូនជ្រើសរើសនូវផ្កា គឺតាមគុណ ៥ នុ៎ះឯង ដូចទឹកដ៏ន្លង់ធំ ដែលកួចយកអ្នកស្រុកតំពូនដេកលក់ទៅ ដូច្នោះឯង ។

អ្នកធ្វើទីបំផុតគឺមរណៈ តែងក្រេងសត្វ ដែលមានចិត្តជាប់ដំពាក់ក្នុងអារម្មណ៍ផ្សេង ។ តំពូនជ្រើសរើសនូវផ្កា គឺតាមគុណ ៥ មិនឆ្អែតឆ្អន់ក្នុងកាមទាំងឡាយនុ៎ះឯង ឲ្យនៅក្នុងអំណាចរបស់ខ្លួន ។

ភមរជាតិ មិនធ្វើផ្លាស់ដែលមានពណ៌និងក្លិនឲ្យរិនាសទេ ត្រេបយកតែរស ហើរទៅ យ៉ាងណាមិញ អ្នកប្រាជ្ញ គប្បីត្រាច់ទៅក្នុងស្រុក ក៏យ៉ាងនោះឯង ។

ฉ ปเวสึ วิโลภาหิ ฉ ปเวสึ ตณฺหาตณฺหาหิ

อฏฺฐโต ว อเวโจฺจยฺย ตาหิ อตาหิ จ ฯ

ยถาปิ รุจิรํ ปุปฺผ วณฺณวนฺตํ อคนฺธกํ

ฬวํ สุภาสิตา วาจา อผลา โหติ อกุพฺพโต ฯ

ยถาปิ รุจิรํ ปุปฺผ วณฺณวนฺตํ สคนฺธกํ[๑]

ฬวํ สุภาสิตา วาจา สผลา โหติ สุกุพฺพโต ฯ

ยถาปิ ปุปฺผราสิมฺหา กยิรา มาลาคุเณ พหู

ฬวํ ชาเตน มจฺเจน กตฺตพฺพ กุสล พหุ ฯ

ฉ ปุปฺผคนฺโธ ปฏิวาตเมติ

ฉ จนฺทนํ ตครมลฺลิกา[๒] วา

---

๑ ม. สุคนฺธก ฯ ๒ ฉ. ตคร มลฺลิก ฯ

ពាក្យចាត់ជោគជាំធំធ្ងាយរបស់ជនដទៃ បុគ្គលមិនគួរធ្វើទុកក្នុងចិត្ត
ទេ កិច្ចដែលធ្វើហើយនឹងមិនទាន់ធ្វើហើយរបស់ជនដទៃ (ដែលមិន
មែនជាមុខការរបស់ខ្លួន) បុគ្គលមិនគួរពិនិត្យមើលទេ បុគ្គលគួរ
ពិនិត្យពិចារណា តែកិច្ចការជាំធំធ្ងាយ ដែលធ្វើហើយ នឹងមិនទាន់
ធ្វើហើយ របស់ខ្លួនតែម្យ៉ាង ។

ផ្កាឈើមានទ្រនំទ្រាយល្អ មានពណ៌ (ល្អ) តែគ្មានក្លិន (ក្រអូប)
(រមែងមិនក្រអូបដល់អ្នកដែលទ្រទ្រង់) ដូចម្តេចមិញ ភាសិតនេះ
សុភាសិត រមែងគ្មានផលដល់អ្នកដែលមិនធ្វើតាមដូច្នោះ ផ្កាឈើ
ដែលមានទ្រនំទ្រាយល្អ មានពណ៌ មានក្លិន (រមែងក្រអូបដល់អ្នក
ដែលទ្រទ្រង់) ដូចម្តេចមិញ ភាសិតនេះសុភាសិត រមែងមានផលដល់
អ្នកដែលធ្វើតាមដោយគោរព ដូច្នោះឯង ។

មាលាការ បេះធ្វើសំណុំនៃតម្រងផ្កា អំពីគំនរនៃផ្កា (ផ្សែងៗគ្នា)
ឲ្យច្រើនបាន យ៉ាងណាមិញ កុសលដែលសត្វកើតមកហើយ គួរ
ធ្វើឲ្យច្រើន យ៉ាងនោះ ។

កិនផ្កាឈើ ផ្សាយទៅច្រាសខ្យល់ មិនបាន ក្លិនខ្ញីមជ្ឈន្តក្តី ក្លិន
ខ្ញីក្រស្នាក្តី ក្លិនផ្កាម្ទិះវត្តក្តី តំផ្សាយទៅច្រាសខ្យល់ មិនបាន

ធម្មបទត្ថាយ ចតុត្ថោ បុប្ផវគ្គោ

សតញ្ច តណ្ហោ បដិឃាតមេតិ
សញ្ញោ ទិសា សប្បុរិសោ បភាសតិ[๑] ។
ចន្ទនំ តគរំ វាបិ ឧប្បលំ អថ វស្សិកី
ឯតេសំ គន្ធជាតានំ សីលគន្ធោ អនុត្តរោ ។
អប្បមត្តោ អយំ គន្ធោ យាយំ តគរចន្ទនី[๒]
យោ ច សីលវតំ គន្ធោ វាតិ ទេវេសុ ឧត្តមោ ។
តេសំ សម្បន្នសីលានំ អប្បមាទវិហារិនំ
សម្មទញ្ញា វិមុត្តានំ មារោ មគ្គំ ន វិន្ទតិ ។
យថា សង្ការធានស្មិំ[๓] ឧជ្ឈិតស្មិំ មហាបថេ
បទុមំ តត្ថ ជាយេថ សុចិគន្ធំ មនោរមំ
ឯវំ សង្ការភូតេសុ អន្ធភូតេ[๔] បុថុជ្ជនេ
អតិរោចតិ បញ្ញាយ សម្មាសម្ពុទ្ធសាវកោ ។

បុប្ផវគ្គោ ចតុត្ថោ ។

---

๑ ឧ. បភាតិ ។ ๒ ម. តគរចន្ទនំ ។ ๓ ម. សង្ការដ្ឋានស្មិំ ចាហេ ។
๔ ម. អន្ធូភូតេ ។

ចំណែកក្លិនរបស់សប្បុរសតាំងឡាយ រមែងផ្សាយទៅច្រាសខ្យល់បាន ព្រោះសប្បុរស រមែងផ្សាយទៅបានគ្រប់ទិស ។ ក្លិននៃសីលជាគុណជាតប្រសើរបំផុតជាងគន្ធជាតទាំងនេះគឺ ខ្លឹមចន្ទន៍ ខ្លឹមត្រែស្នា ផ្កាឧប្បល ផ្កាម្ទិះលា ។

ក្លិនត្រែស្នា ទីឆ៏ក្លិនចន្ទន៍ណា ក្លិននេះ ត្រែអូបមានប្រមាណតិចទេ ចំណែកក្លិននៃបុគ្គលមានសីលតាំងឡាយណា ក្លិននោះ ទើបត្រែអូបលើសលប់ ផ្សាយទៅក្នុងទេវលោកនឹងមនុស្សលោកបាន ។

មាពជិកាជ (ទុកជាទំស្ងែរក) ក៏មិនចូលចម្លងផ្លូវរបស់លោក អ្នកមានសីលបរិបូណ៌ អ្នកនៅដោយសេចក្តីមិនប្រមាទ អ្នករួចស្រែឡះ (ចាកធម៌ជាគ្រឿងសៅហ្មង) ព្រោះដឹងច្បាស់តាមហេតុ ។

ផ្កាឈូក ទុកជាកើតក្នុងគំនរសម្រាម ដែលគេចាក់ចោលតែរថ្នូរធំនោះ ក៏គង់មានក្លិនត្រអូប ជាទីរីករាយនៃចិត្តបាន ដូចម្តេចមិញ បណ្តាជន ដែលដូចជាគំនរសម្រាម សាវ័ករបស់ព្រះសម្មាសម្ពុទ្ធ រមែងរុងរឿងកន្ទុងផុតបុថុជ្ជនតាំងឡាយ ដែលល្ងិតល្ងង់ ដោយប្រាជ្ញា (របស់ខ្លួន) ដូច្នោះឯង ។

ธมฺมปทคาถาย ปฏฺฐมา ภาณวารคฺคา

[๑๕] ยถา ปิ ภาคโร ปตฺวา ยิฏฺฐิ สนฺตสฺส เยภุยฺยโต
ยถา ภาณวโร สมาโน สนฺตึ อาปชฺชเต ๆ
จรญฺเญ ภาวิตตฺตสฺส สเยยฺยุ สนิสมตฺตโน
ปกาจริยึ ธนฺยุ ภยา ตสฺส ภาณเว สมาหิตา ๆ
ปุตฺตา(๑) ปิตฺตุ ธนมตฺตุ(๒) ยถา ภาณเว วิหญฺญติ
อตฺตา หิ อตฺตโน ตสฺส กาโร ปุตฺตา(๓) กาโร ธนมฺ ๆ
เยภา ภาณเว ปญฺญตฺ(๔) ภาณวา ปณฺฑิโต ภวิ เตน เสภา
ภาณเว ย ปณฺฑิตสมาสี สเว ภาณเวติ วุจฺจติ ๆ

---

๑ ม. ปุตฺต ฯ ๒ ฉ. ธนมตฺติ ฯ ๓ ม. ปุตฺโต ฯ ๔ ฉ. ม. ปญฺตฺ ฯ

ធម្មបទគាថា ពាលវគ្គទី ៥

[១៩] ក្តីវែង បំពោះតែអ្នកក្រាក់ក្រៃត (អ្នកដេកមិនលក់) យោជន៍វែង បំពោះតែអ្នកខ្សឹយហត់ សង្សារវដ្តវែង បំពោះតែបុគ្គលពាលមិនដឹងច្បាស់នូវព្រះសទ្ធម្ម ។

បុគ្គលកាលស្វះស្វែងរកកល្យាណមិត្ត បើមិនបានមិត្តដ៏ប្រសើរជាងខ្លួន ឬមិត្តដែលស្មើនឹងខ្លួនទេ គប្បីប្រព្រឹត្តនៅតែម្នាក់ឯង ឲ្យខ្ជាប់ខ្ជួនវិញ ព្រោះថាសហាយតាគុណ(១)មិនមានក្នុងបុគ្គលពាលឡើយ ។ ជនពាលតែងព្រួយលំបាក ដោយសេចក្តីសំគាល់ថា កូនទាំងឡាយរបស់អញមាន ទ្រព្យរបស់អញមាន តាមដែលពិត សូម្បីខ្លួនរបស់ខ្លួនក៏មិនមាន (២) បំណងបើកូនទាំងឡាយ នឹងរាប់ថាមានអំពីណាបាន ទ្រព្យនឹងរាប់ថា មានអំពីណាបាន ។

អ្នកណា ជាមនុស្សពាល ហើយដឹងនូវភាពនៃខ្លួនថាជាពាល អ្នកនោះនឹងទៅជាបណ្ឌិតបានខ្លះ ដោយហេតុដែលដឹងខ្លួន ថាជាពាលនោះ ម្យ៉ាងទៀត អ្នកណា ជាមនុស្សពាល មានសេចក្តីប្រកាន់ថាខ្លួនជាបណ្ឌិត អ្នកនោះ ឈ្មោះថាជាមនុស្សពាល ដោយពិត ។

---

១ ចូឡសីល, មជ្ឈិមសីល, មហាសីល, កថាវត្ថុ១០, ធុតង្គគុណ១៣, វិបស្សនាគុណ, មគ្គ៤, ផល៤, វិជ្ជា៣ អភិញ្ញា៦, ហៅថា សហាយតាគុណ ។ ២ ព្រោះមិនអាចនឹងការពារទុក្ខបាន ។ អដ្ឋកថា ។

ធម្មបទគាថាយ បញ្ចមោ ពាលវគ្គោ

យាវដីវម្បិ ចេ ពាលោ បណ្ឌិតំ បយិរុបាសតិ
ន សោ ធម្មំ វិជានាតិ ទព្វី សូបរសំ យថា ។
មុហុត្តមបិ ចេ វិញ្ញូ បណ្ឌិតំ បយិរុបាសតិ
ខិប្បំ ធម្មំ វិជានាតិ ជិវ្ហា សូបរសំ យថា ។
ចរន្តិ ពាលា ទុម្មេធា អមិត្តេនេវ អត្តនា
ករោន្តា(๑) បាបកំ កម្មំ យំ ហោតិ កដុកប្ផលំ(๒) ។
ន តំ កម្មំ កតំ សាធុ យំ កត្វា អនុតប្បតិ
យស្ស អស្សុមុខោ រោទំ វិបាកំ បដិសេវតិ ។
តញ្ច កម្មំ កតំ សាធុ យំ កត្វា នានុតប្បតិ
យស្ស បតីតោ សុមនោ វិបាកំ បដិសេវតិ ។
មធុវា មញ្ញតិ ពាលោ យាវ បាបំ ន បច្চតិ
យទា ច បច្চតិ បាបំ អថ(๓) [ពាលោ]ទុក្ខំ និគច្ឆតិ ។

---

๑ ម. ករោនុំ ។ ๒ ម. កដុំក ដលំ ។ ๓ ម. អថស្សេ ឥត្ថំ ។

ធម្មបទគាថា ពាលវគ្គទី ៥

មន្ទស្សពាល បើបុគ្គលខៅអង្គុយជិតអ្នកប្រាជ្ញ សូម្បីអស់មួយជីវិត
តែមិនដឹងនូវសេចក្តីពិតទេ ឱប្បាសលាស់ឡើយ ដូចវែក ដែលមិនដឹង
រសសម្លៃ ។

វិញ្ញូជន បើបុគ្គលខៅអង្គុយជិតអ្នកប្រាជ្ញ សូម្បីតែមួយរំពេច រមែង
ឃាល់នូវសេចក្តីពិត ដោយឆាប់រហ័ស ដូចអណ្តាត ដឹងនូវរសសម្លៃ ។

ពួកជនពាលមិនមានប្រាជ្ញា មានខ្លួនដូចជាសត្រូវ តែងធ្វើកម្មលាមក
ដែលផ្តាំអំពើមានផលល្វើយក្រហាយ ។

បុគ្គលធ្វើកម្មណាហើយ រមែងក្តៅក្រហាយ ឬមានមុខប្រឡាក់
ដោយទឹកភ្នែក ស្រែកយំ នូវផលនៃកម្មណា កម្មដែលគេធ្វើ
ហើយនោះ ឈ្មោះថាជាកម្មមិនល្អឡើយ ។

បុគ្គលធ្វើកម្មណាហើយ រមែងមិនក្តៅក្រហាយ ឬដល់នូវសេចក្តីពេញ
ចិត្ត មានចិត្តល្អ នូវផលនៃកម្មណា កម្មដែលគេធ្វើហើយនោះឯង
ឈ្មោះថាជាកម្មល្អ ។

ចាបមិនគាន់ទ្រាំផលត្រឹមណា ជនពាល តែងសំគាល់នូវចាបនោះថា
ដូចទឹកឃ្មុំ លុះតែកាលណាចាបទ្រាំផល ជនពាលនោះបានប្រទះនូវសេចក្តី
ទុក្ខ កាលណោះ ។

សុត្តន្តបិដកេ ខុទ្ទកនិកាយស្ស ធម្មបទគាថា

ហាសេ ហាសេ កុសលេន ពាលោ កុញ្ជេ អោធំ
ន សោ សង្ខាតធម្មានំ តាលំ អក្ខាតិ សោឡសឹ ។
ន ហិ ចាបំ តាតំ តាមំ សង្ខីរំ មុច្ចតិ
ឯហន្តំ ពាលមន្ទេតិ ភស្មាច្ឆន្នោវ(១) ចាវកោ ។
យោវនេវ អនត្ថាយ ញត្តំ ពាលស្ស ជាយតិ
ហន្តិ ពាលស្ស សុក្កំសំ មុទ្ធំ អស្ស(២) វិបាតយំ ។
អសន្តំ ភាវមិច្ឆេយ្យ បុរេក្ខារញ្ច ភិក្ខុសុ
អាវាសេសុ ច ឥស្សរិយំ បូជា បរកុលេសុ ច ។

---

១ ឧ. ភស្មច្ឆន្នោ ។ ២ ម. ពុទ្ធិមស្ស ។

ជនពាលទុកដាក់វិរកោតកោដនដោយចុង(១)ស្មៅ រាល់ៗខែ ជនពាល
នោះក៏មិនដល់មួយចំណែកនៃចំណែកទី១៦ ៗ លើក របស់បុគ្គលចាំធ
ឮាយ ដែលមានធម៌បានដឹង ឬបានពិចារណាហើយឡើយ ។
កម្មណាមក ដែលជនពាលធ្វើហើយ មិនទាន់ឲ្យផលនោះក៏មាន ដូច
ទឹកដោះស្រស់ ដែលមិនទាន់ប្រែក្សាយ (ក្នុង ១ រំពេច) ដូច្នោះ
ឆាបតម្មនោះ តាមដុតបុគ្គលពាល ដូចរងើកភ្លើងដែលបិទបាំងទុក
ដោយផេះដូច្នោះ ។

ការចេះដឹង តើតឡើងដល់បុគ្គលពាល គ្រាន់តែដើម្បីសេចក្តីវិនាស
ប៉ុណ្ណោះ រមែងញ៉ាំងបញ្ញាឲ្យធ្លាក់ចុះ បំផ្លេចបំផ្លាញចំណែកធម៌សគ
ុសលរបស់បុគ្គលពាលនោះ ។ កិត្តិពាល រមែងប្រាថ្នានូវ
សេចក្តីសរសើរ ដែលមិនមាន(ក្នុង ខ្លួន)ផង នូវការធ្វើក្នុងខាងមុខ
គឺជាប្រមុខ ក្នុងពួកភិក្ខុផង នូវការជាឥស្សរៈ ក្នុងអារាមសាំធឮាយ
ផង នូវការបូជាចាំធឮាយ ក្នុងត្រកូលនៃជនចាំធឮាយ ដូចៃ ផង

---

(១) បានសេចក្តីថា យកចុងស្មៅចាក់កោដន ហើយយកមកតេះនឹងចុងអណ្តាត
ចំពោះគាថានេះ ព្រះសម្ពុទ្ធទ្រង់សំដែងប្រារព្ធនឹងជម្ពុកាដីរក ដែលជាអ្នកប្រព្រឹត្តបរិកោត
បែបនោះដែរតែ ក្នុងពេលដែលមហាជនតាំកោដនមកប្រុងជា ។

មមេវ កតមញ្ញុំ តិមាមប្បេតិ ទុកោ

មមេវ អតិវសា[1] អស្សុ តិច្ឆាតិច្ឆេសុ តិស្ថិ[2]

(๓)

ឥតិ ពាលស្ស សង្កប្បោ ឥស្សា មានោ ច វឌ្ឍតិ ។

អញ្ញា ហិ លាភូបនិសា អញ្ញា និព្វានគាមិនី

ឯវមេតំ អភិញ្ញាយ ភិក្ខុ ពុទ្ធស្ស សាវកោ

សក្কារំ នាភិនន្ទេយ្យ វិវេកមនុព្រូហយេ ។

ពាលវគ្គោ បញ្ចមោ ។

ធម្មបទគាថាយ ឆដ្ឋោ បណ្ឌិតវគ្គោ

(๑๖) និធីនំវ បវត្តារំ យំ បស្សេ វជ្ជទស្សិនំ

និគ្គយ្ហវាទិំ មេធាវិំ តាទិសំ បណ្ឌិតំ ភជេ

តាទិសំ ភជមានស្ស សេយ្យោ ហោតិ ន បាបិយោ ។

---

๑ ខ, ម, មមេវាតិវសា ។ ๒ ម, កិស្មិញ្ចិ ។ ๓ ខ, ម, ឥច្ឆា ។

តិក្ខុពាល តែងមានសេចក្តីត្រិះរិះថា គ្រហស្ថនឹងបព្វជិត ពាំង ២ ពួក ចូរសំគាល់នូវកិច្ចដែលមនុស្សដទៃធ្វើហើយថាជាកិច្ចរបស់អញវិញ អំណាចដំរែលែងរបស់អញ ចូរមានក្នុងកិច្ច គួប ធំ ណា ។ មួយ (កាលបើយ៉ាងនេះ) ឫស្សា នឹងមានះ រមែងចំរើន ។ បដិបទា អាស្រ័យនូវលោកផ្សេង បដិបទា ជាដំណើរទៅកាន់ព្រះនិញ្វានផ្សេង តិក្ខុជាសាវ័កបស់ព្រះពុទ្ធ ដឹងច្បាស់នូវហេតុនុ៎ះយ៉ាងនេះហើយ មិនគួរត្រេកអរចំពោះសក្ការៈឡើយ គប្បីញុំាងវិវេកឲ្យចំរើនដោយលំដាប់ ។

ចប់ ពាលវគ្គទី ៥ ។

ធម្មបទគាថា បណ្ឌិតវគ្គទី ៦

(១៦) បុគ្គលគួរឃើញនូវអ្នកប្រាជ្ញណា ដែលជាអ្នកពោលសង្កត់សង្កិន ចង្អុលប្រាប់ទោស ថាដូចជាបុគ្គលអ្នកប្រាប់កំណប់ទ្រព្យឲ្យដូច្នោះ គួរគប់អ្នកប្រាជ្ញបែបនោះ (ព្រោះថា) កាលបុគ្គលគប់អ្នកប្រាជ្ញបែបនោះហើយ រមែងមានសេចក្តីគាប់ប្រសើរ ឥតមានទោសដ៏លាមកឡើយ ។

ទិវាតបេយ្យា ឆុសាសេយ្យា អសព្ភា ច ឯឝារយេ
សតំ ហិ សោ ភិយ្យោ ហោតិ អសតំ ហោតិ អប្បិយោ ។
ឯ កដេ ចាបតេ ភិត្តេ ឯ កដេ បុរិសាឝមេ
កដេ ភិត្តេ កលញ្ជាសោ កដេ បុរិសុត្តមេ ។
ឆប្បញ្ញាតិ សុខំ សេតិ វិប្បសន្នេន ចេតសា
អរិយប្បវេទិតេ ធម្មេ សទា រមតិ បណ្ឌិតោ ។

ឧទកញ្ហិ នយន្តិ នេត្តិកា
ឧសុការ ឧមយន្តិ(๑) តេជនំ
ទារុំ ឧមយន្តិ(๑) តច្ឆកា
អត្តានំ ឧមយន្តិ បណ្ឌិតា ។

សេសោ យថា ឝកឃនោ ឝារេន ឯ សមីរតិ
ឯវំ និន្ទាបសំសាសុ ឯ សម្បញ្ញេ បណ្ឌិតា ។
យថាបិ រហទោ គម្ភីរោ វិប្បសន្នោ អនាវិលោ
ឯវំ ធម្មានិ សុត្វាន វិប្បសីទន្តិ បណ្ឌិតា ។

---

๑ ម. ឧមយន្តិ ។

បណ្ឌិតគួរទ្ទន្ទានប្រៀនប្រដៅ គួរហាមឃាត់នូវជនពាល ឲ្យចាក
អំពើអសប្បុរស បណ្ឌិតនោះ រមែងជាទីស្រឡាញ់របស់សប្បុរស
តែម្យ៉ាង មិនជាទីស្រឡាញ់នៃអសប្បុរសឡើយ ។
បុគ្គល មិនគួរគប់មិត្តអាក្រក់ មិនគួរគប់បុរសថោកទាប គួរគប់
តែមិត្តដែលល្អ គួរគប់តែបុរសជាន់ខ្ពស់ ។
បណ្ឌិត ដែលមានសេចក្តីត្អែតត្អរក្នុងធម៌ មានចិត្តជ្រះថ្លាហើយ រមែង
ដេកជាសុខ រមែងត្រេកអរ ក្នុងធម៌ដែលព្រះអរិយៈ ប្រកាស
ទុកហើយ ជ្រះថ្លាល ។
ធម្មតាអ្នកបង្វែកទឹក តែងបង្វែកទឹកទៅ អ្នកធ្វើព្រួញ តែងពត់ព្រួញ
(ឲ្យត្រង់) អ្នកចាំងឈើ តែងចាំងឈើ ឯបណ្ឌិតចាំងឲ្យ តែង
ទ្ទន្ទានខ្លួន(ដូច្នោះដែរ) ។
ភ្នំថ្មតាន់ មិនរំកើប ព្រោះខ្យល ដូចម្តេចមិញ បណ្ឌិតចាំងឲ្យ
ក៏មិនរំកើប ព្រោះពាក្យតិះដៀល នឹងពាក្យសរសើរ (ជាដើម)
ដូច្នោះឯង ។
អង្ឃដ៏ទឹកដែលជ្រៅ រមែងថ្លាមិនល្អក់យ៉ាងណា បណ្ឌិតចាំងឲ្យ
បើបានស្តាប់ធម៌ទេសនាហើយ រមែងជ្រះថ្លាស៊ប់ស្អួន យ៉ាងនោះ ។

ធម្មបទគាថាយ ជរ្ជ្ជោ បណ្ឌិតវត្ថុ

សព្ពត្ថ វេ សប្បុរិសា វជន្តិ(๑)

ន កាមកាមា លបយន្តិ សន្តោ

សុខេន ផុដ្ឋា អដ ឋ ទុខេន

ន ឧច្ចាវចំ បណ្ឌិតា ទស្សយន្តិ ។

ន អត្តហេតុ ន បរស្ស ហេតុ

ន បុត្តមិច្ឆេ ន ធនំ ន រដ្ឋំ

ន ឥច្ឆេយ្យ អធម្មេន សមិទ្ធិមត្តនោ

ស សីលវា បញ្ញវា ធម្មិកោ សិយា ។

អប្បកា តេ មនុស្សេសុ យេ ជនា បារគាមិនោ

អថាយំ ឥតរា បជា តីរមេវានុធាវតិ ។

យេ ច ខោ សម្មទក្ខាតេ ធម្មេ ធម្មានុវត្តិនោ

តេ ជនា បារមេស្សន្តិ មច្ចុធេយ្យំ សុទុត្តរំ ។

កណ្ហំ ធម្មំ វិប្បហាយ សុក្កំ ភាវេថ បណ្ឌិតោ

---

๑ ម. បដិន្តិ ។ ម. វិដ្ឋន្តិ ។

ធម្មបទគាថា បណ្ឌិតវគ្គទី ៦

ពួកសប្បុរស តែងលះ (នូវកាម) ក្នុងធម៌ទាំងពួង ពួកលោកអ្នកស្ងប់រមែងមិនរវែរវាយ ព្រោះសេចក្តីប្រាថ្នាក្នុងកាម ពួកបណ្ឌិតបើសេចក្តីសុខឬទុក្ខពាល់ត្រូវហើយ រមែងមិនសំដែងអាការឡើងចុះឡើយ ។ បណ្ឌិតមិនគួរធ្វើអាក្រក់ ព្រោះហេតុនៃខ្លួន មិនគួរធ្វើអាក្រក់ ព្រោះហេតុនៃអ្នកដទៃ មិនគួរប្រាថ្នាកូន មិនគួរប្រាថ្នាទ្រព្យ មិនគួរប្រាថ្នារដ្ឋ មិនគួរប្រាថ្នាសិទ្ធិ ដើម្បីខ្លួន ដោយហេតុមិនមែនជាធម៌ឡើយ លោកគួរជាអ្នកមានសីល មានប្រាជ្ញាប្រកបដោយធម៌ ។ បណ្តាមនុស្សទាំងឡាយ ពួកជនណា ដែលឆ្លងដល់ត្រើយគឺព្រះនិព្វាន ពួកជននោះ មានប្រមាណតិច ចំណែកពួកសត្វត្រាំនេះ រមែងស្ទុះទៅកាន់ត្រើយ (គឺសក្កាយទិដ្ឋិ) ។ ជនទាំងឡាយណា ប្រព្រឹត្តតាមធម៌ក្នុងធម៌ ដែលព្រះតថាគតទ្រង់សំដែងទុកហើយដោយប្រពៃ ជនទាំងនោះនឹងឆ្លងនូវលំនៅនៃមច្ចុ ដែលមិនងាយឆ្លងបាន ហើយដល់នូវព្រះនិព្វាន ។ បណ្ឌិតគួរលះបង់ធម៌ខ្មៅ[1]ចេញ ញុំាងធម៌[2]ស ឲ្យចំរើនឡើង

---

១ អកុសលធម៌ មានកាឡេទុច្ចរិតជាដើម ។ ២ កុសលធម៌មានកាយសុចរិតជាដើម ។ អដ្ឋកថា ។

ទិសា អនោសមាគម្ម វិវេកេ យត្ថ ទូរមំ

តត្រាភិរតិមិច្ឆេយ្យ ហិត្វា កាមេ អកិញ្ចនោ

បរិយោទបេយ្យ អត្តានំ ចិត្តក្លេសេហិ បណ្ឌិតោ។

យេសំ សម្ពោធិយង្គេសុ សម្មា ចិត្តំ សុភាវិតំ

អាទានប្បដិនិស្សគ្គេ អនុបាទាយ យេ រតា

ខីណាសវា ជុតិមន្តោ តេ លោកេ បរិនិព្ពុតា។

បណ្ឌិតវគ្គោ ឆដ្ឋោ ។

ធម្មបទគាថាយ សត្តមោ អរហន្តវគ្គោ

[๑๗] គតទ្ធិនោ វិសោកស្ស វិប្បមុត្តស្ស សព្ពធិ

សព្ពគន្ថប្បហីនស្ស បរិឡាហោ ន វិជ្ជតិ ។

(ដោយវិធី)ចេញចាកអាល័យគឺតាមគុណ ហើយឈមទៅរកព្រះនិព្វាន ជាធម្មជាតមិនមានអាល័យ គប្បីលះបង់តាមពាំងឆ្ងាយចេញ ជាអ្នកមិនមានកង្វល់ ច្រាច្បាស់នូវសេចក្តីត្រេកអរ ក្នុងវិវេកដែលពួកសត្វត្រេកអរបានដោយក្រនោះ បណ្ឌិតគួរញុំាងខ្លួនឲ្យផូរផង់ចាកគ្រឿងសៅហ្មងចិត្ត ។ ចិត្តដែលបណ្ឌិតពាំងឆ្ងាយណា បានអប់រំល្អហើយ ក្នុងអង្គនៃធម៌ ជាគ្រឿងត្រាស់ដឹងពាំងឆ្ងាយ ឬ បណ្ឌិតពាំងឆ្ងាយណា មិនប្រកាន់មាំ ត្រេកអរតែក្នុងការលះនូវសេចក្តីប្រកាន់មាំ បណ្ឌិតពាំងឆ្ងាយនោះ ។ រមែងជាអ្នកអស់អាសវៈ មានសេចក្តីរីរឿង បរិនិព្វាន ក្នុងលោក ។

ចប់ បណ្ឌិតវគ្គទី ៦ ។

ធម្មបទគាថា អរហន្តវគ្គទី ៧

[១៧] សេចក្តីក្តៅក្រហាយ(១) រមែងមិនមានដល់លោកអ្នក មានផ្លូវឆ្លាយដើរដល់(២)ហើយ មិនមានសេចក្តីសោក រួចស្រឡះចាកធម៌ពាំងពួន (មានខន្ធជាដើម)មានគំលេសជាគ្រឿងចាក់ស្រេះពាំងពួនលះបង់ហើយ ។

---

១ សេចក្តីក្តៅក្រហាយមាន ២យ៉ាង គឺក្តៅក្រហាយកាយ ១ ក្តៅក្រហាយចិត្ត ។ ព្រះខីណាស្រវ នៅមានសេចក្តីក្តៅក្រហាយកាយ ព្រោះអំណាចកំដៅថ្ងៃឬត្រជាក់ជាដើមតែក្តៅក្រហាយក្នុងចិត្ត មិនមានក្នុងទីនេះសំដៅសេចក្តីក្តៅក្រហាយក្នុងចិត្ត។ ២ ផ្លូវឆ្លាយក្នុងទីនេះ សំដៅយកវដ្តៈដែលហៅថាវដ្តៈ ។ ពួកសត្វដែលជាប់ក្នុងវដ្តៈ នៅក្នុងផ្ទះឯរាបណា ឈ្មោះថាជាអ្នកដើរផ្លូវឆ្ងាយឯរាបនោះ ព្រះសោភបន្ទបុគ្គលជាដើម ក៏ហៅថាអ្នកដើរផ្លូវឆ្ងាយដែរ ព្រោះមិនទាន់អស់វដ្តៈ តែព្រះខីណាស្រពលោកធ្វើវដ្តៈឲ្យអស់ហើយ ឲ្យឈ្មោះថាជាអ្នកដ៏ឥតផ្លូវឆ្ងាយដើរដល់ហើយ ។

ធម្មបទគាថាយ សត្តមោ អរហន្តវគ្គោ

ទុយ្យុញ្ជន្តិ សតីមន្តោ ឧ ឯតេតេ រមន្តិ តេ
ហំសាវ បល្វលំ ហិត្វា ឯតមោកំ ជហន្តិ តេ ។
យេសំ សន្និចយោ នត្ថិ យេ បរិញ្ញាតភោជនា
សុញ្ញតោ អនិមិត្តោ ច វិមោក្ខោ យេស គោចរោ
អាកាសេវ សកុន្តានំ(๑) បទំ តេសំ ទុរន្នយោ ។
យេស្សាសវា បរិក្ខីណា អាហារេ ច អនិស្សិតោ
សុញ្ញតោ អនិមិត្តោ ច វិមោក្ខោ យេស្ស គោចរោ
អាកាសេវ សកុន្តានំ(๑) បទន្តស្ស ទុរន្នយំ ។

យស្សិន្ទ្រិយានិ សមថង្គតានិ
អស្សា យថា សារថិនា សុទន្តា
បហីនមានស្ស អនាសវស្ស
ទេវាបិ តស្ស បិហយន្តិ តាទិនោ ។

---

๑ ម. សកុណានំ ។

ធម្មបទគាថា អរហន្តវគ្គទី ៣

ព្រះខីណាស្រពតាំងខ្លាយ មានស្មារតី រមែងខ្វល់ខ្វាយ[1]
រមែងត្រេកអរ ក្នុងទីនៅអាស្រ័យ លោកលះបង់ចោលស្រុះ
នូវអាល័យតាំងអស់ ដូចហង្សលះបង់តំហើរទៅ ដូច្នោះ ។
ពួកជនណា មិនមានសេចក្តីសន្សំ ពួកជនណា កំណត់ដឹងភោជន
ហើយ ជនណា មានសុញ្ញតវិមោក្ខ អនិមិត្តវិមោក្ខនិងអប្បណិហិត-
វិមោក្ខ ជាគោចរ គតិគឺដំណើរ របស់ពួកជននោះ។ គេកម្រដឹង
ឃាន ដូចដំណើរនៃពួកសត្វស្លាបក្នុងអាកាស ដូច្នោះ ។
ជនណា អស់អាសវៈហើយ តាំងមិនអាស្រ័យ (តណ្ហានិងទិដ្ឋិ) ក្នុង
អាហារ ជនណា មានសុញ្ញតវិមោក្ខ អនិមិត្តវិមោក្ខ និងអប្ប
ណិហិតវិមោក្ខ ជាគោចរ ដំណើររបស់ជននោះ គេកម្រដឹងឃាន
ដូចដំណើរនៃពួកសត្វស្លាបក្នុងអាកាស ដូច្នោះ ។
ឥន្ទ្រិយតាំងខ្លាយ របស់អ្នកណា ដល់នូវការស្ងប់រម្ងាប់ ដូចសេះ
ដែលនាយសារថី ហ្វឹកហ្វឺនរួចហើយ សូម្បីទេវតានឹងមនុស្ស
តាំងខ្លាយ ក៏ស្រឡាញ់អ្នកនោះដែរ ដែលមានមានះលះបង់
ហើយ មិនមានអាសវៈ ជាបុគ្គលមានចិត្តនឹងធឹងមិនញាប់ញ័រ ។

---

[1] ខ្វល់ខ្វាយក្នុងគុណដែលខ្លួនបានហើយ ឬក្នុងឈានទាំងវិបស្សនា ដោយកំចាត់
រំពឹងចូលចេញ អធិដ្ឋាន ឬពិចារណាមិនមានសម្រាក ។ អដ្ឋកថា ។

បឋវីសមោ នោ វិរុជ្ឈតិ
ឥន្ទខីលូបមោ តាទិ សុព្ពតោ
រហទោវ អបេតកទ្ទមោ
សំសារា ន ភវន្តិ តាទិនោ ។
សន្តំ តស្ស មនំ ហោតិ
សន្តា វាចា ច កម្ម ច
សម្មទញ្ញា វិមុត្តស្ស
ឧបសន្តស្ស តាទិនោ ។
អស្សទ្ធោ អកតញ្ញូ ច
សន្ធិច្ឆេទោ ច យោ នរោ
ហតាវកាសោ វន្តាសោ
ស វេ ឧត្តមបោរិសោ ។
គាមេ វា យទិ វារញ្ញេ
និន្នេ វា យទិ វា ថលេ
យត្ថ អរហន្តោ វិហរន្តិ
តំ ភូមិរាមណេយ្យកំ(១) ។

---

១ ឱ· ភូមី រមណេយ្យកំ ។

តិក្ខុមានចិត្តដូចផែនដី មិនក្រោធ មានវត្តល្អ មានចិត្តនឹងធឹងដូច
សសរគោល មានចិត្តថ្លា ដូចអង្គឹធ្រាសចាកកក់ សង្សារ
ទាំងឡាយរបស់តិក្ខុបែបនោះ រមែងមិនមាន ។
ចិត្តស្ងប់ វាចាស្ងប់ នឹងកាយកម្មស្ងប់ រមែងមាន ដល់លោក
ដែលដឹងដោយប្រពៃ ផុតស្រឡះ (ចាកពាធិក្លិសេស) ជាអ្នក
ស្ងប់រម្ងាប់ ដូច្នោះ ។
នរជនណា មិនជឿអ្នកដទៃផង ស្គាល់ព្រះនិព្វានផង កាត់ខ្សែ
គ្រឿងតភ្ជាប់ផង មានឧកាសកំចាត់បង់ហើយផង មានសេចក្តី
ប្រាថ្នាខ្ជាក់ចោលហើយផង នរជននោះ ជាឧត្តមបុរស ។
ព្រះអរហន្តទាំងឡាយ នៅកន្លែងណា ទោះជាស្រុកក្តី ព្រៃក្តី
ទីជាបក្តី ទីទួលក្តី ទីនោះឯង ជាភូមិ គួរត្រេកអរ ។

រមេណីយេនិ អរញ្ញានិ

យត្ថ ន រមតី ជនោ

វីតរាគា រមេស្សន្តិ

ន តេ កាមគវេសិនោ ។

អរហន្តវគ្គោ សត្តមោ ។

ធម្មបទគាថាយ អដ្ឋមោ សហស្សវគ្គោ

(๑๔)សហស្សមបិ ចេ ភាសា អនត្ថបទសញ្ហិតា

ឯកំ អត្ថបទំ សេយ្យោ យំ សុត្វា ឧបសម្មតិ ។

សហស្សមបិ ចេ គាថា អនត្ថបទសញ្ហិតា

ឯកំ គាថាបទំ សេយ្យោ យំ សុត្វា ឧបសម្មតិ ។

យោ ច គាថា សតំ ភាសេ អនត្ថបទសញ្ហិតា[๑]

ឯកំ ធម្មបទំ[๒] សេយ្យោ យំ សុត្វា ឧបសម្មតិ ។

---

๑ ម· អនត្ថបទសញ្ហិតំ ។ ๒ ម· គាថាបទំ ។

ធម្មបទគាថា សហស្សវគ្គទី ៨

ជន (អ្នកស្វែងរកតាម) រមែងមិនត្រេកអរ ក្នុងកន្លែងដែលគួរត្រេកអរទេ ព្រោះឃើញស្ត្រីដែលមានរាគៈខ្លាំងហើយ ទើបត្រេកអរក្នុងកន្លែងនោះ ព្រោះលោកជាអ្នក មិនស្វែងរកតាម ។

ចប់ អរហន្តវគ្គទី ៧ ។

ធម្មបទគាថា សហស្សវគ្គ ទី ៨

(១៨) បើវាចា សូម្បីច្រើនពាន់ម៉ាត់ ជាវាចាប្រកបដោយបទឥតប្រយោជន៍ វាចានោះ ពុំបានសេចក្តីឡើយ អ្នកណា ស្តាប់បទមានប្រយោជន៍ណាហើយ រមែងស្ងប់រម្ងាប់បាន បទមានប្រយោជន៍នោះ សូម្បីតែ១ បទ ក៏ឈ្មោះថា ប្រសើរជាង ។

បើគាថា សូម្បីច្រើនពាន់ ជាគាថា ប្រកបដោយបទឥតប្រយោជន៍ គាថានោះ ពុំប្រសើរឡើយ អ្នកណាស្តាប់បទនៃគាថាណាហើយ រមែងស្ងប់រម្ងាប់បាន បទនៃគាថានោះ សូម្បីតែ១ បទ ក៏ឈ្មោះថា ប្រសើរជាង ។

អ្នកណា គប្បីពោលគាថាមួយរយ ជាគាថា ប្រកបដោយបទឥតប្រយោជន៍ គាថាដែលអ្នកនោះពោលហើយនោះ ពុំប្រសើរឡើយ អ្នកណាស្តាប់បទនៃធម៌ហើយ រមែងស្ងប់រម្ងាប់បាន បទនៃធម៌នោះ សូម្បីតែមួយបទ ក៏ឈ្មោះថា ប្រសើរជាង ។

យោ សហស្សំ សហស្សេន សង្គ្រាមេ មានុសេ ជិនេ
ឯកញ្ច ជេយ្យមត្តានំ ស វេ សង្គ្រាមជុត្តមោ ។

អត្តា ហវេ ជិតំ សេយ្យោ យោ ចាយំ ឥតរា បជា
អត្តទន្តស្ស ទោសស្ស និច្ចំ សញ្ញតចារិនោ[1]

នេវ ទេវោ ន គន្ធព្ពោ ន មារោ សហ ព្រហ្មុនា
ជិនំ អបជិតំ កយិរា តថារូបស្ស ជន្តុនោ ។

មាសេ មាសេ សហស្សេន យោ យជេថ សតំ សមំ
ឯកញ្ច ភាវិតត្តានំ មុហុត្តមបិ បូជយេ
សាយេវ បូជនា សេយ្យោ យញ្ចេ[2] វស្សសតំ ហុតំ ។

យោ ច វស្សសតំ ជន្តុ អគ្គិំ បរិចរេ វនេ
ឯកញ្ច ភាវិតត្តានំ មុហុត្តមបិ បូជយេ
សាយេវ បូជនា សេយ្យោ យញ្ចេ[3] វស្សសតំ ហុតំ ។

---

១ ឱ. សំយតចារិនោ ។ ម. សញ្ញតចារិនោ ។ ២-៣ ឱ. យញ្ញ ។

អ្នកណា គប្បីឈ្នះពួកមនុស្សក្នុងសង្គ្រាមអស់មួយពាន់ៗដង គឺមួយលាន ចំណែកអ្នកណា ឈ្នះខ្លួនឯងម្នាក់ឯងបាន អ្នកនោះឈ្មោះថាជាមនុស្សខ្ពង់ខ្ពស់ ជាងអ្នកដែលឈ្នះ ក្នុងសង្គ្រាមនោះ ។

ខ្លួនឯងដែលឈ្នះហើយ ប្រសើរជាង ចំណែកពួកសត្វក្រៅពីនេះដែលគេឈ្នះហើយ មិនប្រសើរឡើយ កាលបើបុរសមានខ្លួនទូន្មានហើយ ជាអ្នកប្រព្រឹត្តសង្រួមជានិច្ច ទេវតា គន្ធព្វ មារ ព្រមទាំងព្រហ្ម មិនគប្បីធ្វើទុរដំនេះ របស់សត្វមានសភាពដូច្នោះ ឲ្យត្រឡប់ចាញ់វិញបានឡើយ ។

អ្នកណា បូជា(លោកិយមហាជន) ដោយទ្រព្យមួយពាន់រាល់ខែ ៗ អស់ ១ រយឆ្នាំគត់ ចំណែកអ្នកណា គប្បីបូជាចំពោះបុគ្គលដែលមានខ្លួនអប់រំហើយ តែ ១ នាក់ សូម្បីតែមួយរំពេច ការបូជានោះឯង ប្រសើរជាងការបូជារបស់អ្នកដែលបូជាអស់ ១ រយឆ្នាំនោះ ការបូជាអស់ ១០០ ឆ្នាំ មិនប្រសើរឡើយ ។

ជនណា បម្រើភ្លើងក្នុងព្រៃអស់ ១០០ឆ្នាំ ចំណែកអ្នកណាបូជាលោកដែលមានខ្លួនអប់រំហើយ តែ ១ នាក់ សូម្បីមួយរំពេច ការបូជានោះឯង ប្រសើរជាងការបូជារបស់ជននោះ ការបូជាអស់ ១០០ ឆ្នាំ មិនប្រសើរឡើយ ។

ធម្មបទគាថាយ អដ្ឋមេ សវោស្សរត្តេ

យស្ស្ដិញ្ចិ យិដ្ឋំ វ ហុតំ[1] វ លោកេ
សំវច្ឆរំ យជេថ បុញ្ញាបេក្ខោ[2]
សព្ពំបិ តំ ន ចតុភាគមេតិ
អភិវាទនា ឧជុគតេសុ សេយ្យោ ។

អភិវាទនសីលិស្ស និច្ចំ វុឌ្ឍាបចាយិនោ
ចត្តារោ ធម្មា វឌ្ឍន្តិ អាយុ វណ្ណោ សុខំ ពលំ ។

យោ ច វស្សសតំ ជីវេ ទុស្សីលោ អសមាហិតោ
ឯកាហំ ជីវិតំ សេយ្យោ សីលវន្តស្ស ឈាយិនោ ។

យោ ច វស្សសតំ ជីវេ ទុប្បញ្ញោ អសមាហិតោ
ឯកាហំ ជីវិតំ សេយ្យោ បញ្ញវន្តស្ស ឈាយិនោ ។

យោ ច វស្សសតំ ជីវេ កុសីតោ ហីនវីរិយោ
ឯកាហំ ជីវិតំ សេយ្យោ វីរិយំ អារភតោ ទឡ្ហំ ។

---

១ ម. យិដ្ឋញ្ហុតញ្ច ។ ២ ម. បុញ្ញាបេក្ខោ ។

ធម្មបទគាថា សហស្សវគ្គទី ៨

បុគ្គលអ្នកប្រាថ្នាបុណ្យ គប្បីបូជាគ្រឿងសក្ការបូជា ធំតួចណាមួយ
ក្នុងលោកអស់មួយឆ្នាំ ការបូជាខាងអស់នោះឯង រមែងមិនដល់
នូវចំណែកទី ៤ នៃការអភិវាទន៍ ចំពោះលោកខាងឆ្ពាយ ដែល
ប្រព្រឹត្តត្រង់ហើយ ប្រសើរជាង ។

ធម៌ ៤ ប្រការគឺ អាយុ ១ វណ្ណៈ ១ សុខៈ ១ ពលៈ ១ រមែងចំរើនដល់
អ្នកដែលមានសេចក្តីនុនតាយថ្វាយបង្គំជាប្រក្រតី មានសេចក្តីគោត
ក្រែង ដល់បុគ្គលដែលចំរើនជាដរាទ្ធ អស់កាលជានិច្ច ។

បុគ្គលណា រស់នៅមួយរយឆ្នាំ ជាមនុស្សទ្រុស្តសីល មានចិត្ត
មិនបានដម្កល់ខ្ជាប់ ការរស់នៅតែមួយថ្ងៃ របស់លោកដែលមាន
សីលមានការពិនិត្យពិចារណា ជាប្រក្រតី ប្រសើរជាង ។

បុគ្គលណា រស់នៅមួយរយឆ្នាំ ជាមនុស្សមិនមានប្រាជ្ញា មានចិត្ត
មិនបានដម្កល់ខ្ជាប់ ការរស់នៅតែមួយថ្ងៃ របស់លោកដែលមាន
ប្រាជ្ញា មានការពិនិត្យពិចារណា ជាប្រក្រតី ប្រសើរជាង ។

បុគ្គលណា រស់នៅមួយរយឆ្នាំ ជាមនុស្សមានចិត្តធ្លាលឆ្ងល់ ក្នុង
អកុសលវិតក្កៈ មានព្យាយាមថោកថយ ការរស់នៅសូម្បីតែមួយថ្ងៃ
របស់លោកដែលប្រារព្ធសេចក្តីព្យាយាមមាំមួន ប្រសើរជាង ។

យោ ច វស្សសតំ ជីវេ អបស្សំ ទ្ធយ្ហយំ[1]

ឯកាហំ ជីវិតំ សេយ្យោ បស្សតោ ទ្ធយ្ហយំ ។

យោ ច វស្សសតំ ជីវេ អបស្សំ អមតំ បទំ

ឯកាហំ ជីវិតំ សេយ្យោ បស្សតោ អមតំ បទំ ។

យោ ច វស្សសតំ ជីវេ អបស្សំ ធម្មមុត្តមំ

ឯកាហំ ជីវិតំ សេយ្យោ បស្សតោ ធម្មមុត្តមំ ។

សហស្សវគ្គោ អដ្ឋមោ ។

ធម្មបទគាថាយ នវមោ បាបវគ្គោ

[១៧]អភិត្ថរេថ កល្យាណេ បាបា ចិត្តំ និវារយេ

(២)

ទន្ធំ ហិ ករតោ បុញ្ញំ បាបស្មឹំ រមតី មនោ ។

បាបញ្ច បុរិសោ កយិរា ន នំ កយិរា បុនប្បុនំ

ន តម្ហិ ឆន្ទំ កយិរាថ ទុក្ខោ បាបស្ស ឧច្ចយោ ។

---

១ ឧទយ្ហយំ ។ ២ ឆ. ម. កយេរ ។

បុគ្គលណា រស់នៅមួយរយឆ្នាំ ឃើញការកើតឡើងនឹងការវិនាសទៅ
ការរស់នៅ សូម្បីតែមួយថ្ងៃ របស់លោកដែលឃើញការកើតឡើង
នឹងការវិនាសទៅ ប្រសើរជាង ។

បុគ្គលណា រស់នៅមួយរយឆ្នាំ មិនឃើញផ្លូវព្រះនិព្វាន ការរស់នៅ
សូម្បីតែមួយថ្ងៃ របស់លោកអ្នកឃើញផ្លូវព្រះនិព្វាន ប្រសើរជាង ។

បុគ្គលណា រស់នៅមួយរយឆ្នាំ មិនឃើញធម៌ដ៏ខ្ពង់ខ្ពស់ ការរស់នៅ
សូម្បីតែមួយថ្ងៃ របស់លោកអ្នកឃើញធម៌ដ៏ខ្ពង់ខ្ពស់ ប្រសើរជាង ។

ចប់ សហស្សវគ្គទី ៨ ។

ធម្មបទគាថា បាបវគ្គទី ៩

(១៩) បុគ្គលគួរប្រញាប់ប្រញាល់ធ្វើអំពើល្អ គួរឃាត់ចិត្តចាកបាប
ព្រោះថា កាលបើបុគ្គលធ្វើបុណ្យយឺតយូរ ចិត្តរមែងត្រេកអរក្នុងបាប ។
បើបុរសធ្វើបាប កុំធ្វើបាបនោះរឿយ ។ ឡើយ កុំគប្បីធ្វើសេចក្តី
ពេញចិត្ត ក្នុងបាបនោះ (ព្រោះថា) ការសន្សំបាប តែងនាំ
សេចក្តីទុក្ខមកឲ្យ ។

បុញ្ញញ្ច បុរិសោ តាយំ តាយំ តាយំ បុនប្បុនំ

តម្ហិ ឆន្ទំ តាយំ ៥ សុខោ បុញ្ញស្ស ឧច្ចយោ ។

ចាតោបិ បស្សតី ភទ្រំ យោវ ចាបំ ឯ បច្ចតិ

យទា ច បច្ចតី ចាបំ អថ(ចាចោ)ចាចានិ បស្សតិ ។

ភទ្រោបិ បស្សតី ចាបំ យោវ ភទ្រំ ឯ បច្ចតិ

យទា ច បច្ចតី ភទ្រំ អថ(ភទ្រោ)ភទ្រានិ បស្សតិ ។

មាវមញ្ញេ៥(១)ចាបស្ស ឯ មន្តំ(២)អាគមិស្សតិ

ឧទពិន្ទុនិចាតេន ឧទភុម្ភោបិ បូរតិ

អាបូរតិ ពាលោ ចាបស្ស(៣) ថោកំ ថោកំបិ អាចិនំ ។

មាវមញ្ញេ បុញ្ញស្ស ឯ មន្តំ អាគមិស្សតិ

ឧទពិន្ទុនិចាតេន ឧទភុម្ភោបិ បូរតិ

អាបូរតិ ធីរោ បុញ្ញស្ស ថោកំ ថោកំបិ អាចិនំ ។

---

១ ឧ· មាបុញ្ញមញ្ញេ ។ ២ ឧ· មន្តំ ។ ម· មន្តំ ។ ៣ ឧ· ពាលោ បូរតិ ចាបស្ស ។ កត្ថចិ ភោត្តុកេ បូរតិ ពាលោ ចាបស្សតិ ចាហោ ទំស្សតិ ។

បើបុរសធ្វើបុណ្យ គួរធ្វើបុណ្យនោះឲ្យរឿយ។ គួរធ្វើសេចក្តីពេញចិត្ត ក្នុងបុណ្យនោះ (ព្រោះថា) ការសន្សំបុណ្យ តែងនាំសេចក្តីសុខមកឲ្យ ។

បាប មិនទាន់ឲ្យផលត្រឹមណា មនុស្សឃើញបាប ក៏នៅឃើញតែសេចក្តីចំរើនត្រឹមណោះ លុះកាលណា បាបឲ្យផល មនុស្សឃើញបាប ទើបឃើញបាប ក្នុងកាលនោះ ។

អំពើល្អ មិនទាន់ឲ្យផលត្រឹមណា មនុស្សល្អ នៅឃើញតែបាបត្រឹមណោះ លុះកាលណា អំពើល្អឲ្យផល មនុស្សល្អ ទើបឃើញល្អក្នុងកាលនោះ ។

បុគ្គល មិនគួរមើលងាយបាបថា មានប្រមាណតិច នឹងមិនឲ្យផលដូច្នេះឡើយ ប្រៀបដូចភ្នូមទឹក រមែងពេញបានដោយដំណក់ទឹកដែលធ្លាក់ចុះ យ៉ាងណា បុគ្គលពាល តាលសន្សំបាប សូម្បីបន្តិចបន្តួច។ គង់តែពេញបានដោយបាប យ៉ាងនោះដែរ ។

បុគ្គល មិនគួរមើលងាយបុណ្យថា មានប្រមាណតិច នឹងមិនឲ្យផលដូច្នេះឡើយ ប្រៀបដូចភ្នូមទឹក រមែងពេញបានដោយដំណក់ទឹកដែលធ្លាក់ចុះ យ៉ាងណា អ្នកមានប្រាជ្ញា តាលសន្សំបុណ្យបន្តិចបន្តួច ។ គង់តែពេញបានដោយបុណ្យ យ៉ាងនោះ ។

ឯណិជោវ ភយំ មគ្គំ អប្បសទ្ធោ មហាធនោ
វិសំ ជីវិតុកាមោវ ចាចាឯ បរិវជ្ជយេ ។
ចាណិម្ហិ ចេ វណោ នាស្ស ហរេយ្យ ចាណិនា វិសំ
នាព្ភវំ(១) វិសមន្វេតិ នត្ថិ ចាបំ អកុព្ភតោ ។

យោ អប្បទុដ្ឋស្ស នរស្ស ទុស្សតិ
សុទ្ធស្ស បោសស្ស អនង្គណស្ស
តមេវ ពាលំ បច្ចេតិ ចាបំ
សុខុមោ រជោ បដិវាតំវ ខិត្តោ ។

គព្ភមេកេ ឧប្បជ្ជន្តិ និរយំ ចាបកម្មិនោ
សគ្គំ សុគតិនោ យន្តិ បរិនិព្ពន្តិ អនាសវា ។

ឯ អន្តលិក្ខេ ឯ សមុទ្ទមជ្ឈេ
ឯ បព្ភតានំ វិវរំ បវិសំ(២)
ឯ វិជ្ជតី(៣) សោ ជគតិប្បទេសោ
យត្រដ្ឋិតោ(៤) មុច្ចេយ្យ(៥) ចាបកម្មា ។

---

១ ម. នាវណ ។ ២ ឧ. ម. បវិស្ស ។ ៣ ម. វិជ្ជតិ ។ វិជ្ជតេតំ បដិ ឯាបៅ ។ ៤ ប. យត្តដ្ឋិតោ ។ ៥ ឧ. បុញ្ញេយ្យ ។

បុគ្គលគួរចៀសវាងបាបទាំងឡាយ ឲ្យដូចពាណិជ ដែលមានទ្រព្យច្រើន តែមានគ្នាតិច ចៀសវាងផ្លូវគួរខ្លាច ឬដូចជាបុរសប្រាថ្នាវស់នៅ ចៀសវាងថ្នាំពិសដូច្នោះដែរ ។

បើដំបៅមិនមានកន្ទក់ជាតដៃទេ បុគ្គលគប្បីនាំយកថ្នាំពិសដោយជាតដៃ ថ្នាំពិស តែងមិនជ្រាបចូលទៅកាន់ជាតដៃដែលគ្មានដំបៅ យ៉ាងណា បាប រមែងមិនមានដល់បុគ្គលអ្នកមិនធ្វើ យ៉ាងនោះដែរ ។

បុគ្គលណា ប្រទូស្តចំពោះអ្នកមិនប្រទុស្តតប ជាសត្វស្អាត មិនមានតិលេសដូចជាទឹកល្អ បាប រមែងត្រឡប់មកកាន់បុគ្គលពាលនោះវិញដូចធូលីល្អិត ដែលបុគ្គលបាចសាបទៅកាន់ទីច្រាសខ្យល់ ។

ជនពួកខ្លះ កើតក្នុងគភ៌មនុស្ស ពួកអ្នកមានអំពើអាក្រក់ ទៅកាន់នរក ពួកអ្នកមានគតិល្អ ទៅកាន់ឋានសួគ៌ ពួកអ្នកមិនមានអាសវៈ បរិនិព្វាន ។

បុគ្គលអ្នកធ្វើបាបកម្មហើយ ទោះបីចូលទៅឰដ៏អាកាស ក្នុងគណ្ឋាសសមុទ្រ កាន់ចន្ទោះភ្នំទាំងឡាយ ក៏មិនគប្បីរួចចាកបាបកម្ម ព្រោះប្រទេសលើផែនដី ដែលបុគ្គលបិតទៅហើយ គប្បីរួចចាកបាបកម្មបាន នោះមិនដែលមានឡើយ ។

ធម្មបទគាថាយ ទុសមោ ទណ្ឌវគ្គោ

ន អន្តលិក្ខេ ន សមុទ្ទមជ្ឈេ

ន បព្ពតានំ វិវរំ បវិស្ស

ន វិជ្ជតិ សោ ជគតប្បទេសោ

យត្ថដ្ឋិតំ នប្បសហេយ្យ[1] មច្ចុ ។

ចាបវគ្គោ ទុតិយោ ។

ធម្មបទគាថាយ ទុសមោ ទណ្ឌវគ្គោ

[២០]សព្ពេ តសន្តិ ទណ្ឌស្ស សព្ពេ ភាយន្តិ មច្ចុនោ

អត្តានំ ឧបមំ កត្វា ន ហនេយ្យ ន ឃាតយេ ។

សព្ពេ តសន្តិ ទណ្ឌស្ស សព្ពេសំ ជីវិតំ បិយំ

អត្តានំ ឧបមំ កត្វា ន ហនេយ្យ ន ឃាតយេ ។

សុខកាមានិ ភូតានិ យោ ទណ្ឌេន វិហឹសតិ

អត្តនោ សុខមេសានោ បេច្ច សោ ន លភតេ សុខំ ។

---

១ ម. នប្បសហេយ្យ ។

បុគ្គលទៅ ឰដ៏អាកាស ក្នុងកណ្តាលសមុទ្រ គាន់បន្ទោះនៃភ្នំ ទាំងឡាយ ក៏មិនរួចចាកសេចក្តីស្លាប់បាន ព្រោះប្រទេសលើផែនដី ដែលបុគ្គលឋិតនៅហើយ ៖សេចក្តីស្លាប់គ្របសង្កត់មិនបាននោះ មិនដែលមានឡើយ ។

ចប់ ឃាវគ្គទី ៩ ។

ធម្មបទគាថា ទណ្ឌវគ្គទី ១០

[៤០] សត្វទាំងឡាយគ្រប់ប្រាណ តែងតក់ស្លុតនឹងអាជ្ញា សត្វទាំងឡាយ តែងខ្លាចចំពោះសេចក្តីស្លាប់គ្រប់ៗរូប បុគ្គលគួរធ្វើខ្លួនឲ្យជាឧបមា ហើយមិនគួរប្រហារ ដោយខ្លួនឯង មិនគួរប្រើគេឲ្យប្រហារឡើយ ។

សត្វទាំងឡាយគ្រប់ប្រភេទ តែងតក់ស្លុតនឹងអាជ្ញា (ព្រោះថា) ជីវិតជាទីស្រឡាញ់របស់សត្វទាំងពួង បុគ្គលគួរធ្វើខ្លួនឲ្យជាឧបមា ហើយមិនគួរប្រហារ ដោយខ្លួនឯង មិនគួរប្រើគេឲ្យប្រហារឡើយ ។

ជនណា ស្វែងរកសេចក្តីសុខ ដើម្បីខ្លួន តែបៀតបៀនសត្វទាំងឡាយ ដែលប្រាថ្នាសេចក្តីសុខ ដោយអាជ្ញា ជននោះលះលោកនេះទៅហើយ នឹងមិនបានសេចក្តីសុខឡើយ ។

សុខកាមានិ ភូតានិ យោ ទណ្ឌេន ន ហឹំសតិ
អត្តនោ សុខមេសានោ បេច្ច សោ លភតេ សុខំ ។
មាភវេច ឥរុសំ ភញ្ជិ[1] វុត្តា បដិវទេយ្យុ[2] តំ
ទុក្ខា ហិ សារម្ភកថា បដិទណ្ឌា ផុសេយ្យុ[3]តំ ។
សចេ នេរេសិ អត្តានំ ភំសោ ឧបហតោ យថា
ឯស បត្តោសិ និព្ពានំ សារម្ភោ[4] តេ ន វិជ្ជតិ ។
យថា ទណ្ឌេន គោចាលោ គាវោ ចាវេតិ[5] គោចរំ
ឯវំ ជរា ច មច្ចុ ច អាយុំ ចាវេន្តិ ចាណិនំ ។
អថ ចាចានិ កម្មានិ ភរំ ពាលោ ន ពុជ្ឈតិ
សេហិ ភាវេហិ ទុម្មេធោ អគ្គិទឌ្ឍោវ តប្បតិ ។

---

១ ម. ភិញ្ញំ ។ ២ ម. បដិវទេយ្យុំ ។ ៣ ម. ផុសេយ្យុ ។ ៤ ម. សារម្ភោ ។
៥ ឱ. ឋបេតិ ។

ជនណា សែ្វងរកសេចក្តីសុខ ដើម្បីខ្លួន តែមិនបៀតបៀនសត្វពាំង
ឲ្យាយ អ្នកដែលប្រាថ្នាសេចក្តីសុខ ដោយអាជ្ញា ជននោះលះលោក
នេះទៅហើយ រមែងបាននសេចក្តីសុខ ។

អ្នកកុំនិយាយពាក្យអាក្រក់នឹងអ្នកណាមួយឡើយ ជនពាំងឲ្យាយដែល
អ្នកស្តីថាឲ្យហើយ គេគប្បីស្តីថាតបមកអ្នកវិញ ព្រោះថា ការពោល
ពាក្យប្រណាំងប្រជែង ជាហេតុនាំឲ្យកើតទុក្ខ ការតស៊ូពាំងឲ្យាយ
គប្បីប៉ះពាល់នូវអ្នក ។ បើអ្នកធ្វើខ្លួនមិនឲ្យញាប់ញ័រ ដូចគាំងដែល
ចៀរមាត់ចេញហើយ (រមែងមិនលាន់ឮសូរ) ដូច្នោះ អ្នកនុ៎ះជាបុគ្គល
ដល់នូវព្រះនិព្វាន ការប្រណាំងប្រជែង មិនមានដល់អ្នក ។

គង្វាលគោ រមែងកៀនគោទៅកាន់ទីគោចរដោយអាជ្ញា ដូចម្តេចមិញ
ជរានឹងមច្ចុ តែងកៀនអាយុរបស់សត្វពាំងឲ្យាយ ដូច្នោះឯង ។

បុគ្គលមិនមានប្រាជ្ញា កាលធ្វើអំពើអាក្រក់ រមែងមិនភ្ញាក់ខ្លួន លុះ
កាលជាខាងក្រោយ ទើបក្តៅក្រហាយ ដោយសារកម្មរបស់ខ្លួន
ដូចត្រូវភ្លើងឆេះ ។

យោ ឧដ្ឋានវតោ សិយា អប្បមុដ្ឋស្ស នុសฺสតិ
ឧសฺสฏฺឋសงฺกปฺปสฺส ธมฺมชีวิโน ปมตฺตจาริโน
ยสោ ภิยฺโย ปวฑฺฒติ สณฺฐหติ ปุริโส ยถา
ปถวึ สมาย อตฺตโน อุปฏฺฐาเปติ(๑) ปณฺฑิโต
ตถา หิ ตาทิสสฺเสว ปุคฺคลสฺส ปชาปติ
ปถวี ปิยา ภวติ ยถา ปิยา ปุตฺตา ปชาปติ
ปริกฺขยา(๒) ธนสฺส ปณฺฑิโต
ปริกฺขยา(๓) ยโสสฺส ปณฺฑิโต
อปฺปมาทรโต ภิกฺขุ อปฺปมาเท ภยทสฺสิวา
สญฺโญชนานิ ถูลานิ ฑหนฺโต(๔) อคฺคิ ภพฺพโว
อปฺปมาทรโต ภิกฺขุ อปฺปมาเท ภยทสฺสิวา
อภพฺโพ ปริหานาย นิพฺพานสฺเสว สนฺติเก ๚

ยสฺส ยสฺสาปิ ทิสฺสนฺติ ปาปกา ทุกฺกฏา กถา
วาจา ตสฺส ปหาตพฺพา ปุน เอวนฺติ เม สุตนฺติ
ยสฺส เจตา สมุจฺเฉทา ปหีนา มูลพนฺธนา
ส เว วนฺตกสาวสฺส สปฺปุริสาติ วุจฺจติ
ยสฺส ปาปานิ กมฺมานิ กายวาจามนานิ วา
ปฏิจฺฉาทนตฺถาย ปณฺฑิตา ปาปุณนฺติ ตนฺติ
ยสฺส ปาปานิ กมฺมานิ กายวาจามนานิ วา
ปฏิจฺฉาทนตฺถาย ปณฺฑิตา ปาปุณนฺติ ตนฺติ
ยสฺส ปาปานิ กมฺมานิ กายวาจามนานิ วา
ปฏิจฺฉาทนตฺถาย ปณฺฑิตา ปาปุณนฺติ ตนฺติ
ยสฺส ปาปานิ กมฺมานิ กายวาจามนานิ วา
ปฏิจฺฉาทนตฺถาย ปณฺฑิตา ปาปุณนฺติ ตนฺติ

---

๑ ม. ចិត្តវ្ហេបញ្ច ។ ๒ ម. បរិក្ខយេញ្ច ។ ๓ ម. ភោគេញ្ច ។ ๔ ម. ឌយ្ហតិ ។ ๕ ម. បបដ្ឋតិ ។

បុគ្គលណា ប្រទូស្តដោយអាជ្ញា ចំពោះបុគ្គលគាំងឡាយ ដែលមិនមានអាជ្ញា មិនប្រទូស្ត បុគ្គលនោះ រមែងដល់នូវហេតុនៃសេចក្តីទុក្ខណាមួយ ក្នុងហេតុ ១០យ៉ាង ដោយភាន់ហាន់ គឺគប្បីដល់នូវវេទនាដ៏អាក្រក់ ១ សេចក្តីវិនាសទ្រព្យ ១ បែកធ្លាយសរីរៈ ១ អាពាធជាទម្ងន់ ១ ក្រឡាកចិត្ត (ឆ្កួត) ១ រឹបជាន់អំពីស្តេច ១ ពោលពាក្យបង្កាច់ដ៏អាក្រក់ ១ អស់ញាតិសាលី ១ ពុកផុយកោគសម្បត្តិគាំងឡាយ ១ គាំងភ្លើងឆាបឆេះបំផ្លាញនូវផ្ទះ រាល់បុគ្គលនោះ ១ បុគ្គលមិនមានប្រាជ្ញានោះ លុះបែកធ្លាយរាងកាយ រមែងទៅកើត ក្នុងនរក ។ ការប្រព្រឹត្តិអាក្រាតកាយ ទុកសក់ ដេកលើកក់ មិនបរិភោគថ្ងាយដេកលើផែនដី ប្រឡាក់ខ្លួនដោយធូលី ព្យាយាមអង្គុយប្រហោង មិនដម្រះសភ្លឺដែលមិនទាន់ឆ្ងល់ផុតសេចក្តីសង្ស័យបានទេ ។ បើបុគ្គលណាមានខ្លួនប្រដាប់ស្អិតស្អាងហើយ (ដោយគ្រឿងអម្ពរ) តែគប្បីប្រព្រឹត្តស្មើ អ្នកសង្កប់រម្ងាប់ ទូន្មាន (ឥន្ទ្រិយ) ជាបុគ្គលទៀង (ចំពោះមគ្គផល) អ្នកប្រព្រឹត្តធម៌ដ៏ប្រសើរ ទម្លាក់ចោលនូវអាជ្ញាក្នុងសត្វទាំងពួងចេញហើយ បុគ្គលនោះ ហៅថា ព្រាហ្មណ៍ក៏បាន ថាសមណៈក៏បាន ថាភិក្ខុក៏បាន ។

ហិរិនិសេធោ[1] បុរិសោ កោចិ លោកស្មិំ[2] វិជ្ជតិ
យោ និទ្ទំ អបពោធេតិ[3] អស្សទ្ធោ កុសលាមិវ ។

អស្សទ្ធោ យថា កុន្នោ កុសានិវិជ្ជោ
អតាមិនោ សំវេគិនោ កាយ[4]
សទ្ធាយ សីលេន ច វីរិយេន ច
សមាធិនា ធម្មវិនិច្ឆយេន ច
សម្បន្នវិជ្ជាចរណា បតិស្សតា
បហស្សថ[5] ទុក្ខមិទំ អនប្បកំ ។

(៦) (៧)
ខុទកំ ហិ ទយន្តិ នេត្តិកា ខុសុកាកា ទមយន្តិ តេជនំ
ទារុំ ទមយន្តិ[8] តច្ឆកា អត្តានំ ទមយន្តិ សុព្វតា ។

ទណ្ឌវគ្គោ ទុតិយោ ។

ធម្មបទគាថាយ ឯកាទសមោ ជរាវគ្គោ

[២០] កោ នុ ហាសោ កិមានន្ទោ និច្ចំ បជ្ជលិតេ សតិ
អន្ធការេន ឱនទ្ធា បទីបំ ន គវេសថ[9] ។

---

១ ខ.ម. ហិរីនិសេធោ ។ ២ ម. លោកស្មិំ ។ ៣ ម. ខ. សោ និទ្ទំ អប្ប-
ពោធតិ ។ ម. យោ និទ្ទំ អប្បពោធេសិ ។ ៤ ម. ភវត្ថ ។ ៥ ម. ឯហិស្សថ ។
៦ ម,ខ,ទកញ្ហិ ។ ៧-៨ ម. ទមយន្តិ ។ ៩ ខ. គវេសថ ។

បុរសអ្នកកំចាត់បង់នូវអកុសលវិតក្កៈ ដោយសេចក្តីខ្មាសចាប មានតិចក្នុងលោក បុគ្គលណាបន្ទោបង់នូវតារជៈតិចតួច ដូចសេះល្អខ្ចាប ព្រោះរំពាត់ បុរសនោះ រកបានដោយក្រ ក្នុងលោក ។

សេះល្អ ដែលនាយសារថីទូន្មាន ដោយរំពាត់ តក់ស្លុតយ៉ាងណា អ្នកចាំងឡាយ ចូរជាបុគ្គលមានព្យាយាម មានសេចក្តីតក់ស្លុតយ៉ាងនោះឯង បើអ្នកចាំងឡាយ ប្រកបព្រមដោយសទ្ធាផង សីលផង ព្យាយាមផង សមាធិផង ធម្មវិនិច្ឆ័យផង ជាអ្នកមានវិជ្ជានិងចរណៈដ៏បរិបូណ៌ មានស្មារតីដ៏តស៊ូមាំ រមែងលះបង់ទុក្ខ មានប្រមាណច្រើននេះ មិនខាន ។

ធម្មតាអ្នកបង្វរ តែងបង្វរទឹក អ្នកធ្វើព្រួញ តែងពត់ព្រួញ (ឲ្យត្រង់) អ្នកចាំង តែងចាំងឈើ អ្នកមានវត្តល្អ តែងទូន្មានខ្លួន ។

ចប់ វណ្ណវគ្គទី ១០ ។

ធម្មបទគាថា ជរាវគ្គទី ១១

[៤១] កាលបើលោកសន្ធិវាស ត្រូវភ្លើងមានពាគ ជាដើម ឆេះទ្រលោមជានិច្ច ម្តេចក៏សើច ម្តេចក៏ត្រេកត្រអាល អ្នកចាំងឡាយត្រូវងងឹតគឺអវិជ្ជារួបរឹតហើយ (ម្តេចឡើយ) ក៏មិនស្វែងរកប្រទីបគឺប្រាជ្ញា ។

ធម្មបទគាថាយ ឯកាទសមោ ជិណវគ្គោ

បសវ្ហ ចិត្តកតំ តិម្ពំ អរុកាយំ សមុស្សិតំ

អាតុរំ ពហុសង្កប្បំ យស្ស នត្ថិ ធុវំ ឋិតិ(๑)។

បរិជិណ្ណមិទំ រូបំ ភោគនិធ្ហំ បភង្គុណំ

ភិជ្ជតិ ហ្វតិ សន្ទេហោ មរណន្តំ ហិ ជីវិតំ ។

យានិមានិ អបត្ថានិ អលាឞ្ហេវ សារទេ

កាបោតកានិ អដ្ឋីនិ តានិ និស្សាយ កា រតិ ។

អដ្ឋីនំ នគរំ កតំ មំសលោហិតលេបនំ

យត្ថ ជរា ច មច្ចុ ច មានោ មក្ខោ ច ឱហិតោ។

ជីវន្តិ វេ កវរជា សុចិត្តា

អថោ សរីរម្ហិ ជរំ ឧបេតិ

សតញ្ហ ធម្មោ ន ជរំ ឧបេតិ

សន្តោ ហវេ សព្ភិ បវេទយន្តិ ។

ធម្មបទគាថា ជរាវគ្គទី ១១

អត្តភាពណា មិនទៀងទាត់ ឋិតថេរ អ្នកចូរមើលអត្តភាព (នោះ) ដែលកុសលាកុសលកម្ម ធ្វើរឹបគ្រហើយ ជាកាយពាសពេញ ដោយដំបៅ ដែលឆ្អឹងបីរយតំណាត់ ផ្គុំគ្នាហើយ ជាអត្តភាពក្តៅក្រហាយ ជានិច្ច ជាទីរំពឹងគ្រិះរិះរបស់ជនច្រើនគ្នា ។

រូបនេះគ្រាំគ្រាអស់ហើយ ជាទីសំណាក់នៃរោគ ជារបស់ពុកផុយ កងកាយជារបស់ស្អុយ (នេះ) តែងរបែកធ្លាយទៅវិញ ព្រោះថាជីវិតមានសេចក្តីស្លាប់ជាទីបំផុត ។

ឆ្អឹងទាំងឡាយណា មានសម្បុរដូចសត្វព្រាប ដែលគេចោលហើយជូចផ្លែឃ្លោកក្នុងសរទកាល សេចក្តីត្រេកអរអ្វីហ្ន៎ (របស់អ្នកទាំងឡាយ) ព្រោះតែឃើញឆ្អឹងទាំងឡាយនោះ ។

សេចក្តីគ្រាំគ្រា សេចក្តីស្លាប់ សេចក្តីប្រកាន់ខ្លួនធំ សេចក្តីលុបគុណប្រជុំចុះកងសរីរៈណា (សរីរៈនោះ) ដែលកុសលាកុសលកម្មធ្វើហើយឲ្យជានគររបស់ឆ្អឹងទាំងឡាយ ជាគ្រឿងប្រឡាក់ដោយសាច់ឈាម ។ ពជរថទាំងឡាយ ដ៏រឹបគ្រស្អុយ រមែងគ្រាំគ្រា សូម្បីសរីរៈតំណាលខ្លួនូវសេចក្តីគ្រាំគ្រាដូចគ្នា ទើបឯធម៌ របស់សប្បុរសទាំងឡាយ មិនដល់នូវសេចក្តីគ្រាំគ្រា (ដូច្នោះ) ទេ សប្បុរសទាំងឡាយ តែងនិយាយឲ្យពួកសប្បុរសផងគ្នាដឹងបាន ។

អប្បស្សុតាយំ បុរិសោ ពលិពទ្ទោវ ជីរតិ
មំសានិ តស្ស វឌ្ឍន្តិ បញ្ញា តស្ស ន វឌ្ឍតិ ។

អនេកជាតិសំសារំ សន្ធាវិស្សំ អនិព្ពិសំ
គហការំ[1] គវេសន្តោ ទុក្ខា ជាតិ បុនប្បុនំ ។

គហការក ទិដ្ឋោសិ បុន គេហំ ន កាហសិ
សព្ពា តេ ផាសុកា ភគ្គា គហកូដំ វិសង្ខតំ
វិសង្ខារគតំ ចិត្តំ តណ្ហានំ ខយមជ្ឈគា ។

អចរិត្វា ព្រហ្មចរិយំ អលទ្ធា យោព្វនេ ធនំ
ជិណ្ណកោញ្ចាវ ឈាយន្តិ ខីណមច្ឆេវ បល្លលេ ។

អចរិត្វា ព្រហ្មចរិយំ អលទ្ធា យោព្វនេ ធនំ
សេន្តិ ចាបាតិខីណាវ បុរាណានិ អនុត្ថុនំ ។

ដីភវគ្គោ ឯកាទសមោ ។

---

១ ម. គហការ ។

ប្រុសអ្នកមិនមានការចេះដឹងនេះ តែងចាស់ (ឥតរំពៃ) ដូចគោបរិភោគស្មៅរបស់វា តែងបំរើនឲ្បឹង តែប្រាជ្ញារបស់វាមិនចំរើនឲ្យឡើយ ។

កាលតថាគតមិនទាន់ឃើញដួងប្រទីប (ពោធិញ្ញាណវិលាតេ) សូវសែងរកជាងផ្ទះគឺតណ្ហា អ្នកធ្វើផ្ទះគឺអត្តភាព តំអន្លាលទៀតាន់សង្សារវដ្ត មានជាតិដ៏ច្រើន សេចក្តីកើត ជាទុក្ខរឿយ ។ ។

នែជាងផ្ទះ អ្នកឯងនឹងធ្វើផ្ទះគឺអត្តភាព តថាគតឃើញហើយ អ្នកនឹងធ្វើផ្ទះ(របស់តថាគត)ទៀត មិនបានឡើយ ឆ្អឹងជំនីរគឺតិលេសរបស់អ្នកទាំងអស់តថាគតកាប់បំបាក់អស់ហើយ ដម្បូលផ្ទះគឺអវិជ្ជា តថាគតកំចាត់ចោលហើយ ចិត្តរបស់តថាគត ដល់ព្រះនិព្វានដែលមានសង្ខារប្រាសហើយ តថាគត បានដល់ធម៌ជាគ្រឿងក្សយតណ្ហាទាំងឡាយហើយ ។

ជនពាលទាំងឡាយ មិនប្រព្រឹត្តព្រហ្មចរិយធម៌ មិនបានទ្រព្យ ក្នុងកាលខ្លះនៅដាក់ឈ្មោះក្រមុំ រមែងសញ្ជប់សញ្ជឹង ដូចសត្វក្រៀលចាស់ សំកុកនៅ ក្នុងកក់ដែលអស់ត្រីហើយ ។

ជនពាលទាំងឡាយ មិនប្រព្រឹត្តព្រហ្មចរិយធម៌ មិនបានទ្រព្យក្នុងកាលខ្លះនៅដាក់ឈ្មោះក្រមុំ រមែងដេកថ្ងូរ សោកស្តាយទ្រព្យចាស់ទាំងឡាយ ដូចព្រួញដែលផុតចាកខ្សែបន្ទោរដូច្នោះ ។

ចប់ ជរាវគ្គ ទី ១១ ។

ធម្មបទគាថាយ ទ្វាទសមោ អត្ថវគ្គោ

[២២] អត្តានញ្ចេ បិយំ ញញ្ញា រក្ខេយ្យ នំ សុរក្ខិតំ

តិណ្ណំ អញ្ញតរំ យាមំ បដិជគ្គេយ្យ បណ្ឌិតោ ។

អត្តានមេវ បឋមំ បដិរូបេ និវេសយេ

អថញ្ញមនុសាសេយ្យ ន កិលិស្សេយ្យ បណ្ឌិតោ ។

អត្តានញ្ចេ តថា កយិរ យថញ្ញមនុសាសតិ

សុទន្តោ វត ទមេថ អត្តា ហិ កិរ ទុទ្ទមោ ។

អត្តា ហិ អត្តនោ នាថោ កោ ហិ នាថោ បរោ សិយា

អត្តនា ហិ សុទន្តេន នាថំ លភតិ ទុល្លភំ ។

អត្តនា វ កតំ ទាបំ អត្តជំ[1] អត្តសម្ភវំ

អភិមត្ថតិ ទុម្មេធំ វជិរំ[2] វស្មមយំ[3] មណឺ ។

---

១ អត្រដិន្ទូបិ ជាហេ ។ ២ ខ. វជិរំ វស្មមយំ ។ ប. វម្ហមយំ ។

ធម្មបទគាថា អត្ថវគ្គទី ១២

(៤៦) បេបណ្ឌិតដឹងថា ខ្លួនជាទីស្រឡាញ់ គួរតែរក្សាខ្លួននោះឲ្យល្អ គួរសន្តែងខ្លួនទុកក្នុងវ័យទាំង៣ វ័យណាមួយ ។

បណ្ឌិត គួរដម្កល់ខ្លួនទុក ក្នុងគុណដ៏សមគួរជាមុនសិន ហើយ សឹមប្រៀនប្រដៅអ្នកដទៃ ជាខាងក្រោយ (ឆ្លើយ៉ាងនេះ) នឹងមិនលំបាកឡើយ ។

បុគ្គលប្រៀនប្រដៅអ្នកដទៃ យ៉ាងណា ត្រូវធ្វើខ្លួនឲ្យបាន យ៉ាងនោះដែរ អ្នកដែលទូន្មានខ្លួនល្អហើយ ទើបគួរទូន្មានអ្នកដទៃបាន ព្រោះថា ខ្លួនតម្រូវទូន្មានបានពេកណាស់ ។

ខ្លួនជាទីពឹងរបស់ខ្លួន អ្នកដទៃជាទីពឹងដូចម្តេចបាន ព្រោះបុគ្គលអ្នកមានខ្លួនហ្វឹកហ្វឺនល្អហើយ រមែងបាននូវទីពឹង ដែលគេបានដោយកម្រ ។

ឯបុ កើតអំពីខ្លួន មានខ្លួនជាដែនកើត ដែលខ្លួនធ្វើហើយ តែងញាំញីមនុស្សឥតប្រាជ្ញា ដូចពេជ្រសម្រាប់តាត់កែវមណី ដែលកើតអំពីប៉ុ ដូច្នោះឯង ។

យស្ស អច្ចន្តទុស្សីល្យំ មាលុវា សាលមិវោត្ថតំ
ករោតិ សោ តថត្តានំ[1] យថា នំ ឥច្ឆតី តិសោ ។

សុខការានិ អសាធូនិ អត្ថតោ អហិតានិ ច
យំ វេ[2] ហិតញ្ច សាធុញ្ច តំ វេ បរមទុក្ករំ ។

យោ សាសនំ អរហតំ អរិយានំ ធម្មជីវិនំ
បដិក្កោសតិ ទុម្មេធោ ទិដ្ឋឹ និស្សាយ បាបិកំ

ផលានិ កដ្ឋកស្សេវ[3] អត្តព្យញ្ជាយ[4] ផល្លតិ ។

អត្តនា វ កតំ បាបំ អត្តនា សង្កិលិស្សតិ
អត្តនា អកតំ បាបំ អត្តនា វ វិសុជ្ឈតិ

សុទ្ធិ អសុទ្ធិ បច្ចត្តំ នាញ្ញោ អញ្ញំ វិសោធយេ ។

---

១ ខ. តថាត្តានំ ។ ២ ម. ចេ ។ ៣ ខ ម. កដ្ឋកស្សេវ ។
៤ ម. អត្តឃាតាយ ។

ភាពជាអ្នកទ្រុស្តសីលហួសហេតុ (១) គ្រប់សង្កត់ (ខ្លួនអត្តភាព) របស់បុគ្គលណា ដូចវល្លិ៍ដែលរបូតដើមឈើ បុគ្គលនោះឈ្មោះថាធ្វើខ្លួនឯងឲ្យវិនាស ដូចជាពាក្យអ្នកប្រាថ្នាធ្វើបុគ្គលនោះ ឲ្យវិនាសដូច្នោះ ។

កម្មពាំងឡាយណា មិនល្អផង មិនជាប្រយោជន៍ដល់ខ្លួនផង កម្មពាំងនោះដែលជនពាលធ្វើបានដោយងាយ កម្មណាជាប្រយោជន៍ផង ល្អផង កម្មនោះឯង ដែលជនពាលធ្វើបាន ដោយលំបាក ។

បុគ្គលណាអប្បច្រាជ្ញា អាស្រ័យទិដ្ឋិដ៏លាមក ហាមឃាត់សាសនារបស់ព្រះអរហន្តពាំងឡាយដ៏ប្រសើរ រស់នៅដោយធម៌ ការហាមឃាត់របស់បុគ្គលនោះ រមែងចេញផល ដើម្បីសម្លាប់ខ្លួន ដូចផ្លែឫស្សីដូច្នោះ ។

អ្នកធ្វើបាបខ្លួនឯង នឹងសៅហ្មងខ្លួនឯង អ្នកមិនធ្វើបាបខ្លួនឯង តែងបរិសុទ្ធស្អាតខ្លួនឯង សេចក្តីបរិសុទ្ធិនឹងមិនបរិសុទ្ធិ មានបំពោះខ្លួនអ្នកដទៃទេ នឹងធ្វើអ្នកដទៃ ឲ្យបរិសុទ្ធពុំបានទេ ។

---

១ បើត្រួសាប់តាំងអំពីកើតមកធ្វើតែអកុសលកម្មបថទាំង ១០ បើបញ្ជិតតិត អំពីថ្ងៃដែលបានឧបសម្បន្នមក ត្រូវតែកុហបតិ យ៉ាងនេះឈ្មោះថា ភាពជាអ្នកទ្រុស្តសីលហួសហេតុ ។

អត្តនញ្ចំ បរត្តេន ពហុនាបិ ន ហាបយេ

អត្តនញ្ចមភិញ្ញាយ សទត្ថបសុតោ សិយា ។

អត្តវគ្គោ ទ្វាទសមោ ។

ធម្មបទគាថាយ តេរសមោ លោកវគ្គោ

[៤៣] ហីនំ ធម្មំ ន សេវេយ្យ បមាទេន ន សំវសេ

មិច្ឆាទិដ្ឋិំ ន សេវេយ្យ ន សិយា លោកវឌ្ឍនោ ។

ទុត្តិដ្ឋេ ឧបរមេជ្ជេយ្យ ឆន្ទំ សុចរិតំ ចរេ

ឆន្ទោ ចរេ សុចរិតំ ន តំ ទុច្ចរិតំ ចរេ

ឆន្ទោ ចារំ សុខំ សេតិ អស្មិំ លោកេ បរម្ហិ ច ។

ធម្មបទគាថា លោកវគ្គ ទី ១៣

បុគ្គល កុំគប្បីធ្វើប្រយោជន៍ខ្លួនឲ្យវិនាស ព្រោះប្រយោជន៍របស់អ្នកដទៃ សូម្បីច្រើន បើដឹងច្បាស់នូវប្រយោជន៍របស់ខ្លួនហើយ គប្បីខ្ជាប់ខ្ជួនក្នុងប្រយោជន៍របស់ខ្លួន (នោះ) ។

ចប់ អត្តវគ្គ ទី ១២ ។

ធម្មបទគាថា លោកវគ្គទី ១៣

(២៧) បុគ្គល មិនគួរសេពធម៌ថោកទាប[1] មិនគួរនៅរង់ចាំនូវសេចក្តីប្រមាទ មិនគួរសេពមិច្ឆាទិដ្ឋិ មិនគួរជាមនុស្សច្រើនក្នុងលោក ។ បុគ្គលមិនគួរប្រមាទ ក្នុងដំបូងឡើយ ដែលខ្លួនគប្បីក្រោកឡើងទទួលគប្បីប្រព្រឹត្តធម៌[2]ឲ្យសុចរិត បុគ្គលអ្នកប្រព្រឹត្តធម៌ជាប្រក្រតី រមែងដេកជាសុខ ក្នុងលោកនេះផង ក្នុងលោកខាងមុខផង ។ បុគ្គលគួរប្រព្រឹត្តធម៌ឲ្យសុចរិត មិនគួរប្រព្រឹត្តធម៌នោះឲ្យទុច្ចរិតឡើយ បុគ្គលប្រព្រឹត្តធម៌ជាប្រក្រតី រមែងដេកជាសុខ ក្នុងលោកនេះផង ក្នុងលោកខាងមុខផង ។

---

១ តាមគុណ ៥ ឈ្មោះថា ធម៌ថោកទាប ព្រោះជាធម៌សម្រាប់ដល់ថោកទាប រាប់ចាំងអំពីឧច្ឆិន្នឆន្ទៈដោយជើម គប្បីសេព ចាំងជាធម៌ចាំ បន្តទៅកើតក្នុងទីបាបមានឧបមាដោយជើម ។ ២ ឈ្មោះថា ភិក្ខាចរិយាធម៌ ការសម្រេចនូវឧបនិស្ស័យដើរទៅបិណ្ឌបាតតាមរបៀបច្រកល្ហក ឈ្មោះថា ភិក្ខាចរិយធម៌ ។

យថា បុព្ពុឡកំ បស្សេ យថា បស្សេ បរីចិតំ

ឯវំ លោកំ អវេក្ខន្តំ បច្ចរាជា ន បស្សតិ ។

៧៥ បស្សថិមំ លោកំ ចិត្តំ រាជរថូបមំ

យត្ថ ពាលា វិសីទន្តិ នត្ថិ សង្គោ វិជានតំ ។

យោ ច បុព្ពេ បមជ្ជិត្វា បច្ឆា សោ នប្បមជ្ជតិ

សោមំ លោកំ បភាសេតិ អព្ភា មុត្តោវ ចន្ទិមា ។

យស្ស ចាបំ កតំ កុប្បំ កុសលេន បិថីយតិ

សោមំ លោកំ បភាសេតិ អព្ភា មុត្តោវ ចន្ទិមា ។

អន្ធភូតោ អយំ លោកោ តនុកេត្ថ វិបស្សតិ

សកុណ្ដោ[1] ជាលមុត្តោវ អប្បោ សគ្គាយ គច្ឆតិ ។

---

១ ម. សកុណោ ។

បុគ្គលឃើញពុះទឹកយ៉ាងណា ឃើញព្រេញថ្លុយ៉ាងណា ស្តេច
មុត្យ មិនឃើញអ្នកពិចារណាខន្ធលោកជាដើម យ៉ាងនោះទេ ។
អ្នកចាំងឡាយ ចូរមកមើលលោកនេះ ដ៏ត្រកាល ដូចពាងវែ
ដនពាលចាំងឡាយ រមែងលិចលង់ ក្នុងលោកណា សេចក្តី
ជាប់ដំពាក់ ក្នុងលោកនោះ រមែងមិនមាន ដល់ជនជាបណ្ឌិត
ចាំងឡាយដែលដឹងច្បាស់ទេ ។
បុគ្គលណាមួយ កាលពីមុនប្រមាទហើយ លុះកាលជាខាងក្រោយ
គេមិនប្រមាទវិញ បុគ្គលនោះ ឈ្មោះថា ញុំាងខន្ធាទិលោកនេះឲ្យ
ភ្លឺច្បាស់ ដូចព្រះចន្ទ្រះផុតចាកពពក ។
បុគ្គលណា ធ្វើអំពើបាបហើយ បិទប្តូរអំពើបាបនោះដោយកុសល
គឺអរហត្តមគ្គបាន បុគ្គលនោះឈ្មោះថា ញុំាងខន្ធាទិលោកនេះ ឲ្យ
ភ្លឺច្បាស់ ដូចព្រះចន្ទ្រះផុតចាកពពក ។
លោកិយមហាជនេះ ជាមនុស្សឆ្ងល់ តណ្ហាជនចាំងនេះ ជន
តិចគ្នាដែលឃើញច្បាស់ (ខ្លួនខន្ធាទិលោកនេះដោយអំណាចអនិច្ច
លក្ខណៈជាដើម) ជនតិចគ្នា ដែលទៅកាន់ឋានសួគ៌ ដូចសត្វស្លាប
(ដែលជាប់សំណាញ់របស់ព្រានហើយ) តិចណាស់ ដែលរួចអំពី
សំណាញ់ ដូច្នោះ ។

ហំសាទិច្ចបថេ យន្តិ អាកាសេ យន្តិ ឥទ្ធិយា
នីយន្តិ ធីរា លោកម្ហា ជេត្វា មារំ សវាហនំ ។
ឯកំ ឯកម្ហិ អាសីនំ មុសាវាទិស្ស ឥត្ថិនោ
វិតិណ្ណបរលោកស្ស នត្ថិ បាបំ អការិយំ ។
ន វេ កទរិយា ទេវលោកំ វជន្តិ
ពាលា ហវេ នប្បសំសន្តិ ទានំ
ធីរោ ច ទានំ អនុមោទមានោ
តេនេវ សោ ហោតិ សុខី បរត្ថ ។
បមាវគ្គោ ឯកាទសមោ សត្តសដ្ឋិ កមនេន វា
សព្ពលោកាភិភូនេន សោតាបត្តិផលំ វរំ ។

ឱភវគ្គោ តេរសមោ ។

ធម្មបទគាថាយ បុទ្ធវគ្គោ

[๒๔] យស្ស ជិតំ នាវជីយតិ
ជិតមស្ស នោយាតិ កោចិ លោកេ
តំ ពុទ្ធំ អនន្តគោចរំ
អបទំ កេន បទេន នេស្សថ ។

ពួកហង្ស តែងហើរទៅក្នុងគន្ធផ្សុព្រះអាទិត្យ អ្នកមានឫទ្ធិ តែងហោះទៅក្នុងអាកាស ដោយឫទ្ធិ អ្នកប្រាជ្ញ ផ្ចាញ់កិលេសមារ ព្រមទាំងវាហនៈគឺតណ្ហាបានហើយ រមែងរលាស់ខ្លួនចេញ ចាកលោកបាន ។ បុគ្គលប្រព្រឹត្តកន្ទូរ (ពាក្យសម្ដែ:) ដែលជាធម៌ឯក និយាយតែពាក្យកុហក មានបរលោក លះចោលហើយ ឈ្មោះថា មិនធ្វើអំពើបាបមិនមែនឡើយ ។

បុគ្គល កំណាញ់សូតស្អាញ មិនបានទៅកាន់ទេវលោកទេ ជនពាលទាំងឡាយ មិនសរសើរទានឡើយ បណ្ឌិតអ្នកប្រាជ្ញ តែងអនុមោទនាទាន ព្រោះហេតុនោះ លោកតែងបានសេចក្ដីសុខ ក្នុងលោកខាងមុខ ។ សោតាបត្តិផល ជាគុណជាតដ៏ប្រសើរ ជាធំតាងនៃឯករាជ្យលើផែនដីផង ជាធំដណើរទៅកាន់ឋានសួគ៌ផង ជាធំតាងជាធំ ក្នុងលោកទាំងមូលផង ។

ចប់ លោកវគ្គ ទី ១៣ ។

ធម្មបទគាថា ពុទ្ធវគ្គ ទី ១៤

(៦៤) ជ័យជំនះរបស់ព្រះពុទ្ធអង្គណា មិនត្រឡប់ចាញ់វិញ កិលេសណាមួយតទល់លោក រមែងមិនជាប់តាមជ័យជំនះ របស់ព្រះពុទ្ធអង្គនោះ នាទាំងឡាយនឹងប្រលោមព្រះពុទ្ធអង្គនោះ ដែលមានគោចរ រកទីបំផុតគ្មាន មិនមានកិលេសដូចស្នាមដើង ដោយកិលេសដូចស្នាមដើង ម្ដេចកើត ។

សុត្តន្តបិដកពេ ខុទ្ទកនិកាយស្ស ធម្មបទគាថា

យស្ស ជាលិនី វិសត្តិកា

តណ្ហា នត្ថិ កុហិញ្ចិ នេតវេ

តំ ពុទ្ធំ អនន្តគោចរំ

អមគំ កេន បទេន នេស្សថ ។

យេ ឈានប្បសុតា ធីរា នេក្ខម្មូបសមេ រតា

ទេវាបិ តេសំ បិហយន្តិ សម្ពុទ្ធានំ សតីមតំ ។

កិច្ឆោ មនុស្សបដិលាភោ កិច្ឆំ មច្ចាន ជីវិតំ

កិច្ឆំ សទ្ធម្មស្សវនំ កិច្ឆោ ពុទ្ធានមុប្បាទោ ។

សព្ពបាបស្ស អករណំ កុសលស្សូបសម្បទា

សចិត្តបរិយោទបនំ ឯតំ ពុទ្ធាន សាសនំ ។

តណ្ហាដែលមានបណ្តាញផ្សាយទៅ ក្នុងអារម្មណ៍ផ្សេង ។ មិនមានដល់ព្រះពុទ្ធអគ្គណា ដើម្បីនឹងនាំទៅ ក្នុងកពណាមួយ នាងពាំងឆ្ងាយ នុ៎ះប្រសោមព្រះពុទ្ធអគ្គនោះ ដែលមានគោចរ រកទីបំផុតគ្មាន មិនមានតំលៃដូចស្នាមដើង ដោយតំលៃដូចស្នាមដើង ម្តេចកើត ។

អ្នកប្រាជ្ញពាំងឆ្ងាយណា ជាអ្នកខ្ជាប់ខ្ជួយក្នុងឈាន ត្រេកអរក្នុងនេក្ខម្មៈ ជាបានសូម្បីតំលៃ សូម្បីទៅតានឹងមនុស្សពាំងឆ្ងាយតែងកប់រក ចំពោះអ្នកប្រាជ្ញពាំងឆ្ងាយនោះ ដែលជាអ្នកត្រាស់ដឹងខ្លួនឯង ពាំងមានស្មារតី ។

ការត្រឡប់បានអត្តភាពជាមនុស្ស បានដោយកម្រ ការរស់របស់សត្វពាំងឆ្ងាយ បានដោយកម្រ ការស្តាប់ធម៌របស់សប្បុរស បានដោយកម្រ ការកើតឡើងនៃព្រះពុទ្ធពាំងឆ្ងាយ បានដោយកម្រ ។ ការមិនធ្វើបាបពាំងពួន ការញុំាងកុសលឲ្យកើតឡើង ការធ្វើចិត្តរបស់ខ្លួនឲ្យផូរផង់ នេះជាពាក្យប្រៅរបស់ព្រះពុទ្ធពាំងឆ្ងាយ ។

ធម្មបទគាថាយ ចុទ្ទសមោ ពុទ្ធវគ្គោ

ទន្ទិ បរមំ តាទោ តិតិក្ខា
និព្ពានំ បរមំ វទន្តិ ពុទ្ធា
ន ហិ បព្ពជិតោ បរូបឃាតី
សមណោ ហោតិ បរំ វិហេឋយន្តោ ។

អនូបវាទោ អនូបឃាតោ បាតិមោក្ខេ ច សំវរោ
មត្តញ្ញុតា ច ភត្តស្មិំ បន្តញ្ច សយនាសនំ
អធិចិត្តេ ច អាយោគោ ឯតំ ពុទ្ធាន សាសនំ ។

ន កហាបណវស្សេន តិត្តិ កាមេសុ វិជ្ជតិ
អប្បស្សាទា ទុក្ខា កាមា ឥតិ វិញ្ញាយ បណ្ឌិតោ
អបិ ទិព្ពេសុ កាមេសុ រតិំ សោ នាធិគច្ឆតិ
តណ្ហក្ខយរតោ ហោតិ សម្មាសម្ពុទ្ធសាវកោ ។

ពហុំ វេ សរណំ យន្តិ បព្ពតានិ វនានិ ច
អារាមរុក្ខចេត្យានិ បុរិសា ភយតជ្ជិតា
នេតំ ខោ សរណំ ខេមំ នេតំ សរណមុត្តមំ
នេតំ សរណមាគម្ម សព្ពទុក្ខា បមុច្চតិ ។

ឧត្តិ គឺសេចក្តីអត់ធន់ ជាតបធម៌(๑)ដ៏ឧត្តម ព្រះពុទ្ធទាំងឡាយ តែងពោលថា ព្រះនិព្វាន ជាធម្មជាតដ៏ឧត្តម បុគ្គលដែលសម្លាប់សត្វដទៃ មិនឈ្មោះថា បព្វជិតទេ បុគ្គលដែលបៀតបៀនសត្វដទៃ ក៏មិនឈ្មោះថា សមណៈឡើយ ។

ការមិនតិះដៀល ๑ ការមិនបៀតបៀន ๑ ការសង្រួមក្នុងឥន្ទ្រិយ ๑ ភាពជាអ្នកដឹងប្រមាណក្នុងភត្ត ๑ ការដេកនឹងអង្គុយក្នុងទីស្ងាត់ ๑ ការព្យាយាមក្នុងអធិចិត្ត ๑ នុ៎ះជាពាក្យប្រដៅ របស់ព្រះពុទ្ធទាំងឡាយ ។ ការស្អប់ស្អល់ ក្នុងកាមទាំងឡាយ រមែងមិនមាន ព្រោះតហាបណៈ (ដែលជ្រាក់ចុះ) ដូចទឹកក្តៅនៅឡើងទេ កាមទាំងឡាយ មានសុខតិចមានទុក្ខច្រើន អ្នកប្រាជ្ញដឹងច្បាស់ យ៉ាងនេះហើយ លោកមិនបានត្រេកអរ ក្នុងកាមទាំងឡាយ សូម្បីជាទិព្វឡើយ សាវ័ករបស់ព្រះសម្មាសម្ពុទ្ធ រមែងជាអ្នកត្រេកអរ ក្នុងធម៌ ជាគ្រឿងអស់តណ្ហា ។ មនុស្សទាំងឡាយ ច្រើននាក់ ត្រូវភ័យគម្រាមហើយ តែងយកភ្នំអាកាមនឹងវត្តេចេតិយ ជាទីពឹង ទីពឹងបែបនេះ មិនមែនជាទីពឹងដ៏ក្សេមទេ ទីពឹងបែបនេះ មិនមែនជាទីពឹងដ៏ឧត្តមទេ បុគ្គលអាស្រ័យនូវទីពឹងនេះហើយ រមែងមិនរួចស្រឡះចាកទុក្ខទាំងពួងឡើយ ។

---

๑ ធម្មជាតដ៏ពិតកំលេសឲ្យក្តៅ ។

សុត្តន្តបិដកៃ ខុទ្ទកនិកាយស្ស ធម្មបទគាថា

យោ ច ពុទ្ធញ្ច ធម្មញ្ច សង្ឃញ្ច សរណំ គតោ
ចត្តារិ អរិយសច្ចានិ សម្មប្បញ្ញាយ បស្សតិ
ទុក្ខំ ទុក្ខសមុប្បាទំ ទុក្ខស្ស ច អតិក្កមំ
អរិយញ្ចដ្ឋង្គិកំ មគ្គំ ទុក្ខូបសមគាមិនំ
ឯតំ ខោ សរណំ ខេមំ ឯតំ សរណមុត្តមំ
ឯតំ សរណមាគម្ម សព្ពទុក្ខា បមុច្চតិ ។
ទុល្លភោ បុរិសាជញ្ញោ ន សោ សព្ពត្ថ ជាយតិ
យត្ថ សោ ជាយតី ធីរោ តំ កុលំ សុខមេធតិ ។
សុខោ ពុទ្ធានមុប្បាទោ សុខា សទ្ធម្មទេសនា
សុខា សង្ឃស្ស សាមគ្គី សមគ្គានំ តបោ សុខោ ។
បូជារហេ បូជយតោ ពុទ្ធេ យទិ ច សាវកេ
បបញ្চសមតិក្កន្តេ តិណ្ណោសោកបរិទ្ទវេ
តេ តាទិសេ បូជយតោ និព្ពុតេ អកុតោភយេ
ន សក្កា បុញ្ញំ សង្ខាតុំ ឥមេត្តមបិ កេនចិ ។

ពុទ្ធវគ្គោ ចុទ្ទសមោ ។

ឧបរិមភាគោវាទំ ។

លុះតែបុគ្គលណា យកព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ជាទីពឹង យើញច្បាស់នូវ
អរិយសច្ចទាំង ៤ គឺ ទុក្ខសច្ច ១ ទុក្ខសមុទយសច្ច ១ និរោធសច្ច កន្លងទុក្ខ ១
អរិយមគ្គប្រកបដោយអង្គ ៨ ជាដំណើរទៅកាន់ព្រះនិព្វានដែលជាទីរម្ងាប់ទុក្ខ ១
ដោយប្រាជ្ញាដ៏ប្រពៃ នេះឯងជាទីពឹងដ៏ក្សេម នេះឯង ជាទីពឹងដ៏ខ្ពង់ បុគ្គល
អាស្រ័យទីពឹងនេះ រមែង រួចស្រឡះចាកទុក្ខទាំងពួងបាន ។

បុរសអាជានេយ្យ រកបានដោយកម្រ លោកមិនកើតក្នុងសព្វហ៊ានឡើយ លោក
ជាអ្នកមានប្រាជ្ញាកើតក្នុងត្រកូលណា ត្រកូលនោះ តែងដល់នូវសេចក្តីសុខ ។
ការកើតឡើងនៃព្រះពុទ្ធ ជាសុខ ការសំដែងព្រះសទ្ធម្ម ជាសុខ សេចក្តី
ព្រមព្រៀងគ្នានៃពួក ជាសុខ តបធម៌ របស់បុគ្គលអ្នកព្រមព្រៀងគ្នា
ទាំងឡាយ ជាសុខ ។

ការបូជាដល់បុគ្គលបូជា ដល់បូជារហបុគ្គលគឺព្រះពុទ្ធ ឬសាវ័ករបស់ព្រះពុទ្ធ ដែល
កន្លងផុតបបញ្ចធម៌ ដែលកន្លងផុតសេចក្តីសោកនឹងខ្សឹកខ្សួល ឬ ការបូជា
ដល់បូជារហបុគ្គលទាំងនោះ ដែលប្រកប ដោយគុណ លោកមិនមាន
ភ័យអំពីទីណា សូម្បីនិព្វានទៅហើយ បុគ្គលណាមួយ មិនអាចរាប់បុណ្យថា
បុណ្យនេះមានប្រមាណប៉ុណ្ណេះ ឬនឡើយ ។

ចប់ ពុទ្ធវគ្គ ទី ១៤ ។

ចប់ បឋមភាណវារៈ ។

ធម្មបទគាថាយ បណ្ឌវសមោ សុខវគ្គោ

[๒๘] សុសុខំ វត ជីវាម វេរិនេសុ អវេរិនោ

វេរិនេសុ មនុស្សេសុ វិហរាម អវេរិនោ ๆ

សុសុខំ វត ជីវាម អាតុរេសុ អនាតុរា

អាតុរេសុ មនុស្សេសុ វិហរាម អនាតុរា ๆ

សុសុខំ វត ជីវាម ឧស្សុកេសុ អនុស្សុកា

ឧស្សុកេសុ មនុស្សេសុ វិហរាម អនុស្សុកា ๆ

សុសុខំ វត ជីវាម យេសន្នោ នត្ថិ កិញ្ចនំ

មីតភក្ខា ភវិស្សាម ទេវា អាភស្សរា យថា ๆ

ជយំ វេរំ បសវតិ ទុក្ខំ សេតិ បរាជិតោ

ឧបសន្តោ សុខំ សេតិ ហិត្វា ជយបរាជយំ ๆ

នត្ថិ រាគសមោ អគ្គិ នត្ថិ ទោសសមោ កលិ

នត្ថិ ខន្ធសមា ទុក្ខា នត្ថិ សន្តិបរំ សុខំ ๆ

ធម្មបទគាថា សុខវគ្គទី ១៥

[๒๙] យើងជាអ្នកមិនមានពៀរ រស់នៅជាសុខពិត ក្នុងពួកមនុស្ស មានពៀរ កាលពួកមនុស្សមានពៀរ យើងជាអ្នកមិនមានពៀរ ។ យើងជាអ្នកមិនមានសេចក្តីក្តៅក្រហាយ (ដោយកិលេស) រស់នៅជាសុខពិត ក្នុងពួកមនុស្សមានសេចក្តីក្តៅក្រហាយ កាលពួកមនុស្សមានសេចក្តីក្តៅក្រហាយ យើងជាអ្នកមិនមានសេចក្តីក្តៅក្រហាយ ។ យើងជាអ្នកមិនមានសេចក្តីខ្វល់ខ្វាយ ក្នុងការស្វែងរក រស់នៅជាសុខពិត ក្នុងពួកមនុស្សមានសេចក្តីខ្វល់ខ្វាយ កាលពួកមនុស្សមានសេចក្តីខ្វល់ខ្វាយ យើងជាអ្នកមិនមានសេចក្តីខ្វល់ខ្វាយ ។ យើងមិនមានកង្វល់ តែងរស់នៅជាសុខពិត (ព្រោះ) យើងមានបីតិជាអាហារ ដូចពួកទេវតាជាន់អាភស្សរៈ ។

បុគ្គលអ្នកឈ្នះ តែងវង្វេងនូវពៀរ បុគ្គលអ្នកចាញ់ តែងដេកជាទុក្ខ ចំណែកបុគ្គលលះបង់ការឈ្នះនឹងការចាញ់ចេញហើយ ជាអ្នកស្ងប់រម្ងាប់ ទើបដេកជាសុខ ។

ភ្លើងស្មើដោយរាគៈ មិនមាន ទោសតំហុសស្មើដោយទោសៈ មិនមាន ទុក្ខពាំងឡាយស្មើដោយខន្ធ មិនមាន សុខក្រៅពីសេចក្តីស្ងប់ មិនមាន ។

សុត្តន្តបិដកៈ ខុទ្ទកនិកាយស្ស ធម្មបទគាថា

ជិយ្យេថ បរមា កោធា សង្ខារា បរមា ទុក្ខា

ឯតំ ញត្វា យថាភូតំ និព្ពានំ បរមំ សុខំ ។

អារោគ្យបរមា លាភា សន្តុដ្ឋិបរមំ ធនំ

វិស្សាសបរមា ញាតី និព្ពានំ បរមំ សុខំ ។

បវិវេករសំ បិត្វា រសំ ឧបសមស្សុ ច

និទ្ទរោ ហោតិ និប្បាបោ ធម្មបីតិរសំ បិវំ ។

សាធុ ទស្សនមរិយានំ សន្និវាសោ សទា សុខោ

អទស្សនេន ពាលានំ និច្ចមេវ សុខី សិយា ។

ពាលសង្គតចារី ហិ ទីឃមទ្ធាន សោចតិ

ទុក្ខោ ពាលេហិ សំវាសោ អមិត្តេនេវ សព្ពទា ។

សេចក្តីស្រេកឃ្លាន ជារោគយ៉ាងក្រៃលែង សង្ខារទាំងឡាយ ជាទុក្ខយ៉ាងក្រៃលែង (អ្នកប្រាជ្ញ) ដឹងច្បាស់សេចក្តីនុ៎ះ តាមពិតហើយ (រមែងធ្វើឲ្យច្បាស់) នូវព្រះនិព្វាន ជាសុខយ៉ាងក្រៃលែង ។

លាភមានការមិនមានរោគ ជាយ៉ាងក្រៃលែង ទ្រព្យមានសេចក្តីសន្តោស ជាយ៉ាងក្រៃលែង ញាតិមានសេចក្តីស្និទ្ធស្នាល ជាយ៉ាងក្រៃលែង ព្រះនិព្វាន ជាសុខយ៉ាងក្រៃលែង ។

ភិក្ខុផឹករស (๑) វិវេកផង រសព្រះនិព្វាន ជាទីរម្ងាប់តិលេសផង ផឹករសបីតិដែលកើតអំពីធម៌ផង ទើបជាអ្នកមិនមានសេចក្តីក្រៃលែក្រៃឡយ មិនមានសេចក្តីសៅហ្មងឡើយ ។

ការចូលប្រទះព្រះអរិយបុគ្គលទាំងឡាយ ជាការល្អ ការនៅរួមជាមួយព្រះអរិយបុគ្គលទាំងឡាយ ជាហេតុឲ្យកើតសេចក្តីសុខ សព្វកាល បុគ្គលគប្បីមានសេចក្តីសុខអស់កាលជានិច្ចបាន ព្រោះមិនចូលប្រទះបុគ្គលពាលទាំងឡាយ ។

បុគ្គលអ្នកប្រព្រឹត្តសមគប់ដោយជនពាល រមែងសោកក្តៅអស់កាលយូរអង្វែង ការនៅរួមជាមួយនឹងជនពាល រមែងជាទុក្ខសព្វកាល ។

---

๑ រស ក្នុងទីនេះសំដៅយកសេចក្តីសុខដ៏ប្រសើរ ។

ឆឝ្ឆេ ច សុខសំវាសោ ញាតីនំ សមាគមោ

តស្មាហិ

ឆឝ្ឆ បញ្ញ ពហុស្សុតញ្ច

ធោរយ្ហសីលំ វតវន្តមរិយំ

តំ តាទិសំ សប្បុរិសំ សុមេធំ

ភជេថ នក្ខត្តបថំវ ចន្ទិមា ។

សុខវគ្គោ បណ្ណរសមោ ។

ធម្មបទគាថាយ សោឡសមោ បិយវគ្គោ

[๒๖]អយោគេ យុញ្ជមត្តានំ យោគស្មិញ្ច អយោគយំ

អត្ថំ ហិត្វា បិយគ្គាហី បិហេតត្តានុយោគិនំ ។

មា បិយេហិ សមាគញ្ឆិ អប្បិយេហិ កុទាចនំ

បិយានំ អទស្សនំ ទុក្ខំ អប្បិយានញ្ច ទស្សនំ ។

ដូចគារនៅរួមជាមួយ នឹងសត្រូវ ចំណែកខាងគារនៅរួមនឹងធីរជន រមែងជាសុខ ដូចគារបួបជុំនៃញាតិទាំងពួយ ព្រោះហេតុនោះឯង បុគ្គលគួរសេពគប់សប្បុរស ជាអ្នកមាំមួនផង មានបញ្ញាផង មានសេចក្តីចេះដឹងច្រើនផង មានតិរិយានាំទៅនូវធុរៈជាប្រក្រតីផង មានសីលវតៃនឹងធុតង្គវត្តផង ជាអ្នកនាយចាកកិលេសផង មានបញ្ញាល្អផង ប្រាកដដូច្នោះ ។ ឲ្យដូចព្រះចន្ទគប់នូវផ្លូវនក្ខត្តឫក្ស ។

ចប់ សុខវគ្គ ទី ១៥ ។

ធម្មបទគាថា បិយវគ្គ ទី ១៦

(៦៦) បុគ្គលគាលប្រកបខ្លួនខុស ក្នុងអំពើដែលមិនគួរប្រកប មិនប្រកបខ្លួន ក្នុងអំពើដែលគួរប្រកប លះបង់ប្រយោជន៍បេញ្ញៅហើយ កាន់យកតាមគាប់ចិត្ត រមែងស្រឡាញ់ បុគ្គលអ្នកប្រកបតាមខ្លួន ។ កុំគប់រកសត្វនឹងសង្ខារទាំងពួយ ដែលជាទីស្រឡាញ់ នឹងមិនជាទីស្រឡាញ់ ក្នុងគាលណា ។ ឡើយ ព្រោះថា គារមិនបួបប្រសព្វសត្វនឹងសង្ខារជាទីស្រឡាញ់ក្តី គារបួបប្រសព្វសត្វនឹងសង្ខារមិនជាទីស្រឡាញ់ក្តី ជាហេតុទាំងកន្លងទៅក្តី ។

ตสฺมา ปิยํ น กยิราถ ปิยาปายาโย หิ ปาปโก
ยตฺถ เตสํ น วิชฺชนฺติ เยสํ นตฺถิ ปิยาปฺปิยํ ฯ
ปิยโต ชายเต[๑] โสโก ปิยโต ชายเต ภยํ
ปิยโต วิปฺปมุตฺตสฺส นตฺถิ โสโก กุโต ภยํ ฯ
ปฺเปมโต ชายเต โสโก ปฺเปมโต ชายเต ภยํ
ปฺเปมโต วิปฺปมุตฺตสฺส นตฺถิ โสโก กุโต ภยํ ฯ
รติยา ชายเต โสโก รติยา ชายเต ภยํ
รติยา วิปฺปมุตฺตสฺส นตฺถิ โสโก กุโต ภยํ ฯ
กามโต ชายเต โสโก กามโต ชายเต ภยํ
กามโต วิปฺปมุตฺตสฺส นตฺถิ โสโก กุโต ภยํ ฯ
ตณฺหาย ชายเต โสโก ตณฺหาย ชายเต ภยํ
ตณฺหาย วิปฺปมุตฺตสฺส นตฺถิ โสโก กุโต ภยํ ฯ

๑ ชายเตติปิ ปาโฐ ฯ

ព្រោះហេតុនោះ បុគ្គលមិនគួរធ្វើសត្វទឹងឆ្ងាយ ឲ្យជាទីស្រឡាញ់ ព្រោះការព្រាត់ប្រាសចាកសត្វទឹងឆ្ងាយ ជាទីស្រឡាញ់ ជាសភាពអាក្រក់ ការស្រឡាញ់នឹងការស្អប់ មិនមានដល់ពួកជនណា តែលេសគ្រឿនចាក់ស្រែះចាំងឡាយ តែងមិនមាន ដល់ពួកជននោះ ។

សេចក្តីសោកកើតអំពីសេចក្តីស្រឡាញ់ ភ័យកើតអំពីសេចក្តីស្រឡាញ់ កាលបើរួចស្រឡះចាកសេចក្តីស្រឡាញ់ហើយ សេចក្តីសោក ក៏លែងមាន ភ័យនឹងមានមកពីណា ។

សេចក្តីសោកកើតអំពីសេចក្តីស្រឡាញ់ ភ័យកើតអំពីសេចក្តីស្រឡាញ់ កាលបើរួចស្រឡះចាកសេចក្តីស្រឡាញ់ហើយ សេចក្តីសោក ក៏លែងមាន ភ័យនឹងមានមកពីណា ។

សេចក្តីសោកកើតអំពីតម្រេក ភ័យកើតអំពីតម្រេក កាលបើរួចស្រឡះចាកតម្រេកហើយ សេចក្តីសោកក៏លែងមាន ភ័យនឹងមានមកពីណា ។

សេចក្តីសោកកើតអំពីកាម ភ័យកើតអំពីកាម កាលបើរួចស្រឡះចាកកាមហើយ សេចក្តីសោក ក៏លែងមាន ភ័យនឹងមានមកពីណា ។

សេចក្តីសោកកើតអំពីតណ្ហា ភ័យកើតអំពីតណ្ហា កាលបើរួចស្រឡះចាកតណ្ហាហើយ សេចក្តីសោក ក៏លែងមាន ភ័យនឹងមានមកពីណា ។

ធម្មបទគាថាយ សត្តរសមោ កោធវគ្គោ

សីលេនសុគតិំ យន្តិ ឯកច្ចេ ឥធ បណ្ឌិតា
អត្តនោ កម្មកុព្ពានំ ផលំ ឧបនិធាយ ច ។
ឯកច្ចេ បន សទ្ធាយ ធនភោគេន ឧត្តមា[1]
តេ ហិ តត្ថ តត្ថ ជាយន្តិ យត្ថ យត្ថ ភវន្តិ តេ ។
តេ ច តត្ថ ភវិត្វាន ឧបបជ្ជន្តិ តាទិសេ[2]
កុលេ ជាតិំ ច លច្ឆន្តិ ឥតិ ពុទ្ធានុសាសនំ ។
ឯវំ ទេវមនុស្សេសុ ឧបបត្តិ ច ទុល្លភា
ឥតិ ញត្វាន មេធាវី ទេវមនុស្សេសុ ច

ជនតែងធ្វើបុគ្គលដែលបរិបូណ៌ ដោយសីលនឹងតបយើញត្រូវ ឋិត
នៅក្នុងធម៌ ពោលសច្ចធម៌(១)ជាប្រក្រតី ធ្វើកម្ម(២)ជារបស់ខ្លួននោះ
ឲ្យជាទីស្រឡាញ់ ។

បុគ្គល អ្នកមានសេចក្តីប្រាថ្នា ចំពោះព្រះនិព្វាន ដែលគេនិយាយ
ប្រាប់គ្មានបានផង ជាអ្នកមានមគ្គចិត្តនឹងផលចិត្ត (ខាងក្រោម)
ប៉ះពាល់ហើយផង មានចិត្តមិនប្រតិព័ទ្ធក្នុងកាមផង តថាគតហៅថា
ជាអ្នកមានខ្យែរមគ្គប្រព្រឹត្តទៅ ក្នុងខាងលើ ។

ពួកញាតិក្តី មិត្រក្តី សំឡាញ់ក្តី រមែងត្រេកអរនឹងបុរសដែលឃ្លាតគ្នា
អស់កាលយូរ មកអំពីបម្ងាយដោយសួស្តី មកដល់ហើយ យ៉ាងណា
មិញ បុណ្យទាំងឡាយ តែងទទួលបុគ្គល ដែលបានធ្វើបុណ្យ
ប្រុតអំពីមនុស្សលោកនេះ ទៅកាន់លោកខាងមុខ ដូចញាតិទាំង
ឡាយ ទទួលបុរសជាទីស្រឡាញ់ទើបមកដល់ ដូច្នោះឯង ។

ចប់ បិយវគ្គ ទី ១៦ ។

ធម្មបទគាថា កោធវគ្គ ទី ១៧

(៦៧) បុគ្គលគួរលះបង់សេចក្តីក្រោធចេញ គួរលះបង់មានះចេញ

---

១ សំដៅយកអរិយសច្ច ៤ ។ ២ បានដល់ត្រៃសិក្ខា ។ អដ្ឋកថា ។

សព្ពេ ធម្មា អនត្តាតិ យទា បញ្ញាយ បស្សតិ
អថ និព្ពិន្ទតិ ទុក្ខេ ឯស មគ្គោ វិសុទ្ធិយា ។

សព្ពេ សង្ខារា ទុក្ខាតិ យទា បញ្ញាយ បស្សតិ
អថ និព្ពិន្ទតិ ទុក្ខេ ឯស មគ្គោ វិសុទ្ធិយា ។

សព្ពេ សង្ខារា អនិច្ចាតិ យទា បញ្ញាយ បស្សតិ
អថ និព្ពិន្ទតិ ទុក្ខេ ឯស មគ្គោ វិសុទ្ធិយា ។

ឧដ្ឋានកាលម្ហិ អនុដ្ឋហានោ យុវា ពលី អាលសិយំ ឧបេតោ
សំសន្នសង្កប្បមនោ កុសីតោ បញ្ញាយ មគ្គំ អលសោ ន វិន្ទតិ ។

វាចានុរក្ខី មនសា សុសំវុតោ កាយេន ច អកុសលំ ន កយិរា
ឯតេ តយោ កម្មបថេ វិសោធយេ អារាធយេ មគ្គមិសិប្បវេទិតំ ។

មគ្គស្ស ខោ សតិ បមុខាយនំ យទិទំ អប្បមាទោ
អប្បមាទោ អមតបទំ បមាទោ មច្ចុនោ បទំ
អប្បមត្តា ន មីយន្តិ យេ បមត្តា យថា មតា ។

ឯវំ វិសេសតោ ញត្វា អប្បមាទម្ហិ បណ្ឌិតា
អប្បមាទេ បមោទន្តិ អរិយានំ គោចរេ រតា ។

តេ ឈាយិនោ សាតិកា និច្চំ ទឬ្ហបរក្កមា
ផុសន្តិ ធីរា និព្ពានំ យោគក្ខេមំ អនុត្តរំ ។

ឧដ្ឋានវតោ សតីមតោ សុចិកម្មស្ស និសម្មការិនោ
សញ្ញតស្ស ច ធម្មជីវិនោ អប្បមត្តស្ស យសោភិវឌ្ឍតិ ។

ឧដ្ឋានេនប្បមាទេន សញ្ញមេន ទមេន ច
ទីបំ កយិរាថ មេធាវី យំ ឱឃោ នាភិកីរតិ ។

ចត្តារិ ឋានានិ នរោ បមាទា អនាយុសំ បាបុណាតិ
ទុម្មេធោ ឯតមាទីនវំ ឥតិ ភាយមានោ ន ករេយ្យ បាបំ ។

ន ហិ ឯតេ ឯកវិហារិនោ ឯកោ ន ឈាយតិ ន ហិ ឯកោ ន ឈាយតិ
ឯតេ ជាតិជរាភិភូតិនោ ឯកោ ន ឈាយតិ ន ហិ ឯកោ ន ឈាយតិ ។

ឯតេ ជាតិជរាភិភូត

គួរកន្ទក់សង្ឃដនធម៌ចាំធ៌អស់ចោលចេញ ទុក្ខចាំធ៌ឡាយ តែធ៌
មិនជាប់តាមបុគ្គល ដែលមិនចំពាក់ ក្នុងនាមនធ៌រូប មិនមាន
តំលៃស គ្រឿងតង្រៃនោះឡើយ ។

បុគ្គលណា ឃាត់សេចក្តីក្រោធ ដែលកើតឡើងហើយ ដូចសារថី
ទប់រថដែលកំពុងលឿនបាន តថាគតហៅបុគ្គលនោះថាជាសារថី ជន
ក្រៅពីនេះ គ្រាន់តែជាអ្នកកាន់ខ្សែបរ (មិនមែនសារថីឡើយ) ។

បុគ្គលគប្បីផ្តាញ់មនុស្សក្រោធ ដោយសេចក្តីមិនក្រោធ គប្បីផ្តាញ់
មនុស្សអសប្បុរស ដោយសប្បុរស គប្បីផ្តាញ់មនុស្សកំណាញ់ដោយ
ការឲ្យ គប្បីផ្តាញ់មនុស្សនិយាយពាក្យមិនពិត ដោយពាក្យពិត ។

បុគ្គលគួរពោលពាក្យពិត ១ មិនគួរក្រោធ ១ កាលគេសូមវត្ថុសូម្បី
មានតិច ក៏គួរឲ្យ (តាមតិច) ១ បុគ្គលគប្បីទៅកើត ក្នុងសំណាក់
ទេវតាចាំធ៌ឡាយបាន ដោយហេតុចាំធ៌ ៣ នេះឯង ។

ជនចាំធ៌ឡាយណា ជាអ្នកប្រាជ្ញ(១) មិនបៀតបៀនសត្វដទៃ សង្រួម
ហើយដោយកាយវាចា (ជាដើម) ជានិច្ច ជនចាំធ៌ឡាយនោះ រមែង
ទៅកាន់ស្ថានដ៏មិនប្រែប្រួល ជាស្ថានដែលគេទៅដល់ហើយ តែធ៌
មិនសោកស្តាយ ។

---

១ សំដៅយកអរិយបុគ្គលមុនពីនេះ ដែលសម្រេចមគ្គផល ដោយមោនេយ្យប្បដិបទា ។ អដ្ឋកថា ។

ធម្មបទគាថាយ សត្ថុសម្ភេ កោធវត្ថុ

សធា ជាតរមាណានំ អរោគាតិ្ថ ឧសិក្ខិនំ

ឯញ្ញានំ អធិមុត្តានំ អត្ថំ គច្ឆន្តិ អាសវា ។

ចោភណាមេតំ អតុលំ នេតំ អដ្ឋគណាមិវ

ឯន្ទ្រិ តុណ្ហីមាសីនំ ឯន្ទ្រិ ពហុភាណិនំ

មិតភាណិមិវ ឯន្ទ្រិ ឯតំ លោកេ អនិន្ទិតោ ។

ន ចាហ្ន ន ច ភវិស្សតិ ន ចេតរហិ វិជ្ជតិ

ឯកន្តំ និន្ទិតោ ចោសោ ឯកន្តំ វា បសំសិតោ ។

យញ្ចេ វិញ្ញូ បសំសន្តិ អនុវិច្ច សុវេ សុវេ

អច្ឆិទ្ទវុត្តឹ(๑) មេធាវឹ បញ្ញាសីលសមាហិតំ

នេក្ខំ ជម្ពោនទស្សេវ កោ តំ និន្ទិតុមរហតិ

ទេវាបិ នំ បសំសន្តិ ព្រហ្មុនាបិ បសំសិតោ ។

---

๑ ម. អច្ឆិទ្ទវុត្តិ ។

*អាសវៈ*ទាំង*ឆ្អាយ*របស់*បុគ្គល* *អ្នក*ភ្ញាក់*រឭក*សព្វ*កាល* *ជា*អ្នក*សិក្សា* *ត្រៃសិក្ខា* *ទាំង*ថ្ងៃ*ទាំង*យប់ *មាន*ចិត្ត*ប្រុះ*ស៊ប់*នាន*ព្រះ*និព្វាន* *តែង* *ដល់*នូវ*តណ្ហា*ដែល*ទៅ*មិន*បាន*ឡើយ ។

*ម្នាល*អតុល: *តណ្ហា*ដៀល*នឹង*តណ្ហា*សរសើរ*នេះ *ជា*របស់*បុរាណ* *តណ្ហា* ដៀល*នឹង*តណ្ហា*សរសើរ*នេះ *មិន*មែន*ទើប*នឹង*កើត*ឡើង* *ក្នុង*ថ្ងៃ*នេះ*ទេ (*ព្រោះ*ថា) *ជន*ទាំង*ឆ្អាយ* *តែង*និន្ទា*បុគ្គល*អ្នក*អង្គុយ*ស្ងៀម* *ក៏*មាន *និន្ទា*បុគ្គល*អ្នក*និយាយ*ច្រើន* *ក៏*មាន *និន្ទា*បុគ្គល*អ្នក*និយាយ*ល្មម ប្រមាណ *ក៏*មាន(*អ្នក*ណា ។ *ក៏*ដោយ)*ក្នុង*លោក *ដែល*មិន*ត្រូវ*គេ*និន្ទា *គ្មាន*ឡើយ *បុគ្គល*ដែល*ត្រូវ*គេ*និន្ទា*តែ*ម្យ៉ាង* *ឬ*ត្រូវ*គេ*សរសើរ*តែ *ម្យ៉ាង* *មិន*មែន*មាន*មក*ហើយ*តែ*ក្នុង*អតីត*នេ *នឹង*មាន*ទៅ*ក្នុង*អនាគត *ក៏*នេ *មាន*តែ*ក្នុង*បច្ចុប្បន្ន*នេះ*ក៏*នេ ។

*បើ*អ្នក*ប្រាជ្ញ*ទាំង*ឆ្អាយ*សង្កេត*មើល*រាល់ ។ *ថ្ងៃ* *ហើយ*សរសើរ*បុគ្គល ណា ដែល*ជា*អ្នក*ប្រព្រឹត្ត*មិន*ជាប់ *មាន*ប្រាជ្ញា *មាន*ចិត្ត*ដម្កល់*ខ្ជាប់ *ក្នុង*បញ្ញា*នឹង*សីល *អ្នក*ណា*គួរ*នឹង*និន្ទា*បុគ្គល ដែល*ដូច*ជា*ឆ្នោរ*នៃ *មាស*ដម្ពោន*នោះ*បាន *សូម្បី*ទេវតា*នឹង*មនុស្ស*ទាំង*ឆ្អាយ *ក៏*សរ-សើរ*បុគ្គល*នោះ *ទាំង*ព្រហ្ម*ក៏*សរសើរ(*ដូច*គ្នា) ។

កាយម្បាកោបំ រក្ខេយ្យ កាយេន សំវុតោ សិយោ
កាយទុច្ចរិតំ ហិត្វា កាយេន សុចរិតំ ចរេ
វចីបកោបំ រក្ខេយ្យ វាចាយ សំវុតោ សិយោ
វចីទុច្ចរិតំ ហិត្វា វាចាយ សុចរិតំ ចរេ
មនោបកោបំ រក្ខេយ្យ មនសា សំវុតោ សិយោ
មនោទុច្ចរិតំ ហិត្វា មនសា សុចរិតំ ចរេ
កាយេន សំវុតា ធីរា អថោ វាចាយ សំវុតា
មនសា សំវុតា ធីរា តេ វេ សុបរិសំវុតា ។

កោធវគ្គោ សត្តរសមោ ។

ធម្មបទគាថាយ អដ្ឋារសមោ មលវគ្គោ

[๒๘] បណ្ឌុបលាសោវាធិសិ
យមបុរិសាបិ ច តេ ឧបដ្ឋិតា
ឧយ្យោគមុខេ ច តិដ្ឋសិ
បាថេយ្យម្បិ ច តេ ន វិជ្ជតិ ។

បុគ្គលគប្បីរក្សាន្ទូវគារកម្រើកកាយ គប្បីសង្រួមកាយ គប្បីលះបង់កាយទុច្ចរិត គប្បីប្រព្រឹត្តកាយសុចរិត គប្បីរក្សាន្ទូវគារកម្រើកវាចា គប្បីសង្រួមវាចា គប្បីលះបង់វចីទុច្ចរិត គប្បីប្រព្រឹត្តវចីសុចរិត គប្បីរក្សាន្ទូវគារកម្រើកចិត្ត គប្បីសង្រួមចិត្ត គប្បីលះបង់មនោទុច្ចរិត គប្បីប្រព្រឹត្តមនោសុចរិត អ្នកប្រាជ្ញទាំងឡាយ ឯងសង្រួមកាយ សង្រួមវាចា អ្នកប្រាជ្ញទាំងឡាយ ឯងសង្រួមចិត្តហើយ លោកទាំងនោះឯង ឈ្មោះថា សង្រួមហើយដោយប្រពៃ ។

ចប់ កោធវគ្គទី ១៧ ។

ធម្មបទគាថា មលវគ្គទី ១៨

(៤៨) ឥឡូវនេះ ខ្ញុំឯងដូចស្លឹកឈើទុំហើយ ទាំងពួកបុរសរបស់យមរាជ(១) ប្រាកដ ដល់អ្នកហើយ ខ្ញុំឯងគាំងនៅក្នុងមាត់សេចក្តីវិនាស សូម្បីសម្បៀងគឺកុសលរបស់អ្នក ក៏មិនមានមកខ្ញុំឯងឡើយ ។

---

១ អ្នកបម្រើស្តេចយម: តែពាក្យនេះសំដៅយកសេចក្តីស្លាប់ ។ អដ្ឋកថា ។

សោ ភវេមិ ឧបមញ្ញតោ
ទិព្ពំ វាយមេ បណ្ឌិតោ ភវ
និទ្ទន្តមលោ អនង្គណោ
និព្ពុំ អរិយភូមិមេហិសិ[1] ។
ឧបធីតវាយោ វាតាធិសិ
សម្បយោគោសិ[2] យមស្ស សន្តិកំ[3]
វាសោបិ ច នេ ឧត្តំ អន្តរា
ភាថេយ្យម្បិ ច នេ ន វិជ្ជតិ ។
សោ ភវេមិ ឧបមញ្ញតោ
ទិព្ពំ វាយមេ បណ្ឌិតោ ភវ
និទ្ទន្តមលោ អនង្គណោ
ន បុន ជាតិជរំ ឧបេហិសិ ។
អនុបុព្ពេន មេធាវី ថោកំ ថោកំ ខណេ ខណេ
តកម្មារោ រជតស្សេវ និទ្ធមេ មលមត្តនោ ។

---

๑ ម. អរិយភូមិំ ឧបេហិសិ ។ ๒. សម្បយោភោ ច ។ ๓ ឧ.ម. សន្តិកេ ។

ធម្មបទគាថា មលវគ្គ ទី ១៨

អ្នកចូរធ្វើកុសលជាទីពឹងសម្រាប់ខ្លួនទៅ ចូរព្យាយាមឲ្យឆាប់ទៅ ចូរជាអ្នកប្រាជ្ញទៅ បើអ្នក (ធ្វើយ៉ាងនេះហើយ) នឹងទៅជាអ្នកកំចាត់បង់មន្ទិលបាន មិនមានទីទួលគឺកិលេស នឹងដល់នូវភូមិរបស់ព្រះអរិយៈជួបជាមិញ្ញបាន ។

ឥឡូវនេះ ខ្លួនអ្នកត្រូវដកចូលដល់ហើយ ជាអ្នករៀបដំណើរទៅកាន់សំណាក់យមរាជ មួយទៀត ទីសំចតក្នុងចន្លោះ មិនមានដល់អ្នកទេ សូម្បីសៀវផ្លែ ក៏មិនមានដល់អ្នក ។

អ្នកចូរធ្វើទីពឹងសម្រាប់ខ្លួនទៅ ចូរព្យាយាមឲ្យឆាប់ទៅ ចូរជាអ្នកប្រាជ្ញទៅ បើអ្នក (ធ្វើយ៉ាងនេះហើយ) នឹងទៅជាអ្នកកំចាត់បង់មន្ទិលបាន មិនមានទីទួលគឺកិលេស នឹងមិនត្រូវចូលទៅកាន់ជាតិ ជរា ព្យាធិ មរណៈទៀតឡើយ ។

អ្នកមានប្រាជ្ញា គួរកំចាត់បង់មន្ទិលរបស់ខ្លួនបន្តិចម្តងៗ រាល់ ។ ខណៈ ដោយលំដាប់ ដូចជាងមាស ដំរះស្នាមប្រេះរបស់មាសដូច្នោះ ។

សុត្តន្តបិដកេ ខុទ្ទកនិកាយស្ស ធម្មបទគាថា

អយសា វ មលំ សមុដ្ឋិតំ(๑)

តទុដ្ឋាយ តមេវ ខាទតិ

ឯវំ អតិធោនចារិនំ

សានិ កម្មានិ នយន្តិ ទុគ្គតិំ ។

អសជ្ឈាយមលា មន្តា អនុដ្ឋានមលា ឃរា

មលំ វណ្ណស្ស កោសជ្ជំ បមាទោ រក្ខតោ មលំ។

មលិត្ថិយា ទុច្চរិតំ មច្ឆេរំ ទទតោ មលំ

មលា វេ បាបកា ធម្មា អស្មិំ លោកេ បរម្ហិ ច

តតោ មលា មលតរំ អវិជ្ជា បរមំ មលំ

ឯតំ មលំ បហន្ត្វាន និម្មលា ហោថ ភិក្ខវោ ។

សុជីវំ អហិរិកេន កាកសូរេន ធំសិនា

បក្ខន្ទិនា បគព្ភេន សង្កិលិដ្ឋេន ជីវិតំ ។

ហិរីមតា ច ទុជ្ជីវំ និច្চំ សុចិគវេសិនា

អលីនេនាបគព្ភេន សុទ្ធាជីវេន បស្សតា ។

---

๑ កត្ថចិ ចោត្ថកេ សមុដ្ឋាយាតិ ទិស្សតិ ។

ប្រែរកតែតអំពីដែក លុះកើតអំពីដែកនោះហើយ តែងស៊ីដែកនោះវិញ
យ៉ាងណាមិញ កម្មទាំងឡាយរបស់ខ្លួន តែងនាំបុគ្គលអ្នកប្រព្រឹត្ត
កន្លងបញ្ជាជាគ្រឿងដំរេចិត្ត ឲ្យទៅកាន់ទុគ្គតិ កំយ៉ាងនោះឯង ។
មន្តទាំងឡាយមានការមិនស្វាធ្យាយ ជាមន្តិល ផ្ទះទាំងឡាយមានការ
មិនថែទាំ ជាមន្តិល សេចក្តីខ្ជិល ជាមន្តិលរបស់ពណ៌សម្បុរ សេចក្តី
ប្រមាទ ជាមន្តិលរបស់បុគ្គលអ្នករក្សា ។
ការប្រព្រឹត្តិអាក្រក់[1] ជាមន្តិលរបស់ស្ត្រី សេចក្តីកំណាញ់ ជាមន្តិល
របស់អ្នកឲ្យ ធម៌អាក្រក់ទាំងឡាយ ជាមន្តិល ក្នុងលោកនេះនឹងលោក
ខាងមុខ ធម្មជាត ជាមន្តិលដ៏លើសលុប ជាងមន្តិលទាំងនោះ គឺអវិជ្ជា
ជាមន្តិលដ៏ក្រៃលែង ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរលះមន្តិល
ទាំងនេះចេញ ចូរកុំជាអ្នកមានមន្តិលឡើយ ។
បុគ្គលអ្នកមិនមានសេចក្តីអៀនខ្មាស ក្អៀវក្អាចដូចសត្វក្អែក កំចាតបង់
គុណរបស់អ្នកដទៃ ជាអ្នកឈ្លានពាន (យកមុខ) ជាអ្នកឃើញឃន់ ជា
មនុស្សសៅហ្មង រស់នៅដោយងាយ ។ បំណែកបុគ្គលអ្នកមាន
សេចក្តីអៀនខ្មាស ស្វែងរកអំពើស្អាតជានិច្ច មិនលេះលោះមិនឃើញ
ឃន់ រស់នៅដោយកម្មដ៏បរិសុទ្ធ អ្នកឃើញច្បាស់ រស់នៅដោយលំបាក ។

---

๑ សំដៅយកការប្រព្រឹត្តិក្នុងចិត្តប្ចី ។ អដ្ឋកថា ។

ធម្មបទគាថាយ អដ្ឋកថាសង្គៅ មលវគ្គោ

យោ ចាណាមតំមាបេតំ[1] មុសាវាទញ្ច ភាសតិ
លោកេ អទិន្នំ អាទិយតិ បរទារញ្ច គច្ឆតិ
សុរាមេរយចានញ្ច យោ នរោ អនុយុញ្ជតិ
ឥធេវមេសោ លោកស្មឹំ មូលំ ខណតិ អត្តនោ ។
ឯវំ ភោ បុរិស ជានាហិ ធម្មា អសញ្ញតា
មា តំ[2] លោភោ អធម្មោ ច ចិរំ ទុក្ខាយ រន្ធយុំ[3] ។
ទទាតិ[4] វៃ យថាសទ្ធំ យថាបសាទនំ ជនោ
តត្ថ យោ មង្កុ ភោ ហោតិ បរេសំ បានភោជនេ
ន សោ ទិវា វា រត្តឹ វា សមាធឹ អធិគច្ឆតិ ។
យស្ស ឆេតំ សមុច្ឆិន្នំ មូលឃច្ចំ[5] សមូហតំ
ស វៃ ទិវា វា រត្តឹ វា សមាធឹ អធិគច្ឆតិ ។
នត្ថិ រាគសមោ អគ្គិ នត្ថិ ទោសសមោ គហោ
នត្ថិ មោហសមំ ជាលំ នត្ថិ តណ្ហាសមា នទី ។

---

๑ កត្ថចិ ចោត្តកេ យោ ចាណមតំបាបេតីតិ ទិស្សតិ ។ ๒ តន្តិបិ ជាហោ ។
๓ ម. រុន្ធយុំ ។ ๔ កត្ថចិ ចោត្តកេ ទទន្តីតិ ទិស្សតិ ។ ๕ មូលឃច្ចំន្តិ ជាហោ ។

ធម្មបទគាថា មគ្គវគ្គ ទី ១៨

ជនណា សម្លាប់សត្វផង និយាយពាក្យកុហកផង កាន់យកវត្ថុ
ដែលគេមិនបានឲ្យ ក្នុងលោកផង សេពប្រពន្ធរបស់អ្នកដទៃផង
ជនណា ផឹកទឹកស៊ុរានិងមេរ័យផង ជននោះឯងឈ្មោះថា គាស់
រំលើងឫសគល់របស់ខ្លួន ក្នុងលោកនេះ ដោយពិត ។
ម្នាលបុរសដ៏ចំរើន អ្នកចូរដឹងយ៉ាងនេះថា ជនទាំងឡាយមានធម៌ដ៏
លាមក រមែងមិនជាអ្នកសង្រួមដូច្នេះ លោភៈនឹងសភាពមិនមែនធម៌គឺ
ទោសៈ ចូរកុំបៀតបៀនអ្នក ឲ្យបានសេចក្តីទុក្ខអស់កាលយូរឡើយ ។
ជន រមែងឲ្យតាមសទ្ធា តាមសេចក្តីជ្រះថ្លា បុគ្គលណា ជាអ្នក
អៀនខ្មាសក្នុងទឹកនឹងកោជនរបស់ជនទាំងឡាយដទៃ ជននោះ រមែង
មិនបានសមាធិចិត្ត ក្នុងវេលាថ្ងៃ ឬក្នុងវេលាយប់ឡើយ ។
លុះតែសេចក្តីអៀនខ្មាសនោះ បុគ្គលណា បានផ្តាច់ផ្តិលដកឫសឆ្ងឹង
ឆ្លើងឲ្យមានឫសគល់ដាច់ហើយ បុគ្គលនោះឯង ទើបបានសមាធិចិត្ត
ក្នុងវេលាថ្ងៃ ឬក្នុងវេលាយប់ ។
ភ្លើងស្មើដោយរាគៈ មិនមាន គរចាប់ស្មើដោយទោសៈ មិនមាន
បណ្តាញស្មើដោយមោហៈ មិនមាន ស្ទឹងស្មើដោយតណ្ហា មិនមាន ។

สุตฺตนฺตปิฏเก ขุทฺทกนิกายสฺส ธมฺมปทคาถา

สุขสฺสาวชฺชมญฺเญสํ อตฺตาโน ปน ทุกฺขสํ
ปเรสํ หิ เสา วชฺชานิ ปิปฺุชาติ ยถาภุสํ
อตฺตาโน ปน ฉาเทติ กลิ๋ว กิตวา สเฐา ๆ
ปรวชฺชานุปสฺสิสฺส นิจฺจํ อุชฺฌานสญฺิโน
อาสวา ตสฺส วฑฺฒนฺติ อาก เสา อาสวกฺขยา ๆ
อากาเสว ปทํ นตฺถิ สมโณ นตฺถิ พาหิเร[๑]
ปปญฺจาภิรตา ปชา นิปฺปปญฺา ตถาคตา ๆ
อากาเสว ปทํ นตฺถิ สมโณ นตฺถิ พาหิเร[๒]
สงฺขารา สสฺสตา นตฺถิ นตฺถิ พุทฺธานมิญฺชิตํ ๆ

มลวิคฺโค อฏฺวีสเมา ๆ

๑-๒ ฉ. ม. พาหิเร ๆ

ទោសរបស់ពួកជនដទៃ ឃើញបានដោយងាយ ចំណែកទោសរបស់ខ្លួន ឃើញបានដោយលំបាក ព្រោះថា បុគ្គលនោះ រោយទោសគាំងឆ្ងាយ ចំពោះពួកជនដទៃ ដូចបុគ្គលរោយអង្កាមដូច្នោះ តែថារមែងបិទបាំងទោសរបស់ខ្លួនទុក ដូចព្រានបក្សីបិទបាំងអត្តភាពដោយវត្ថុសម្រាប់បិទបាំង (មានមែកឈើជាដើម) ដូច្នោះ ។

កាលបុគ្គលតយង្គាំមើលទោស របស់បុគ្គលដទៃ ជាប្រក្រតី មានការសំគាល់ហេតុក្នុងការពោលទោស (អ្នកដទៃ) ជានិច្ចជាប្រក្រតី អាសវៈ គាំងឆ្ងាយ របស់បុគ្គលនោះ តែងចំរើន បុគ្គលនោះ ឈ្មោះថា ឋិតនៅឆ្ងាយអំពីធម៌ជាគ្រឿងអស់អាសវៈ ។

ស្នាមដើរ ក្នុងអាកាស មិនមាន សមណៈខាងក្រៅ មិនមាន ពួកសត្វត្រេកអរហើយ ក្នុងធម៌ជាគ្រឿងយឺតយូរ ព្រះតថាគតគាំងឆ្ងាយ មិនមានធម៌ជាគ្រឿងយឺតយូរឡើយ ។

ស្នាមដើរ ក្នុងអាកាស មិនមាន សមណៈខាងក្រៅ មិនមាន សង្ខារគាំងឆ្ងាយជារបស់ទៀង មិនមាន ព្រះពុទ្ធគាំងឆ្ងាយ មិនមានកិលេសជាគ្រឿងញាប់ញ័រទេ ។

ធម្មបទគាថាយ ឯកូនវីសតិមោ ធម្មដ្ឋវគ្គោ

(២៥) ន តេន ហោតិ ធម្មដ្ឋោ យេនត្ថំ សហសា នយេ
យោ ច អត្ថំ អនត្ថញ្ច ឧភោ និច្ឆេយ្យ បណ្ឌិតោ ។
អសាហសេន ធម្មេន សមេន នយតី បរេ
ធម្មស្ស គុត្តោ មេធាវី ធម្មដ្ឋោតិ បវុច្ចតិ ។
ន តេន បណ្ឌិតោ ហោតិ យាវតា ពហុ ភាសតិ
ខេមី អវេរ អភយោ បណ្ឌិតោតិ បវុច្ចតិ ។
ន តាវតា ធម្មធរោ យាវតា ពហុ ភាសតិ
យោ ច អប្បម្បិ សុត្វាន ធម្មំ កាយេន បស្សតិ
ស វេ ធម្មធរោ ហោតិ យោ ធម្មំ នប្បមជ្ជតិ ។

ធម្មបទគាថា ធម្មដ្ឋវគ្គ ទី ១៩

(៦៩) បុគ្គលតាត់សេចក្តីដោយអាក្រក់ ដោយសារហេតុណា ឈ្មោះថាជាអ្នកតាំងនៅក្នុងធម៌ ដោយហេតុនោះ មិនទាន់បានទេ លុះត្រាតែបុគ្គលណា ជាបណ្ឌិតតាត់សេចក្តីទាំងពីរ គឺសេចក្តីពិត និងសេចក្តីមិនពិត ណែនាំដនទាំងឡាយដទៃ ដោយមិនអាក្រក់ ដោយសារធម៌តាមសមគួរ (ដល់ហេតុ) បុគ្គលនោះ ឈ្មោះថាជាអ្នកមានប្រាជ្ញារក្សាធម៌ ទើបហៅថា អ្នកតាំងនៅក្នុងធម៌ ។

បុគ្គលនិយាយច្រើន ដោយហេតុមានប្រមាណប៉ុណ្ណា ឈ្មោះថាជាបណ្ឌិត ដោយហេតុមានប្រមាណប៉ុណ្ណោះ មិនទាន់បានទេ លុះត្រាតែបុគ្គលដែលមានសេចក្តីក្សេម មិនមានពៀរ មិនមានភ័យ ទើបហៅថា បណ្ឌិតបាន ។

បុគ្គលនិយាយច្រើន ដោយហេតុមានប្រមាណប៉ុណ្ណា ឈ្មោះថាជាអ្នកទ្រទ្រង់ធម៌ ដោយហេតុមានប្រមាណប៉ុណ្ណោះ មិនទាន់បានទេ លុះត្រាតែបុគ្គលណា ស្តាប់ពុទ្ធវចនៈ សូម្បីមានប្រមាណតិចហើយឃើញធម៌ដោយនាមកាយគឺចិត្តបាន បុគ្គលនោះទើបឈ្មោះថាជាអ្នកទ្រទ្រង់ធម៌ បុគ្គលណា មិនមើលងាយធម៌ បុគ្គលនោះឯងឈ្មោះថាជាអ្នកទ្រទ្រង់ធម៌ ។

ន តេន ថេរោ ហោតិ យេនស្ស បលិតំ សិរោ
បរិបក្កោ វយោ តស្ស មោឃជិណ្ណោតិ វុច្ចតិ ។
(១)
យម្ហិ សច្চញ្ច ធម្មោ ច អហឹសា សញ្ញមោ ទមោ
ស វេ វន្តមលោ ធីរោ សោ ថេរោតិ បវុច្ចតិ ។

ន ឯកក្ករណមត្តេន វណ្ណទោក្ករតាយ វា
សាធុរូបោ នរោ ហោតិ ឥស្សុកី មច្ឆរី សឋោ ។

យស្ស ចេតំ សមុច្ឆិន្នំ មូលឃច្চំ សមូហតំ
ស វន្តទោសោ មេធាវី សាធុរូបោតិ វុច្ចតិ ។

ន មុណ្ឌកេន សមណោ អព្វតោ អលិកំ ភណំ
ឥច្ឆាលោភសមាបន្នោ សមណោ កិំ ភវិស្សតិ ។

យោ ច សមេតិ បាបានិ អណុំ ថូលានិ សព្វសោ
សមិតត្តា ហិ បាបានំ សមណោតិ បវុច្ចតិ ។

---

១ ម. សំយមោ ។

បុគ្គលមានក្បាលស្កូវហើយ ដោយហេតុណា ឈ្មោះថាជាថេរៈ ដោយ
ហេតុនោះមិនទាន់បានទេ វ័យរបស់បុគ្គលនោះចាស់ជ្រុលហើយ ហៅថា
ចាស់ជាមោឃៈ ។ លុះត្រាតែ សច្ចៈផង ធម៌ផង ការមិនបៀតបៀនផង
ការសង្រួមផង ការទូន្មានខ្លួនផង មានក្នុងបុគ្គលណា បុគ្គលនោះឯងជា
អ្នកមានមន្ទិលខ្ចាត់ចោលហើយ ជាអ្នកមានប្រាជ្ញា ទើបហៅថា ថេរៈ ។
បុគ្គលមានសេចក្តីប្លុសក្បាល មានសេចក្តីកំណាញ់ ជាអ្នកអួតអាង ឈ្មោះ
ថាជាមនុស្សល្អ ដោយហេតុត្រឹមតែធ្វើការនិយាយពាក្យ (ល្អ)
ឬដោយភាពជាអ្នកមានសម្បុរជាទីគាប់ចិត្ត ក៏មិនទាន់បានទេ ។
លុះត្រាតែទោសជាតិ មានឫស្យាជាដើមនេះ បុគ្គលណាបានផ្តាច់ផ្តិល
ដកឡើង ធ្វើឲ្យមានឫសគល់ជាប់ហើយ បុគ្គលនោះជាអ្នកមានទោស
ខ្ចាត់ចោលហើយ ជាអ្នកមានប្រាជ្ញា ទើបហៅថាជាមនុស្សល្អបាន ។
បុគ្គល មិនបានឈ្មោះថាជាសមណៈ ដោយភាពជាអ្នកមានក្បាល
ត្រងោលទេ បុគ្គលអ្នកមិនមានសីលតែនឹងធុតង្គវត្ត ពោលតែពាក្យ
ឡេះឡោះ ប្រកបដោយសេចក្តីប្រាថ្នាទន់ឆ្កៀលៈ ឈ្មោះថាជាសមណៈ
ដូចម្តេចបាន ។ លុះត្រាតែបុគ្គលណា រម្ងាប់បាបទាំងឡាយទាំងតូច
ទាំងធំ ដោយប្រការទាំងពួងបាន ទើបហៅថា សមណៈ ព្រោះបាប
ទាំងឡាយ ដែលបុគ្គលនោះរម្ងាប់បានហើយ ។

ន តេន ភិក្ខុ សោ ហោតិ យោវតា ភិក្ខុតេ បវេ

វិសំ ធម្មំ សមាទាយ ភិក្ខុ ហោតិ ន តាវតា ។

(๑)

យោធ បុញ្ញញ្ច បាបញ្ច ពាហេត្វា ព្រហ្មចរិយវា

សង្ខាយ លោកេ ចរតិ ស វេ ភិក្ខូតិ វុច្ចតិ ។

ន មោនេន មុនិ ហោតិ មូឡ្ហរូបោ អវិទ្ទសុ

យោ ច តុលំវ បគ្គយ្ហ វរមាទាយ បណ្ឌិតោ

(๒)

បាបានិ បរិវជ្ជេតិ ស មុនិ តេន សោ មុនិ

យោ មុនាតិ ឧភោ លោកេ មុនិ តេន បវុច្ចតិ ។

ន តេន អរិយោ ហោតិ យេន បាណានិ ហិំសតិ

អហិំសា សព្វបាណានំ អរិយោតិ បវុច្ចតិ ។

---

๑ ម. វាហិត្វ ព្រហ្មចរិយោ ។ ๒ ឧ. ម. មុនី ។

ធម្មបទគាថា ធម្មដ្ឋវគ្គ ទី ១៩

បុគ្គលណា ដើរស្ងួមដនតាំងឡាយដរៃ ដោយហេតុត្រឹមណា បុគ្គលនោះ មិនបាននឹ្មាះថាជាតក្ខុ ដោយហេតុត្រឹមណោះទេ បុគ្គលសមាទានធម៌ជាពិស ឈ្មោះថាជាតក្ខុ ដោយហេតុត្រឹមតែការដើរស្ងួមប៉ុណ្ណោះ មិនទាន់បានទេ ។ លុះត្រាតែបុគ្គលណា ក្នុងលោកនេះ បន្ទាត់បុណ្យនឹងបាបចេញហើយ ជាអ្នកមានការប្រព្រឹត្តិដ៏ប្រសើរត្រាច់ទៅក្នុងលោកដោយសេចក្តីចេះដឹង បុគ្គលនោះឯង ទើបហៅថាជាតក្ខុ ។ បុគ្គលមានសេចក្តីវង្វេង ជាធម្មតា មិនមានការចេះដឹង មិនបានឈ្មោះថាជាមុនី ដោយភាពជាអ្នកស្ងៀមទេ លុះត្រាតែបុគ្គលណាជាបណ្ឌិតកាន់យកធម៌ដ៏ប្រសើរ រៀរចាកបាបទាំងឡាយ ដូចបុគ្គលកាន់ជញ្ជីងហើយថ្លឹងដូច្នោះ បុគ្គលនោះទើបឈ្មោះថាជាមុនី ដោយភាពជាអ្នកស្ងៀមនោះបាន បុគ្គលណា ដឹងប្រយោជន៍ទាំងពីរ ក្នុងលោក បុគ្គលនោះហៅថា មុនី ដោយហេតុនោះ ។

បុគ្គលបៀតបៀនសត្វទាំងឡាយ ដោយហេតុណា មិនបានឈ្មោះថាជាអរិយៈ ដោយហេតុនោះទេ បុគ្គលដែលតថាគតហៅថា អរិយៈ ព្រោះមិនបៀតបៀនសត្វទាំងពួង ។

ន សរីរម្ហតម្ហេន ពាហុសច្ចេន វា បន
អថ វា សមាធិលាភេន វិវិត្តសយនេន[1] វា
ផុសាមិ នេក្ខម្មសុខំ អបុថុជ្ជនសេវិតំ
ភិក្ខុ វិស្សាសមាបាទិ អប្បត្តោ អាសវក្ខយំ ។

ធម្មដ្ឋវគ្គោ ឯកូនវីសតិមោ ។

ធម្មបទគាថាយ វិសតិមោ មគ្គវគ្គោ

(៧១) មគ្គានដ្ឋង្គិកោ សេដ្ឋោ សច្চានំ ចតុរោ បទា
វិរាគោ សេដ្ឋោ ធម្មានំ ទ្វិបទានញ្ច ចក្ขុមា
ឯសេវ[2] មគ្គោ នត្ថញ្ញោ ទស្សនស្ស វិសុទ្ធិយា ។
ឯតញ្ហិ តុម្ហេ បដិបជ្ជថ មារសេន្ធំ បមោហនំ
ឯវញ្ហិ តុម្ហេ បដិបន្នា ទុក្ខស្សន្តំ ករិស្សថ ។

(៣)
អក្ខាតោ វោ មយា មគ្គោ អញ្ញាយ សល្លសន្ថនំ
តុម្ហេហិ កិរិយំ អាតប្បំ អក្ខាតារោ តថាគតា

---

๑ ម. វិវេកសយនេន ។ ๒ ម. ឯសោ វ ។ ๓ ម. សល្លសន្ថនំ ។
ម. សល្លកន្ថនំ ។

ម្នាលភិក្ខុ បើភិក្ខុមិនទាន់ដល់ នូវការអស់អាសវៈទេ កុំអាលទុកចិត្ត ដោយគុណត្រឹមតែសីលនឹងវត្ត ឬដោយភាពជាអ្នកចេះដឹងច្រើនឡើយ មួយទៀត ដោយការបានសមាធិ ឬដោយការដេកក្នុងទីស្ងាត់ ឬក៏ដោយគុណមានប្រមាណប៉ុណ្ណេះថា អាត្មាអញ ពាល់ត្រូវនេក្ខម្មសុខ ដែលបុថុជ្ជនមិនដែលជួបប្រសព្វ ដូច្នេះឡើយ ។

ចប់ ធម្មដ្ឋវគ្គ ទី ១៩ ។

ធម្មបទគាថា មគ្គវគ្គ ទី ២០

(៣០) ផ្លូវមានអង្គ ៨ ប្រសើរជាងផ្លូវទាំងឡាយ បទ ៤ គឺអរិយសច្ច ប្រសើរជាងសច្ចៈទាំងឡាយ វិរាគធម៌ប្រសើរជាងធម៌ទាំងឡាយ មួយទៀត ព្រះតថាគតមានចក្ខុ ប្រសើរជាងសត្វទ្វេបាទទាំងឡាយ ផ្លូវនេះឯង ប្រព្រឹត្តទៅដើម្បីសេចក្តីបរិសុទ្ធិនៃទស្សនៈ ផ្លូវដទៃមិនមានទេ ។ ព្រោះហេតុនោះ អ្នកទាំងឡាយ ចូរដើរទៅតាមផ្លូវនោះ ផ្លូវនេះជាផ្លូវញុំាងមារឲ្យវង្វេង អ្នកទាំងឡាយដើរទៅតាមផ្លូវនេះហើយ នឹងធ្វើឲ្យផុតទុក្ខបាន ។ ផ្លូវនេះហើយ ដែលតថាគតដឹងច្បាស់ជាផ្លូវកំចាត់បង់នូវសរ ប្រាប់ដល់អ្នកទាំងឡាយ សេចក្តីព្យាយាម ញុំាងគំនិលេសឲ្យក្តៅសព្វ អ្នកទាំងឡាយគប្បីធ្វើ ព្រះតថាគតទាំងឡាយ គ្រាន់តែជាអ្នកប្រាប់

ធម្មបទគាថាយ វីសតិមេ មគ្គវគ្គេ

បដិបន្នោ បមោក្ខន្តិ ឈាយិនោ មារពន្ធនា ។
សព្ពេ សង្ខារ អនិច្ចាតិ យទា បញ្ញាយ បស្សតិ
អថ និព្ពិន្ទតិ[1] ទុក្ខេ ឯស មគ្គោ វិសុទ្ធិយា ។
សព្ពេ សង្ខារ ទុក្ខាតិ យទា បញ្ញាយ បស្សតិ
អថ និព្ពិន្ទតិ ទុក្ខេ ឯស មគ្គោ វិសុទ្ធិយា ។
សព្ពេ ធម្មា អនត្តាតិ យទា បញ្ញាយ បស្សតិ
អថ និព្ពិន្ទតិ ទុក្ខេ ឯស មគ្គោ វិសុទ្ធិយា ។

ឧដ្ឋានកាលម្ហិ អនុដ្ឋហានោ
យុវា ពលី អាលសិយំ ឧបេតោ
សំសន្នសង្កប្បមនោ[2]កុសីតោ
បញ្ញាយ មគ្គំ អលសោ ន វិន្ទតិ ។
ឯចានុក្កំ មនសា សុសំវុតោ
កាយេន ច អកុសលំ ន កយិរ
ឯតេ តយោ កម្មបថេ វិសោធយេ
អារាធយេ មគ្គមិសិប្បវេទិតំ ។

---

๑ ម. និព្ពិន្ទតី ។ ๒ ម. អសម្បន្នសង្កប្បមនោ ។

ធម្មបទគាថា មគ្គវគ្គ ទី ២០

ជនទាំងឡាយមានការពិនិត្យ បើបានដើរទៅហើយ នឹងរួចចាកបំណងរបស់មារបាន ។

ភាលណា បុគ្គលយល់ឃើញដោយប្រាជ្ញាថា សង្ខារទាំងពួងមិនទៀងដូច្នេះ ភាលណោះ រមែងនឿយណាយ ក្នុងសេចក្តីទុក្ខ នេះជាផ្លូវនៃសេចក្តីបរិសុទ្ធិ ។

ភាលណា បុគ្គលយល់ឃើញដោយប្រាជ្ញាថា សង្ខារទាំងពួង នាំមកនូវសេចក្តីទុក្ខដូច្នេះ ភាលណោះ រមែងនឿយណាយ ក្នុងសេចក្តីទុក្ខ នេះជាផ្លូវនៃសេចក្តីបរិសុទ្ធិ ។ ភាលណា បុគ្គលយល់ឃើញដោយប្រាជ្ញាថា សង្ខារទាំងពួង មិនមែនជារបស់ខ្លួនដូច្នេះ ភាលណោះ រមែងនឿយណាយ ក្នុងសេចក្តីទុក្ខ នេះជាផ្លូវនៃសេចក្តីបរិសុទ្ធិ ។ បុគ្គលនៅកំឡោះមានកំឡាំង ទាស់តែប្រកបដោយសេចក្តីខ្ជិលច្រអូសមិនប្រឹងប្រែង ក្នុងភាលដែលគួរប្រឹងប្រែង មានសេចក្តីត្រិះរិះក្នុងចិត្តលិបចុះ ក្នុងអកុសលវិតក្កៈ ជាមនុស្សខ្ជិល បុគ្គលខ្ជិល (នោះ) រមែងមិនបានផ្លូវបញ្ញាឡើយ ។

បុគ្គលគប្បីជាអ្នករក្សាវាចា សង្រួមឲ្យល្អ ដោយចិត្ត ទាំងមិនគប្បីធ្វើអកុសលដោយកាយ បុគ្គលគប្បីដំរះកម្មបថទាំង ៣ នេះ នឹងគប្បីត្រេកអរបំពេញមគ្គ ដែលលោកអ្នកសំដែងរកគុណល្អ សំដែងទុកហើយ ។

សុត្តន្តបិដកេ ខុទ្ទកនិកាយស្ស ធម្មបទគាថា

យោគា វេ ជាយតី ភូរិ[1] អយោគា ភូរិសង្ខយោ
ឯតំ ទ្វេធា បថំ ញត្វា ភវាយ វិភវាយ ច
តថត្តានំ និវេសេយ្យ យថា ភូរិ បវឌ្ឍតិ ។
វនំ ឆិន្ទថ មា រុក្ខំ វនតោ ជាយតី[2]ភយំ
ឆេត្វា វនំ វនថម្ភញ្ច និព្វានា ហោថ ភិក្ខវោ ។
យាវញ្ហិ វនថោ ន ឆិជ្ជតិ
អណុមត្តោបិ នរស្ស នារិសុ
បដិពទ្ធមនោ វ តាវ សោ
វច្ឆោ ខីរបកោវ[3]មាតរិ ។
ឧច្ឆិន្ទ សិនេហមត្តនោ
កុមុទំ សារទិកំវ បាណិនា
សន្តិមគ្គមេវ ព្រូហយ
និព្វានំ សុគតេន ទេសិតំ ។
ឥធ វស្សំ វសិស្សាមិ ឥធ ហេមន្តឥតិ្ថសុ
ឥតិ ពាលោ វិចិន្តេតិ អន្តរាយំ ន ពុជ្ឈតិ ។

---

១ ម. ភូរី ។ ២ ម. ជាយតេ ។ ៣ ម. ខីរបោកោវ ។ ម. ខីរុបកោវ ។

ប្រាជ្ញា រមែងកើតអំពីការប្រកប សេចក្តីវិនាសប្រាជ្ញា រមែងកើតអំពីការមិនប្រកប អ្នកមានប្រាជ្ញា ដឹងការប្រកប នឹងការមិនប្រកប ពាំងពីរនេះថា ជាគន្លងនៃសេចក្តីចំរើននឹងសេចក្តីវិនាសហើយ ប្រាជ្ញាចំរើនឡើងដោយប្រការណា គួរដឹកលះខ្លួនទុក ដោយប្រការនោះ ។

អ្នកពាំងផ្សាយ ចូរកាត់តំលេសដូចជាព្រៃចេញ ចូរកុំកាត់ដើមឈើ(ព្រោះ)ភ័យកើតអំពីតំលេសដូចជាព្រៃ ម្នាលភិក្ខុពាំងផ្សាយ អ្នកពាំងផ្សាយ ចូរកាត់តំលេសដូចជាព្រៃផង តំលេសដូចជាដើមឈើដុះក្នុងព្រៃផង ហើយចូរជាអ្នកកុំមានតំលេស ដូចជាព្រៃឡើយ ព្រោះថាតំលេសដូចដើមឈើដុះក្នុងព្រៃរបស់នរជន សូម្បីមានប្រមាណតិចតំដោយ បើកាត់មិនជាប់ក្នុងពួកនារីដកបណា នរជននោះឯង តែងមានចិត្តជាប់ចំពោះក្នុងពួកនារីដូចកូនគោនៅកំពុងជប់ដោះ ដែលមានចិត្តជាប់នៅនឹងមេ ដរាបនោះ ។

អ្នកចូរដកសេចក្តីស្រឡាញ់របស់ខ្លួនចេញ ដូចបុគ្គលដកផ្កាកុមុទ ដែលកើតក្នុងសរទកាលដោយដៃ អ្នកចូរបណ្តុះនូវផ្លូវសន្តិភាពតែម្យ៉ាង ព្រះនិព្វាន ព្រះសុគតសំដែងទុកហើយ ។

អញនឹងនៅក្នុងទីនេះអស់រដូវសា អញនឹងនៅក្នុងទីនេះក្នុងរដូវហេមន្តរដូវ នឹងគិម្ហរដូវ ជនពាល រមែងគិតខុសដូច្នេះ តែងមិនដឹងឮសេចក្តីអន្តរាយឡើយ ។

តំ បុត្តបសុសម្មត្តំ ព្យាសត្តមនសំ[๑] នរំ
សុត្តំ គាមំ មហោឃោវ មច្ចុ អាទាយ គច្ឆតិ ។
ន សន្ថិ បុត្តា តាណាយ ន បិតា ន បិ ពន្ធវា
អន្តកេនាធិបន្នស្ស នត្ថិ ញាតីសុ តាណតា
ឯតមត្ថវសំ ញត្វា បណ្ឌិតោ សីលសំវុតោ
និព្វានគមនំ មគ្គំ ខិប្បមេវ វិសោធយេ ។

មគ្គវគ្គោ វីសតិមោ ។

ធម្មបទគាថាយ ឯកវីសតិមោ បកិណ្ណកវគ្គោ

[๓๑] មត្តាសុខបរិច្চាគា បស្សេ চេ វិបុលំ សុខំ
চជេ មត្តាសុខំ ធីរោ សម្បស្សំ វិបុលំ សុខំ ។
បរទុក្ខូបធានេន យោ អត្តនោ សុខមិច្ឆតិ
វេរសំសគ្គសំសដ្ឋោ វេរា សោ ន បរិមុច្চតិ ។

---

๑ .ម ព្យាសត្តមានសំ ។

មប្ប៉ុ គឺសេចក្តីស្ងប់ តែងនាំយកនូវជន អ្នកស្រេវឹងជ្រប់ ក្នុងកូនទឹង សត្វចិញ្ចឹម មានចិត្តជាប់ដំពាក់ ក្នុងអារម្មណ៍ផ្សេង។នោះ ដូចជំនន ទឹកធំ នាំយកអ្នកស្រុកតំពុងដេកលក់ ។

កាលបុគ្គល ត្រូវមច្ចុគ្របសង្កត់ហើយ កូនតាំងឡាយ មិនមាន ដើម្បីជាទីពឹង បិតា ក៏មិនមាន តាំងដៅពងស្រ ក៏មិនមាន ដើម្បីជាទីពឹងឡើយ សេចក្តីទីពឹងក្នុងញាតិតាំងឡាយ ក៏មិនមាន បណ្ឌិតដឹងអំណាចប្រយោជន៍នេះហើយ គួរជាអ្នកសង្រួមក្នុងសីល គួរប្រញាប់ប្រញាល់ដម្រះផ្លូវ ជាទីទៅកាន់ព្រះនិព្វានឲ្យបាន ។

ចប់ មគ្គវគ្គ ទី ២០ ។

ធម្មបទគាថា បកិណ្ណកវគ្គ ទី ២១

(៣១) បើយើញសេចក្តីសុខដ៏ធំទូលាយ ព្រោះលះបង់សុខល្មមប្រមាណ អ្នកមានប្រាជ្ញា កាលយើញសុខធំទូលាយ គប្បីលះសុខល្មមប្រមាណចេញ ។

ជនប្រាថ្នាសេចក្តីសុខ ដើម្បីខ្លួន ដោយបង្កឲ្យទុក្ខដល់អ្នកដទៃ ជននោះឈ្មោះថា ប្រឈូកប្រឈល់ហើយ ដោយការជាប់ចំពាក់ គឺពៀរ រមែងមិនរួចចាកពៀរទេ ។

យញ្ញា តាំ តនុមាទ្ធំ អតាំ បន តាយីវតំ(១)

ខុទ្ទលាធំ បមត្តានំ តេសំ វឌ្ឍតិ អាសវា ។

យោសព្វ សុសមារទ្ធា ធិច្ចំ កាយគតា សតិ

អតាំច្ឆន្តេ ន សេវន្តិ តាំច្ឆេ សាតច្ចការិនោ

សតានំ សម្បជានានំ អត្ថំ គច្ឆន្តិ អាសវា ។

មាតរំ បិតរំ ហន្ត្វា រាជានោ ទ្វេ ច ខត្តិយេ

រដ្ឋំ សានុចរំ ហន្ត្វា អនីឃោ យាតិ ព្រាហ្មណោ ។

មាតរំ បិតរំ ហន្ត្វា រាជានោ ទ្វេ ច សោត្ថិយេ

វេយ្យគ្ឃបញ្ចមំ ហន្ត្វា អនីឃោ យាតិ ព្រាហ្មណោ ។

---

១ ម· ការយតិ ។

របស់ណាដែលខ្លួនគួរធ្វើ របស់នោះពួកកិក្ខុណា លះបង់ចោលហើយ តែរបស់ដែលមិនគួរធ្វើ ត្រូវប្រព្រឹត្តរឿយ កាសវៈតាំងឡាយ តែងចំរើនឡើងដល់ពួកកិក្ខុនោះ ជាអ្នកមានសេចក្តីប្រមាទ មានមានះដូចជាដើមបបុសលើកឡើងហើយ ។

លុះតែសតិប្រព្រឹត្តទៅ ក្នុងកាយជានិច្ច ដែលពួកកិក្ខុណាបានប្រារព្ធប្រពៃហើយ កិក្ខុទាំងនោះ រមែងជាអ្នកធ្វើការដែលគួរធ្វើរឿយ ។ មិនធ្វើការដែលមិនគួរធ្វើ កាសវៈតាំងឡាយ របស់ពួកកិក្ខុនោះ ដែលជាអ្នកមានសតិ មានសម្បជញ្ញៈ រមែងដល់នូវការអស់ទៅ ។

បុគ្គលសម្លាប់តណ្ហាដូចមាតាផង សម្លាប់អស្មិមានះដូចបិតាផង សម្លាប់សស្សតទិដ្ឋិនឹងឧច្ឆេទទិដ្ឋិ ដូចស្តេចជាក្សត្រីពីរព្រះអង្គផង សម្លាប់អាយតនៈដូចជាដែន ប្រព្រឹត្តទៅមួយអន្លើ ដោយបុរសអ្នកដើរតាមគឺស្មៀនផង រមែងបានទៅជាទំណាសព្រាហ្មណ៍ ជាអ្នកមិនមានទុក្ខ ។

បុគ្គលសម្លាប់តណ្ហាដូចមាតាផង សម្លាប់អស្មិមានះដូចបិតាផង សម្លាប់សស្សតទិដ្ឋិនឹងឧច្ឆេទទិដ្ឋិ ដូចជាស្តេច ជាព្រាហ្មណ៍តាំងពីរផង សម្លាប់វិចិកិច្ឆា ដូចជាខ្លាធំជាគំរប់ ៥ ផង (ដែលនៅស្ពាត់ផ្លូវ) បានហើយ រមែងបានទៅជាទំណាសព្រាហ្មណ៍ ជាអ្នកមិនមានទុក្ខ ។

ធម្មបទគាថាបាឡី ឯកវីសតិវគ្គោ បឋមំ

សុប្បពុទ្ធំ បពុជ្ឈន្តិ សទា គោតមសាវកា
យេសំ ទិវា ច រត្តោ ច និច្ចំ ពុទ្ធគតា សតិ ។

សុប្បពុទ្ធំ បពុជ្ឈន្តិ សទា គោតមសាវកា
យេសំ ទិវា ច រត្តោ ច និច្ចំ ធម្មគតា សតិ ។

សុប្បពុទ្ធំ បពុជ្ឈន្តិ សទា គោតមសាវកា
យេសំ ទិវា ច រត្តោ ច និច្ចំ សង្ឃគតា សតិ ។

សុប្បពុទ្ធំ បពុជ្ឈន្តិ សទា គោតមសាវកា
យេសំ ទិវា ច រត្តោ ច និច្ចំ កាយគតា សតិ ។

សុប្បពុទ្ធំ បពុជ្ឈន្តិ សទា គោតមសាវកា
យេសំ ទិវា ច រត្តោ ច អហិំសាយ រតោ មនោ ។

សុប្បពុទ្ធំ បពុជ្ឈន្តិ យទា គោតមសាវកា
យេសំ ទិវា ច រត្តោ ច ភាវនាយ រតោ មនោ ។

ធម្មបទគាថា បកិណ្ណកវគ្គ ទី ២១

សតិរបស់ជនពួកណា ដែលឋិតនៅ ក្នុងព្រះពុទ្ធគុណ អស់កាលជានិច្ច ទាំងថ្ងៃទាំងយប់ ជនពួកនោះឈ្មោះថា សាវ័កបស់ព្រះគោតម រមែងភ្ញាក់រឭក ។ ដោយប្រពៃ សូត្រកាល ។

សតិរបស់ជនពួកណា ដែលឋិតនៅ ក្នុងព្រះធម្មគុណ អស់កាលជានិច្ច ទាំងថ្ងៃ ទាំងយប់ ជនពួកនោះឈ្មោះថា សាវ័កបស់ព្រះគោតម រមែងភ្ញាក់រឭក ។ ដោយប្រពៃ សូត្រកាល ។

សតិរបស់ជនពួកណា ដែលឋិតនៅ ក្នុងព្រះសង្ឃគុណ អស់កាលជានិច្ច ទាំងថ្ងៃ ទាំងយប់ ជនពួកនោះ ឈ្មោះថា សាវ័កបស់ព្រះគោតម រមែងភ្ញាក់រឭក ។ ដោយប្រពៃ សូត្រកាល ។

សតិរបស់ជនពួកណា ដែលឋិតនៅក្នុងកាយ អស់កាលជានិច្ច ទាំងថ្ងៃទាំងយប់ ជនពួកនោះ ឈ្មោះថា សាវ័កបស់ព្រះគោតម រមែងភ្ញាក់រឭក ។ ដោយប្រពៃ សូត្រកាល ។

ចិត្តរបស់ជនពួកណា ត្រេកអរហើយ ក្នុងការមិនបៀតបៀនគេ ទាំងថ្ងៃទាំងយប់ ជនពួកនោះ ឈ្មោះថា សាវ័កបស់ព្រះគោតម រមែងភ្ញាក់រឭក ។ ដោយប្រពៃ សូត្រកាល ។

ចិត្តរបស់ជនពួកណា ត្រេកអរហើយ ក្នុងមេត្តាភាវនា ទាំងថ្ងៃទាំងយប់ ជនពួកនោះឈ្មោះថា សាវ័កបស់ព្រះគោតម រមែងភ្ញាក់រឭក ។ ដោយប្រពៃ សូត្រកាល ។

សុត្តន្តបិដកេ ខុទ្ទកនិកាយស្ស ធម្មបទគាថា

ទុប្បព្ពជ្ជំ ទុរភិរមំ ទុរាវាសា ឃរា ទុខា

ទុក្ខោសមានសំវាសោ ទុក្ខានុបតិតទ្ធគូ

តស្មា ន ចទ្ធគូ សិយា ន ច ទុក្ខានុបតិតោ សិយា ។

សទ្ធោ សីលេន សម្បន្នោ យសោភោគសមប្បិតោ

យំ យំ បទេសំ ភជតិ តត្ថ តត្ថេវ បូជិតោ ។

ទូរេ សន្តោ បកាសេន្តិ ហិមវន្តោវ បព្ពតោ

អសន្តេត្ថ ន ទិស្សន្តិ រត្តិំ ខិត្តា យថា សរា ។

ឯកាសនំ ឯកសេយ្យំ ឯកោ ចរមតន្ទិតោ

ឯកោ ទមយមត្តានំ វនន្តេ រមិតោ សិយា ។

បកិណ្ណកវគ្គោ ឯកាទសមោ ។

ការចេញបួសបានដោយក្រ ការត្រេកអរត្រូវបានដោយក្រ ផ្ទះតាំងឡាយ
មានការនៅគ្រប់គ្រងដោយលំបាក ជាការក្រ ការនៅរួមដោយជនស្មើ
គ្នា(១) (ដែលមិនមានសេចក្តីគោតវត្រែង) ជាការក្រ ជនអ្នកដើរផ្លូវធ្ងាយគឺ
វដ្តៈ តែងត្រូវសេចក្តីទុក្ខភ្ជាក់ជាប់តាម ព្រោះហេតុនោះ បុគ្គលមិនគប្បី
ជាអ្នកដើរផ្លូវធ្ងាយផង មិនគប្បីជាអ្នកត្រូវសេចក្តីទុក្ខភ្ជាក់ជាប់តាមផង ។
បុគ្គលអ្នកមានសទ្ធា បរិបូណ៌ដោយសីល ស្កប់ស្កល់ដោយយសនិងភោគសម្បត្តិ គប់តែប្រទេសណា ។ គេតែងបូជា ក្នុងប្រទេសនោះ ។ ។
ពួកសប្បុរស រមែងប្រាកដ ក្នុងទីឆ្ងាយ ដូចភ្នំហិមពាន្តដូច្នោះ ពួក
អសប្បុរស (ទុកជាឋិតនៅ) ក្នុងទីដិត តែរមែងមិនប្រាកដ ដូចព្រួញ
ដែលបុគ្គលបាញ់ ក្នុងវេលាយប់ ។
បុគ្គល គួរគប់រកទីអង្គុយម្នាក់ឯង ទីដេកម្នាក់ឯង ជាអ្នកត្រាច់ទៅម្នាក់
ឯង មិនជាអ្នកខ្ជិលច្រអូស ជាអ្នកម្នាក់ឯងទូន្មានខ្លួន គួរជាអ្នកត្រេកអរ
ក្នុងព្រៃស្ងាត់ ។

ចប់ បកិណ្ណកវគ្គ ទី ២១ ។

---

១ អាថាវ្យូ: ប្រែថា ការនៅរួមដោយជនមិនស្មើគ្នា ព្រោះបទថា ទុក្ខោសមានសំវាសោ អាចកាត់បទជាទុក្ខោ + អសមានសំវាសោ យ៉ាងនេះបាន ។ អដ្ឋកថា ក៏មានពន្យល់ដែរ ចំណែកសេចក្តី បានសេចក្តីល្អទាំង ២ យ៉ាង គឺការមិននៅរួមនឹងមនុស្សស្មើគ្នា ក៏ជាការក្រ នៅរួមនឹងមនុស្សមិនស្មើគ្នា ក៏ជាការក្រ ។

ធម្មបទគាថាយ ទ្វាវីសតិមោ និរយវគ្គោ

(๓๒) អភូតវាទី និរយំ ឧបេតិ

យោ វាបិ(๑) កត្វា ន करोमីតិ(๒) चाह

ឧភោបិ តេ បេច្ច សមា ភវន្តិ

និហីនकम्मा មនុជា បរត្ថ ។

कासावकण्ठा बहवो हि पापा चाभिक्खणं अस्सुतवा

चाचा चापेहि करेहि निरयन्ते दुपपज्जरे ॥

សេយ្យោ អយោគុឡោ ភុត្តោ តត្តោ អគ្គិសិខូបមោ

យញ្ចេ ភុញ្ជេយ្យ ទុស្សីលោ រដ្ឋបិណ្ឌំ អសញ្ញតោ ។

ចត្តារិ ឋានានិ នរោ បមត្តោ

អាបជ្ជតី បរទារូបសេវី

អបុញ្ញលាភំ ន និកាមសេយ្យំ

និន្ទំ តតិយំ និរយំ ចតុត្ថំ ។

---

๑ ម. ចាបិ ។ ๒ ឧ. ម. करोमि ។ करोम चाहन्ति चाहो ។

ធម្មបទគាថា និរយវគ្គ ទី ២២

(៣៦) អ្នកពោលពាក្យមិនពិត ឬបុគ្គលណាធ្វើ (អំពើអាក្រក់) ហើយ និយាយថា អញមិនធ្វើទេ (បុគ្គលនោះ) រមែងទៅកាន់នរក ជនទាំងពីរនាក់ ដែលមានអំពើថោកទាប (ស្មើគ្នា) នោះ លុះលះលោកនេះទៅហើយ រមែងជាអ្នកស្មើគ្នា (ដោយគតិ) ក្នុងលោកខាងមុខទៀត ។

ពួកជនច្រើននាក់ ដែលមានកម្ពត់ក្រចក់ ដោយសំពត់កាសាវៈ តែ (ប្រព្រឹត្ត) ធម៌ដ៏លាមក មិនបានសង្រួម ពួកជនលាមកទាំងនោះ រមែងទៅកើតក្នុងនរក ដោយសារកម្មទាំងឡាយ ដ៏លាមកនោះ ។

បព្វជិតទ្រុស្តសីល សូរបរិភោគដុំដែក ដែលកំពុងក្តៅ មានពណ៌ដូចអណ្តាតភ្លើង ប្រសើរជាង បព្វជិតទ្រុស្តសីល មិនសង្រួម បរិភោគដុំបាយអ្នកដែន នឹងប្រសើរ ដូចម្តេចបាន ។

នរជន អ្នកប្រមាទហើយ សេពប្រពន្ធរបស់បុគ្គលដទៃ រមែងដល់នូវហេតុនៃសេចក្តីទុក្ខ ៤ យ៉ាង គឺ ទី ១ បានរបស់មិនមែនជាបុណ្យ ទី ២ ដេកមិនបានតាមប្រាថ្នា ទី ៣ ការតិះដៀល ទី ៤ ការធ្លាក់នរក ។

อปุญฺญลาภา จ ตโต จ ปาปิกา

ภีตสฺส ภีตาย รโต จ โจตกิตา

ราชา จ ฆณฺฑำ ตรุกำ ปลาตเ

ตสฺมา ฆเร ปรทารำ น เสเว ฯ

กาเสา ยถา ฉฑฺฑหิเตา หาเรยฺยา ทุกฺกฏาตเ

สาปญฺญำ ทุปฺปรามฏฺฐำ นิรยายูปกฑฺฒติ ฯ

ยำ กริตฺวา สิโลกสฺมึ กมฺมำ สงฺกิลิฏฺฐมญฺญา ยำ ปตำ

สงฺกสฺสรำ ปรหฺมจริยำ น ตำ เหาติ มหาผลำ ฯ

กายิเก เจ กายิกเจนำ นปฺปเมยฺยำ ปรกฺกเม

สิถิโล หิ ปริพฺพาโช[1] ภิยฺโย อากิรเต รชำ ฯ

อกตำ ทุกฺกฏำ เสยฺยา ปจฺฉา ตปติ ทุกฺกฏำ

กตญฺจ สุกตำ เสยฺยา ยำ กตฺวา นานุตปฺปติ ฯ

---

๑ ม. ปริพฺพโช ฯ

(ហេតុនៃសេចក្តីទុក្ខ ๔ យ៉ាងផ្សេងទៀត) គឺ ឋានរបស់មិនដាបុណ្យ ๑ មានគតិកាក្រក់ ๑ តម្រេករបស់បុរសអកខ្វាច ដាបួយនឹងស្ត្រីដែលខ្វាចដែរ មានប្រមាណតិច ๑ ព្រះរាជានឹងដាក់កាជ្រាយ៉ាងធ្ងន់ ๑ ព្រោះហេតុនោះ បុរសមិនគួរសេពប្រពន្ធ របស់បុគ្គលដទៃឡើយ ។ សូវភ្លាំង ដែលបុគ្គលគាន់មិនចំណាប់ រមែងលះដែ យ៉ាងណាមិញ តាពជាសមណៈដែលបព្វជិតគាន់មិនស៊ប់សួនហើយ រមែងតាញបព្វជិតនោះទៅនរក យ៉ាងនោះឯង ។

កម្មណាមួយ ដែលដូរថយក្តី រឹតណាមួយដែលសៅហ្មងក្តី ព្រហ្មចរិយៈដែលបុគ្គលរក្សាដោយសេចក្តីរង្កៀសក្តី កម្មទាំង ๓ នោះ ជារបស់មិនមានផលច្រើនឡើយ ។

បើបុគ្គលធ្វើ គប្បីធ្វើកិច្ចនោះឲ្យមែនទែន គប្បីច្រឹងច្រែងធ្វើកិច្ចនោះឲ្យមាំមួន ព្រោះថា សមណធម៌ជាគ្រឿងរវៃចាកកិលេសដូរថយរមែងរោយដូលគឺរាគាទិកិលេសដល់បុគ្គល ដោយក្រៃលែង ។

អំពើអាក្រក់ ដែលបុគ្គលមិនធ្វើ ប្រសើរជាង (ព្រោះថា) អំពើអាក្រក់ រមែងធ្វើឲ្យក្តៅក្រហាយ តទីតាមខាងក្រោយ បុគ្គលធ្វើអំពើណាហើយ រមែងមិនក្តៅក្រហាយក្រោយ អំពើនោះ ជាអំពើល្អ បើបុគ្គលធ្វើហើយ ឈ្មោះថា បុគ្គលប្រសើរ ។

ធម្មបទគាថាយ ទ្វាសែតំមោ ឱរយរត្តោ

ឧតរំ យថា បច្ចន្តំ ទុគ្គំ សន្ធរតាមិវំ
ឯវំ គោបេថ អត្តានំ ខណោ មា វោ ឧបច្ចគា
ខណាតីតា ហិ សោចន្តិ និរយម្ហិ សមប្បិតា ។
អលជ្ជិតាយេ លជ្ជន្តិ លជ្ជិតាយេ ន លជ្ជរេ
មិច្ឆាទិដ្ឋិសមាទានា សត្តា គច្ឆន្តិ ទុគ្គតឹ ។
អកយេ(១)កយទស្សិនោ កយេ ច អកយទស្សិនោ(២)
មិច្ឆាទិដ្ឋិសមាទានា សត្តា គច្ឆន្តិ ទុគ្គតឹ ។
អវជ្ជេ វជ្ជមតិនោ វជ្ជេ ច អវជ្ជទស្សិនោ
មិច្ឆាទិដ្ឋិសមាទានា សត្តា គច្ឆន្តិ ទុគ្គតឹ ។

---

๑ ឧ. ឯតទន្តរេ ចសទ្ទោ អត្ថិ ។ ๒ ម. ចាកយទស្សិនោ ។

ធម្មបទគាថា នវយវគ្គ ទី ២២

នគរនៅតំបន់ផុតដែន ដែលគេគ្រប់គ្រងហើយ តាំងខាងក្នុង តាំងខាងក្រៅយ៉ាងណា អ្នកតាំងខ្លួនយ៉ាងនោះ កុំឲ្យខណៈ(១) កន្លងអ្នកតាំងខ្លួនឯងឡើយ ព្រោះថាជនតាំងខ្លួន ដែលឲ្យខណៈកន្លងហើយ រមែងសោកស្តាយក្នុងនរក ម៉ឺងដងវាស ។

សត្វតាំងខ្លួន ដែលប្រកាន់មិច្ឆាទិដ្ឋិ រមែងខ្វាស ក្នុងហេតុដែលគេមិនត្រូវខ្វាស រមែងមិនខ្វាស ក្នុងហេតុដែលគេត្រូវខ្វាស សត្វតាំងនោះ តែងទៅកាន់ទុគ្គតិ ។

សត្វតាំងខ្លួន ដែលប្រកាន់មិច្ឆាទិដ្ឋិ រមែងយល់ឃើញ ក្នុងហេតុដែលគេមិនត្រូវខ្វាច ថាជាហេតុដែលគេត្រូវខ្វាចផង យល់ឃើញក្នុងហេតុដែលគេត្រូវខ្វាច ថាជាហេតុដែលគេមិនត្រូវខ្វាចផង សត្វតាំងនោះ តែងទៅកាន់ទុគ្គតិ ។

សត្វតាំងខ្លួន ដែលប្រកាន់មិច្ឆាទិដ្ឋិ រមែងយល់ឃើញ ក្នុងហេតុដែលឥតទោស ថាជាហេតុមានទោសផង យល់ឃើញ ក្នុងហេតុដែលមានទោស ថាជាហេតុឥតទោសផង សត្វតាំងនោះតែងទៅកាន់ទុគ្គតិ ។

---

១ ខណៈ-សព្វនេះ ប្រែថា " ពេលល្អ " ចែកចេញជា ៤ យ៉ាងគឺ ពុទ្ធុប្បាទក្ខណៈ ពេលដែលព្រះពុទ្ធបានត្រាស់ ១ មជ្ឈិមប្បទេសេ ឧបត្តិក្ខណៈ ពេលដែលសត្វកើតឡើងក្នុងមជ្ឈិមប្បទេស ១ សម្មាទិដ្ឋិហេ បដិលទ្ធក្ខណៈ ពេលដែលត្រូវបានសម្មាទិដ្ឋិ ១ ឆន្នមាយតនាទំ អវោកិណ្ណក្ខណៈ ពេលដែលមិនវិកលអាយតនៈប្រាំមួយ ១ ។ អដ្ឋកថា ។

วชฺชญฺ วชฺชเตา ญตฺวา อวชฺชญฺ อวชฺชเตา

สมฺมาทิฏฺฐิสมาทานา สตฺตา คจฺฉนฺติ สุคฺคตึ ๗

อิติ ธมฺมปเท คาถาโย เวฬุวคฺโค ทุติโย นิฏฺฐิโต ๗

ธมฺมปทคาถาโย เวฬุวคฺโค นาม ทุติโย

(๓๓) อหมาสนฺนเก วาสฺมิ ชานาเมา ยตฺถ ทาเรา ยตฺตกญ์ จ

อตฺถวิกฺขายิโน ปญฺญา อุสฺสูเลา ยสฺส ทาหุชฺชเตา ๗

ธนญ์ ชยนฺติ สมิตึ ธนญ์ ภชติ ภริยาติ

ธนโต เสฏฺโฐ มนุสฺเสสุ เยา ตตฺถวิกฺขายิโน ตตฺถ ๗

วิมสฺสเตา ธนญ์ อาชานิยา ๗[1] สนฺโต

กิตฺติภา ๗ มหาภาคา อตฺตนฺโต ตเตา วิ ๗

---

๑ ฉ. ปี. ปิ ๗

សត្វទាំងឡាយ ដែលប្រកាន់សម្មាទិដ្ឋិ ដឹងរបស់មានទោស ថាជារបស់មានទោសផង ដឹងរបស់មិនមានទោស ថាជារបស់មិនមានទោសផង សត្វទាំងនោះ តែងទៅកាន់សុគតិ ។

ចប់ ឆវិយវគ្គ ទី ២២ ។

ធម្មបទគាថា នាគវគ្គ ទី ២៣

(៣៣) គថាគតនឹងអត់ទ្រាំពាក្យល្មើស ដូចដំរីកាលអត់ទ្រាំចំពោះព្រួញដែលរបូតចេញអំពីធ្នូ ក្នុងសង្គ្រាមដូច្នោះ ព្រោះថា ជនទ្រុស្តសីលមានច្រើននាក់ ។ ពួកជនតែងនាំវាហនៈ ដែលទូន្មានហើយទៅកាន់ទីប្រជុំ ព្រះរាជាតែងស្តេចឡើងគាន់វាហនៈ ដែលទូន្មានហើយ បណ្តាមនុស្សទាំងឡាយ មនុស្សណា អត់សង្កត់នឹងពាក្យល្មើសបាន មនុស្សនោះជាអ្នកមានខន្តីទូន្មានហើយ ឈ្មោះថា បុគ្គលប្រសើរបំផុត ។ ពួកសេះអស្សតរាជ្ញ សេះអាជានេយ្យក្តី សេះសិន្ធពក្តី ដ៏ក្រុញ្ជរដ៏ប្រសើរក្តី ដែលបុគ្គលប្រឿនប្រដៅបានបទហើយ រាប់ថាជាសត្វប្រសើរ បុគ្គលដែលមានខន្តីទូន្មានបានបទហើយ ប្រសើរជាងសត្វទាំងអស់នោះ ។

ន ហិ ឃនេហិ យោនេហិ កច្ចេយ្យ អកតំ ឯសំ
យថាភូតា[1] សុទន្តេន ទន្តា ទន្តេន តច្ឆតិ ។

ឆនថាលសោ ឆាម កុញ្ជរោ
កជុកប្បកេទនោ ទុន្និវារយោ
ពន្ធោ[2] កពន្ធឃ្យ ន កុញ្ជតិ
សុមរតិ ឆាតវនស្ស កុញ្ជរោ ។
មិទ្ធី យទា ហោតិ មហាឃ្យសោ ច
ឯទ្ធាយិតា សម្ប្យវត្តសាយី
មហាវរាហោវ និវាបបុដ្ឋោ
បុនប្បុនំ គព្ភមុបេតិ មន្ទោ ។
ឥទំ បុរេ ចិត្តមចារិ ចារិកំ
យេនិច្ឆកំ យត្តកាមំ យថាសុខំ
តទជ្ជហំ និគ្គហេស្សាមិ យោនិសោ
ហត្ថិប្បភិន្នំ វិយ អង្កុសគ្គហោ ។

---

๑ យថាភូតាតិបិ ឆាយោ ។ ๒ ម. ពន្ធោ ។

បុគ្គលខ្លួនខ្លួនបានបង់ហើយ ខ្លួនខ្លួនល្អហើយ ឈ្មោះថាខ្លួនហើយ ទើបទៅកាន់ទិសដែលខ្លួនមិនធ្លាប់ទៅគឺព្រះនិព្វានបាន ពុំមែនដូចបុគ្គលទៅកាន់ទិស ដែលខ្លួនមិនធ្លាប់ទៅ ដោយសារយានតាំងខ្លាយនោះឡើយ ។

ដំរីឈ្មោះធនបាល ជាសត្វចុះប្រេង កៀវកៀវ នាយហត្ថាចារ្យឃាត់បានដោយលំបាក បើនាយហត្ថាចារ្យ ចង់ស្លាប់ មិនស៊ីស្មៅទេ ព្រោះរឭកដល់ព្រៃខ្លឹង ដែលដំរីនោះធ្លាប់នៅ ។

កាលណា បុគ្គលអ្នកមានសេចក្តីដោតឆ្ងុយផង អ្នកបរិភោគភោជនមានប្រមាណច្រើនផង អ្នកដេកលក់ផង អ្នកដេកបម្រុងនឿលផង ដូចជ្រូកស្រុក ដែលបុគ្គលចិញ្ចឹម ដោយសូកវគ្គ កាលនោះបុគ្គលនោះ ជាមនុស្សខ្លៅ រមែងចូលទៅកាន់គភ៌រឿយ ។ ។

ក្នុងកាលមុនអំពីកាលនេះ ចិត្តនេះបានត្រាច់ទៅកាន់ចារិក តាមអាការដែលខ្លួនប្រាថ្នា តាមអារម្មណ៍ដែលខ្លួនប្រាថ្នា តាមសេចក្តីសប្បាយក្នុងថ្ងៃនេះ អញនឹងសង្កត់សង្កិនចិត្តនោះ ដោយឧបាយ ដូចហ្នាំដំរីកាន់តង្វេរសង្កត់សង្កិនដំរីចុះប្រេង ដូច្នោះដែរ ។

អប្បមាទរតា ហោថ សចិត្តមនុរក្ខថ

ទុគ្គា ទុទ្ធរថត្តានំ[1] បង្កេ សន្នោវ កុញ្ជរោ ។

សចេ លភេថ និបកំ សហាយំ

សទ្ធិំ ចរំ សាធុវិហារិ ធីរំ

អភិភុយ្យ សព្ពានិ បរិស្សយានិ

ចរេយ្យ តេនត្តមនោ សតីមា ។

នោ চে លភេថ និបកំ សហាយំ

សទ្ធិំ ចរំ សាធុវិហារិ ធីរំ

រាជាវ រដ្ឋំ វិជិតំ បហាយ

ឯកោ চរេ មាតង្គរញ្ញេវ នាគោ ។

ឯកស្ស চរិតំ សេយ្យោ នត្ថិ ពាលេ សហាយតា

ឯកោ চរេ ন চ បាបានি កយិរា

អប្បោស្សុក្កោ មាតង្គរញ្ញេវ នាគោ ។

---

១ ម. ខុទ្ទរតត្តានំ ។

អ្នកចាំធ្លាយ ចូរត្រេកអរ ក្នុងសេចក្តីមិនប្រមាទ ចូរកក្រាចិត្តរបស់ខ្លួន ចូរដើរខ្លួនចេញចាកកត់គឺកិលេស ដែលធ្លុងបានដោយកម្រ ដូចដំរីដែលជាប់នៅក្នុងកក់ ដើរខ្លួនឲ្យរួចបាន ។

បើបុគ្គលបានសំឡាញ់ ដែលមានប្រាជ្ញាជាគ្រឿងរក្សាខ្លួន មានប្រាជ្ញាចងចាំ មានគុណធម៌ជាគ្រឿងនៅញាំងប្រយោជន៍ឲ្យសម្រេច ជាអ្នកត្រាច់ទៅជាមួយ គួរជាអ្នកមានចិត្តត្រេកអរ មានស្មារតី គ្របសង្កត់សេចក្តីអន្តរាយទាំងពួង ហើយត្រាច់ទៅជាមួយនឹងសំឡាញ់នោះឯង ។ បើស្វែងរកមិនបានសំឡាញ់ ដែលមានប្រាជ្ញាជាគ្រឿងរក្សាខ្លួន មានប្រាជ្ញាចងចាំ មានគុណធម៌ជាគ្រឿងញាំងប្រយោជន៍ឲ្យសម្រេច ជាអ្នកត្រាច់ទៅជាមួយទេ គួរត្រាច់ទៅតែឯកឯងវិញ ដូចព្រះរាជាលះបង់រដ្ឋ ដែលទ្រង់ឈ្នះហើយស្តេចទៅតែឯកអង្គ ពុំនោះសោត ដូចដំរីឈ្មោះមាតង្គៈ ដែលលះហ្វូងត្រាច់ទៅតែឯកឯងក្នុងព្រៃ ដូច្នោះដែរ ។

ការត្រាច់ទៅ របស់បុគ្គលឯកឯង ជាគុណជាតប្រសើរផុត (ព្រោះថា) សហាយតាគុណ រមែងមិនមាន ក្នុងដនពាលឡើយ បុគ្គលនោះគប្បីជាអ្នកមិនមានសេចក្តីខ្វល់ខ្វាយ ត្រាច់ទៅតែម្នាក់ឯងឥត មិនគប្បីធ្វើអំពើបាបទាំងឡាយផង ដូចដំរីឈ្មោះមាតង្គៈ ជាសត្វមិនមានសេចក្តីខ្វល់ខ្វាយ លះបង់ហ្វូង ត្រាច់ទៅតែឯកឯងក្នុងព្រៃ ដូច្នោះដែរ ។

អត្តមិ ជាតមិ សុខា សហាយោ
តុដ្ឋី សុខា យោ ឥតរីតរេន
បុញ្ញំ សុខំ ជីវិតសង្ខយម្ហិ
សព្វស្ស ទុក្ខស្ស សុខំ បហានំ ។

សុខា មត្តេយ្យតា[1] លោកេ អថោ បេត្តេយ្យតា សុខា
សុខា សាមញ្ញតា លោកេ អថោ ព្រហ្មញ្ញតា សុខា
សុខំ យាវ ជរា សីលំ សុខា សទ្ធា បតិដ្ឋិតា
សុខោ បញ្ញាបដិលាភោ ផាផានំ អករណំ សុខំ ។

ឆាតវគ្គោ តេវីសតិមោ ។

ធម្មបទគាថាបាឡិ បត្តវិសតិមោ តណ្ហាវគ្គោ

[៣៤] មនុជស្ស បមត្តចារិនោ
តណ្ហា វឌ្ឍតិ មាលុវា វិយ
សោ បលវតី[2] ហុរាហុរំ
ផលមិច្ឆំវ វនស្មឹ[3] វានរោ ។

---

๑ កត្ថចិ ឃោត្តកោ មេត្តេយ្យាតិ ទិស្សតិ ។ ๒ ប្លវតីតិបិ ពាហេ ។ ๓ ខ. វនម្ហិ ។

តាលបើសេចក្តីត្រិះរិះ តើតឡើងហើយ សំឡាញ់តាំងឡាយនាំសេចក្តីសុខមកឲ្យ សេចក្តីត្រេកអរដោយបច្ច័យ តាមមានតាមបាន ជាហេតុនាំសេចក្តីសុខមកឲ្យ បុណ្យនាំសេចក្តីសុខមកឲ្យ ក្នុងតាលទៀបក្សយ ជីវិត តាលរះបង់ទុក្ខតាំងអស់បាន ជាហេតុនាំសេចក្តីសុខមកឲ្យ ។ សេចក្តីប្រតិបត្តិលុកងមាតា នាំសេចក្តីសុខមកឲ្យក្នុងលោក មួយទៀត សេចក្តីប្រតិបត្តិលុកងបិតា នាំសេចក្តីសុខមកឲ្យ សេចក្តីប្រតិបត្តិលុកងសមណៈ នាំសេចក្តីសុខមកឲ្យក្នុងលោក មួយទៀត សេចក្តីប្រតិបត្តិលុកងព្រាហ្មណ៍ នាំសេចក្តីសុខមកឲ្យ សីលនាំសេចក្តីសុខមកឲ្យ ជរាបដល់ចាស់ សទ្ធាដែលបុគ្គលតម្កល់ស៊ប់ហើយ នាំសេចក្តីសុខមកឲ្យ ការបានប្រាជ្ញា នាំសេចក្តីសុខមកឲ្យ ការមិនធ្វើបាបតាំងឡាយ នាំសេចក្តីសុខមកឲ្យ ។

ចប់ នាគវគ្គ ទី ២៣ ។

ធម្មបទគាថា តណ្ហាវគ្គ ទី ២៤

(៣៤) តណ្ហា តែងចំរើនដល់មនុស្សអ្នកមានការប្រព្រឹត្តិ ដោយសេចក្តីប្រមាទជាប្រក្រតី ដូចវល្លិ រួបរឹតដើមឈើហើយ ចំរើនឡើង បុគ្គលនោះ តែងស្ទុះទៅ កាន់កំពតគួបកំពង ដូចស្វា កាលប្រាថ្នាផ្លែឈើលោតទៅក្នុងព្រៃ ដូច្នោះដែរ ។

សុត្តន្តបិដកេ ខុទ្ទកនិកាយស្ស ធម្មបទគាថា

យំ ឯសា សហតី[1]ជម្មី តណ្ហា លោកេ វិសត្តិកា
សោកា តស្ស បវឌ្ឍន្តិ អភិវឌ្ឍំវ[2] វីរណំ ។
យោ វេ[3]តំ សហតី ជម្មិំ តណ្ហំ លោកេ ទុរច្ចយំ[4]
សោកា តម្ហា បបតន្តិ[5] ឧទពិន្ទុវ បោក្ខរា ។
តំ វោ វទាមិ ភទ្ទំ វោ យាវន្តេត្ថ សមាគតា
តណ្ហាយ មូលំ ខណថ ឧសីរត្ថោវ វីរណំ ។
មា វោ នឡំវ សោតោវ មារោ ភញ្ជិ បុនប្បុនំ ។
យថាបិ មូលេ អនុបទ្ទវេ ទឡ្ហេ
ឆិន្នោបិ រុក្ខោ បុនរេវ[6]រូហតិ
ឯវម្បិ តណ្ហានុសយេ អនូហតេ
និព្ពត្តតិ ទុក្ខមិទំ បុនប្បុនំ ។

---

១ សហតេតិបិ ៣ហេ ។ ២ ទ. អភិវំវ ។ ម. អភិវ្ឍ្ឍំវ ។ អភិវ្ឍ្ឍន្តិបិ ៣ហេ។ ៣ ទ. ម. ឯ ។ ៤ ទុរច្ចយន្តិបិ ៣ហេ ។ ៥ បបតន្តិបិ ៣ហេ ។ ៦ បុនទេវតិបិ ៣ហេ ។

តណ្ហាទុះ ជាទោសជាតិដ៏លាមក ផ្សាយទៅក្នុងអារម្មណ៍ផ្សេង ។ ក្នុងលោក គ្រប់សត្វតំបុគ្គលណា សេចក្តីសោកស្តាយ តែងចំរើនឡើង ដល់បុគ្គលនោះ ដូចស្មៅវល្លិ៍ ដែលត្រូវក្តៀងធ្លាក់ប៉ុនដង្រៃ ហើយពន្លក លូតលេចឡើង ដូច្នោះដែរ ។

ចំណែកជនណា គ្រប់សត្វតំតណ្ហាដ៏លាមក ក្នុងលោក ដែលគេឆ្លងបានដោយកម្រនោះ សេចក្តីសោកស្តាយ តែងធ្លាក់ចេញចាកជននោះឯង ដូចដំណក់ទឹកដែលធ្លាក់ប៉ុនចាកស្មឹកឈូក ដូច្នោះដែរ ។

ព្រោះហេតុនោះ បានជាតថាគត ប្រាប់អ្នកទាំងឡាយ អ្នកទាំងឡាយ មានប៉ុន្មានរូប ដែលមកប្រជុំក្នុងទីនេះ សេចក្តីចំរើនចូរមានដល់អ្នកទាំងឡាយទាំងប៉ុណ្ណោះចុះ អ្នកទាំងឡាយ ចូរវៀរលែងឫសតណ្ហាចោលចេញ ដូចបុគ្គលត្រូវការដោយស្មៅកំទ្ង គាស់ស្មៅវល្លិ៍ចោលចេញ ដូច្នោះឯង មារកុំរុករានអ្នកទាំងឡាយរឿយ ។ ដូចខ្សែទឹក តាប់បំបាក់ដើមបបុស ដូច្នោះឡើយ ។

កាលបើឫសឈើ មិនមានសេចក្តីអន្តរាយ នៅមាំមួនទេ ដើមឈើទុកជាកាប់ចោលហើយ ក៏តែងដុះឡើងវិតបាន មានឧបមាដូចម្តេចមិញ កាលបើតណ្ហានុស័យ បុគ្គលកំចាត់មិនទាន់បានហើយ ទុក្ខ (មានជាតិទុក្ខជាដើម) នេះ ក៏តែងកើតរឿយ ។ មានឧបមេយ្យដូច្នោះឯង ។

យស្ស ឆត្តឹសតី សោតា មជាមស្សរោ ភុសោ
មហា[1] វាហេ ទុទ្ទិដ្ឋី សង្គបា ភគធិសុតា ។
សវន្តិ សព្វធី សោតា លតា ឧព្ភិជ្ជ[2] តិដ្ឋតិ
តញ្ច និស្សា លតំ ជាតំ មូលំ[3] បញ្ញាយ ឆិន្ទថ ។

សរីតានិ សិនេហានិ ច
សោមនស្សានិ ភវន្តិ ឆន្ទសោ
តេ សាតសិតា សុខេសិនោ
តេ វេ ជាតិជរូបគា ឧភ ។
តសិណាយ[4] បុរក្ខតា[5] បជា
បរិសប្បន្តិ សសោវ ពាធិតោ
សញ្ញោជនសង្គសត្តា[6]
ទុក្ខមុបេន្តិ បុនប្បុនំ ចិរាយ ។

---

១ ឧ. ភិហា ។ ២ ឧប្បជ្ជាតិបិ ពាហេ ។ ៣ ម. មូលេ ។ ៤ តសិណាយាតិបិ ពាហេ ។ ៥ ម. បុរក្ខិតា ។ បុរក្ខិតាតិបិ ពាហេ ។ ៦ ម. សំយោជនសង្គសត្តា ។

ខ្សែតណ្ហា ៣៦ ជាធម្មជាតិហូរទៅ ក្នុងអារម្មណ៍ ជាទីគាប់ចិត្ត ជាធម្មជាតិក្រៀវក្រា មានដល់បុគ្គលណា តម្រិះពាំនាំឲ្យដ៏ធំ ដែលអាស្រ័យនូវភាគៈ តែងនាំនូវទិដ្ឋិអាក្រក់ របស់បុគ្គលនោះ ។

ខ្សែតណ្ហាពាំនាំឲ្យ តែងហូរទៅ ក្នុងអារម្មណ៍ពាំនាំពួន ដូចជាវល្លិដែលបែកខ្នែងឡើង តាំងនៅដូច្នោះ បើអ្នកពាំនាំឲ្យ ឃើញតណ្ហាដូចជាវល្លិនោះ កើតឡើងហើយ ចូរកាត់ឫសចោលចេញ ដោយកាំចិតគឺបញ្ញា ។

សោមនស្សពាំនាំឲ្យ ដែលផ្សាយទៅហើយផង ដែលប្រព្រឹត្តទៅដោយសេចក្តីស្រឡាញ់ផង រមែងមានដល់សត្វ ពួកសត្វនោះ ជាអ្នកអាស្រ័យនូវសេចក្តីរីឃ អ្នកស្វែងរកសេចក្តីសុខ នូវផលពាំនាំឲ្យនោះឯង តែងឈមទៅរកជាតិនឹងជរា ។

ពួកសត្វដែលតណ្ហា ជាទីញុំាងសត្វឲ្យតក់ស្លុត ក្រុងក្រុកហើយ តែងរន្ធត់ដូចទន្សាយដែលព្រានចាក់បានហើយដូច្នោះ ពួកសត្វ ដែលជាប់ក្នុងសំយោជនៈនឹងសង្គធម៌ (ធម៌ជាគ្រឿងដំពាក់) តែងដល់នូវសេចក្តីទុក្ខរឿយ ។ អស់កាលអង្វែង ។

តសិណាយ បុរក្ខតា បជា
បរិសប្បន្តិ សសោវ ពាធិតោ
តស្មា តសិណំ វិនោទយេ
ភិក្ខុ អាកង្ខី(១) វិរាគមត្តនោ ។
យោ ឥមួនជ្ជោ វនាធិមុត្តោ
វនមុត្តោ វនមេវ ធាវតិ
តំ បុគ្គលមេវ បស្សថ
មុត្តោ ពន្ធនមេវ ធាវតិ ។
ន តំ ទឬ្ហំ ពន្ធនមាហុ ធីរា
យទាយសំ ទារុជំ បព្ពជញ្ច ។
សារត្តរត្តា មណិកុណ្ឌលេសុ
បុត្តេសុ ទារេសុ ច យោ អបេក្ខា
ឯតំ ទឬ្ហំ ពន្ធនមាហុ ធីរា
ឱហារិនំ សិថិលំ ទុប្បមុញ្ចំ
ឯតំបិ ឆេត្វាន បរិព្ពជន្តិ
អនបេក្ខិនោ(២) កាមសុខំ បហាយ ។

---

១ ម. អាកង្ខី ។ ម. អាកង្ខន្តិ ។ ២ ម. ន បេក្ខិនោ ។

ពួកសត្វដែលតណ្ហា ជាទីញុំាងសត្វឲ្យតក់ស្លុត ក្រែងខ្លុកហើយ តែងរន្ធត់ដូចទន្សាយ ដែលនាយព្រាន ចាក់បានហើយដូច្នោះ ព្រោះហេតុនោះ ភិក្ខុកាលប្រាថ្នាធម៌ ជាគ្រឿងប្រាសចាកភាគៈ ដើម្បីខ្លួន គប្បីបន្ទោបង់តណ្ហា ដែលជាគ្រឿងតក់ស្លុត ចោលចេញ ។

បុគ្គលណា មិនមានអាល័យ ក្នុងគិហិភាព ដូចដើមឈើតាំងនៅក្នុងព្រៃ មានចិត្តប្តុះស៊ប់ក្នុងព្រៃគឺគុណធម៌ ជាអ្នកបួសស្រឡះចាកព្រៃគឺតណ្ហា ហើយស្តុះទៅរកព្រៃគឺតណ្ហាវិញ អ្នកចាំងឡាយចូរមើលបុគ្គលនោះឯង បុគ្គលនោះរួចចាកចំណងគឺឃាវ៉ាសហើយ ស្តុះទៅរកចំណងគឺឃាវ៉ាសវិញ ។

ចំណងណា ដែលកើតអំពីដែកក្តី កើតអំពីឈើក្តី កើតអំពីស្មៅយ៉ាបូនក្តី អ្នកប្រាជ្ញមិនហៅចំណងនោះ ថាជាចំណងមាំមួនឡើយ ។

ពួកជនណា ត្រេកអរក្រៃពេក ក្នុងវត្ថុមណី និងកុណ្ឌលចាំងឡាយក្តី សេចក្តីអាឡោះអាល័យកូននឹងប្រពន្ធចាំងឡាយក្តី អ្នកប្រាជ្ញចាំងឡាយ ហៅសេចក្តីត្រេកអរនឹងសេចក្តីអាឡោះអាល័យនោះ ថាជាចំណងមាំមួន ជាចំណងនាំបុះ (ពាក្យសត្វទំលាក់ទៅក្នុងអបាយ) ជាចំណងធូរទេ ប៉ុន្តែសត្វស្រាយបានដោយកម្រ អ្នកប្រាជ្ញចាំងឡាយកាត់ចំណងនោះចេញ ជាអ្នកមិនមានសេចក្តីអាឡោះអាល័យ លះបង់កាម-សុខ ហើយចេញបួស ។

ធម្មបទអដ្ឋកថាយ ចតុវីសតិភេទ ពណ្ណនាពុទ្ធ

យេ ភគវន្តានុបតន្តិ សេភតំ
សយំ កតំ មញ្ញជនោវ ជាលំ
ឯតម្បិ ឆេត្វាន[1] វជន្តិ ធីរា
អនបេក្ខិនោ សព្ពទុក្ខំ បហាយ ។
មុញ្ច បុរេ មុញ្ច បច្ឆតោ
មជ្ឈេ មុញ្ច ភវស្ស បារគូ
សព្ពត្ថ វិមុត្តមានសោ
ន បុន ជាតិជរំ ឧបេហិសិ ។
វិតក្កមថិតស្ស ជន្តុនោ
តិព្ពរាគស្ស សុភានុបស្សិនោ
តិយ្យា តណ្ហា បវឌ្ឍតិ
ឯស ខោ ទឬ្ហំ[2] កុរុតេ ពន្ធនំ ។
វិតក្កូបសមេ ច[3] យោ រតោ
អសុភំ ភាវយតី[4] សទា សតោ
ឯស ខោ វ្យន្តិកាហិតិ
ឯសច្ឆេច្ឆតិ[5] មារពន្ធនំ ។

---

១ ម. ឆេ វិត្វេន ។ ២ ម. ឯស ពាឡ្ហំ ។ ៣ ម. វិ ។ ៤ ម. ភាយេតេ ។ ៥ ម. ឯស ច្ឆេច្ឆតិ ។

ពួកជនណា ត្រេកអរដោយអំណាចពាគៈ ពួកជននោះ តែងធ្លាក់ចុះ
កាន់ខ្សែគណ្ហា ដូចពីរពាងទម្លាក់ខ្លួនចុះកាន់សំណាញ់ ដែលឆ្លៀហើយ
ដោយខ្លួនឯង អ្នកប្រាជ្ញចាំងឆ្លាយ តែងកាត់ខ្សែគណ្ហានោះ ជាអ្នក
មិនមានសេចក្តីអាឡោះអាល័យ លះកុ្ខចាំងពួងចេញទៅ ។

អ្នកចូរដោះ (សេចក្តីអាលយ័) ក្នុងកាលមុនចេញ ចូរដោះ
(សេចក្តីអាលយ័) ក្នុងខាងក្រោយចេញ ចូរដោះ (សេចក្តីអាលយ័)
ក្នុងកាលជាគណ្តាលចេញ (កាលបើឆ្លៀយ៉ាងនេះ) អ្នកនឹងដល់ត្រើយ
នៃភព នឹងមានចិត្តរួចស្រឡះ ចាកសង្ខតធម៌ចាំងពួង មិនត្រូវទៅកាន់
ជាតិនឹងជាតទៀតឡើយ ។

គណ្ហា រមែងចំរើនក្នៃលែង ដល់ជនដែលវិតក្កៈញាំញី មានតម្រេក
ក្តៀវក្តា យល់ឃើញអារម្មណ៍ថាល្អ បុគ្គលនោះឯងឈ្មោះថាធ្វើចំណង
ឲ្យមាំមួន ។ លុះតែបុគ្គលណា ត្រេកអរក្នុងអសុភជ្ឈាន ដែលជាហេតុ
ឲ្យស្ងប់រម្ងាប់នូវវិតក្កៈ មានស្មារតីសព្វកាល តែងចំរើនអសុភជ្ឈាន
បុគ្គលនោះឯង នឹងឆ្លើតណ្ហាឲ្យអស់ទៅបាន បុគ្គលនោះឯង ទើប
ឈ្មោះថា កាត់ចំណងមរបាន ។

និដ្ឋង្គតោ អសន្ថាសី វីតតណ្ហោ អនង្គណោ
អច្ចិង្គិ ភវសល្លានិ អន្តិមោយំ សមុស្សយោ ។
វីតតណ្ហោ អនាទានោ និរុត្តិបទកោវិទោ
អក្ខរានំ សន្និបាតំ ញត្វា បុព្ពាបរានិ ច
សវេ អន្តិមសារីរោ មហាបញ្ញោ មហាបុរិសោតិ វុច្ចតិ ។

សព្ពាភិភូ សព្ពវិទូហមស្មិ
សព្ពេសុ ធម្មេសុ អនូបលិត្តោ
សព្ពញ្ជហោ តណ្ហក្ខយេ វិមុត្តោ
សយំ អភិញ្ញាយ កមុទ្ទិសេយ្យំ ។
សព្ពទានំ ធម្មទានំ ជិនាតិ
សព្ពរសំ ធម្មរសោ ជិនាតិ
សព្ពរតឹ ធម្មរតិ ជិនាតិ
តណ្ហក្ខយោ សព្ពទុក្ខំ ជិនាតិ ។

បុគ្គលណា ដល់សេចក្តីសម្រេចគឺអរហត្ត ជាអ្នកមិនតក់ស្លុត មិនមានតណ្ហា មិនមានតិលេសដូចធូលី បានកាត់កូនសរគឺតិលេស ជាហេតុញ៉ាំងសត្វឲ្យទៅកាន់តពបានហើយ កាយដែលឆ្អឹង ៣០ កំណាត់ផុំគ្នាហើយនេះ របស់បុគ្គលនោះ ឈ្មោះថាតាំងនៅក្នុងទីបំផុត ។

បុគ្គលណា មិនមានតណ្ហា មិនមានសេចក្តីប្រកាន់មាំ ជាអ្នកឈ្លាស ក្នុងនិរុត្តិ (វាចាជាគ្រឿងសំដែងចេញ) នឹងបទដ៏សេស ដឹងច្បាស់ រួរប្រជុំនៃអក្ខរៈតាំងព្យាយផង នូវខាងដើមនឹងខាងចុង នៃអក្ខរៈតាំងព្យាយផង បុគ្គលនោះឯង តថាគតហៅថា អ្នកមានសរីរៈបំតនៅក្នុងទីបំផុត មានបញ្ញាច្រើន ជាមហាបុរស ។

តថាគតជាអ្នកគ្របសង្កត់តេកូមិកធម៌តាំងអស់ ដឹងច្បាស់បតុពមិកធម៌តាំងអស់ មានចិត្តមិនបានជាប់នៅ ក្នុងតេកូមិកធម៌តាំងអស់ លះបង់តេកូមិកធម៌តាំងអស់ មានចិត្តរួចស្រឡះ ព្រោះអស់តណ្ហា បើតថាគតត្រាស់ដឹងធម៌ ដោយខ្លួនឯងហើយ ចាំបាច់យកអ្នកណាជាគ្រូអាចារ្យទៀត ។

ធម្មទានឈ្នះអាមិសទានតាំងពួង ធម្មរសឈ្នះរសតាំងពួង សេចក្តីត្រេកអរក្នុងធម៌ ឈ្នះសេចក្តីត្រេកអរតាំងពួង ការអស់តណ្ហាឈ្នះទុក្ខតាំងពួង ។

ធម្មបទគាថាយ ចតុវីសតិមោ តណ្ហាវគ្គោ

មាទិសំ គោតមា ទុម្មេធំ យោ ច ធម្មវិសារទោ
គោតមស្សាយ ទុម្មេធោ មាទិសំ អព្ភាវ អត្តនំ ។

តិណាទោសានិ ខេត្តានិ រាគទោសា អយំ បជា
តស្មា មា វីតរាគេសុ ទិន្នំ ហោតិ មហប្ផលំ ។

តិណាទោសានិ ខេត្តានិ ទោសទោសា អយំ បជា
តស្មា មា វីតទោសេសុ ទិន្នំ ហោតិ មហប្ផលំ ។

តិណាទោសានិ ខេត្តានិ មោហទោសា អយំ បជា
តស្មា មា វីតមោហេសុ ទិន្នំ ហោតិ មហប្ផលំ ។

តិណាទោសានិ ខេត្តានិ ឥច្ឆាទោសា អយំ បជា
តស្មា មា វីតឥច្ឆេសុ ទិន្នំ ហោតិ មហប្ផលំ ។

តណ្ហាវគ្គោ ចតុវីសតិមោ ។

គោគៈតាំងឡាយ រមែងសម្លាប់បុគ្គលអប្បប្រាជ្ញា ប៉ុន្តែមិនសម្លាប់បុគ្គលអ្នកស្វែងរកត្រើយគឺព្រះនិព្វានទេ ឯបុគ្គលអប្បប្រាជ្ញា រមែងសម្លាប់ខ្លួនឯង ដូចជាសម្លាប់បុគ្គលដទៃ ព្រោះចំណង់ក្នុងគោគៈ ។

ស្រែតាំងឡាយមានស្មៅជាទោស ពួកសត្វលោកនេះមានរាគៈជាទោស ព្រោះហេតុនោះ ទានដែលបុគ្គលឲ្យហើយ ដល់អ្នកមានរាគៈអស់ហើយ រមែងជាទានមានផលច្រើន ។ ស្រែតាំងឡាយមានស្មៅជាទោស ពួកសត្វលោកនេះ មានទោសៈជាទោស ព្រោះហេតុនោះ ទានដែលបុគ្គលឲ្យហើយដល់អ្នកមានទោសៈអស់ហើយ រមែងជាទានមានផលច្រើន ។ ស្រែតាំងឡាយមានស្មៅជាទោស ពួកសត្វលោកនេះ មានមោហៈជាទោស ព្រោះហេតុនោះ ទានដែលបុគ្គលឲ្យហើយ ដល់អ្នកមានមោហៈអស់ហើយ រមែងជាទានមានផលច្រើន ។ ស្រែតាំងឡាយមានស្មៅជាទោស ពួកសត្វលោកនេះ មានសេចក្តីប្រាថ្នាជាទោស ព្រោះហេតុនោះ ទានដែលបុគ្គលឲ្យហើយ ដល់អ្នកមានសេចក្តីប្រាថ្នាអស់ហើយ រមែងជាទានមានផលច្រើន ។

ธมฺมปทคาถาย បញ្ចវีសติโม ភิกฺขุวคฺโค

[๓๗] จกฺขุนา สำวโร สาธุ สาธุ โสเตน สำวโร
ฆาเนน สำวโร สาธุ สาธุ ชิวฺหาย สำวโร
กาเยน สำวโร สาธุ สาธุ วาจาย สำวโร
มนสา สำวโร สาธุ สาธุ สพฺพตฺถ สำวโร
สพฺพตฺถ สำวุโต ภิกฺขุ สพฺพทุกฺขา ปมุจฺจติ ฯ

หตฺถสญฺญโต[๑] ปาทสญฺญโต
วาจาย สญฺญโต[๒] สญฺญตุตฺตโม[๓]
อชฺฌตฺตรโต สมาหิโต
เอโก สนฺตุสิโต ตมาหุ ภิกฺขุ ฯ

โยมุขสญฺญโต ภิกฺขุ มนฺตภาณี อนุทฺธโต
อตฺถํ ธมฺมญฺจ ทีเปติ มธุรํ ตสฺส ภาสิตํ ฯ

ธมฺมาราโม ธมฺมรโต ธมฺมํ อนุวิจินฺตยํ
ธมฺมํ อนุสฺสรํ ภิกฺขุ สทฺธมฺมา น ปริหายติ ฯ

---

๑ ม. หตฺถสญฺญโต ฯ ๒ ม. ปาทสญฺญโต ฯ ๓ ฉ. สญฺญตุตฺตโม ฯ ม. สญฺญตุตฺตมโม ฯ

ធម្មបទគាថា ភិក្ខុវគ្គ ទី ២៥

(៣៥) ការសង្រ្គមភ្នែកប្រពៃ ការសង្រ្គមត្រចៀកប្រពៃ ការសង្រ្គមច្រមុះប្រពៃ ការសង្រ្គមអណ្តាតប្រពៃ ការសង្រ្គមកាយប្រពៃ ការសង្រ្គមវាចាប្រពៃ ការសង្រ្គមចិត្តប្រពៃ ការសង្រ្គមតាំងអស់ប្រពៃ ភិក្ខុសង្រ្គមហើយក្នុងធម្មារម្មណ៍តាំងអស់ តែងរួចស្រឡះចាកទុក្ខតាំងពួងបាន។ ជនណា សង្រ្គមដៃ សង្រ្គមជើង សង្រ្គមវាចា សង្រ្គមអត្តភាព ជាអ្នកត្រេកអរក្នុងការចំរើនកម្មដ្ឋានដែលមានក្នុងខ្លួន ជាអ្នកមានចិត្តតម្កល់មាំ ជាអ្នកនៅឯកឯង តែងមានចិត្តត្រេកអរក្នុងធម៌ បណ្ឌិតតាំងឡាយហៅជននោះថា ភិក្ខុ ។

ភិក្ខុណា សង្រ្គមមាត់ ជាអ្នកពោលដោយបញ្ញា មានចិត្តមិនរាយមាយ សំដែងអត្ថធម៌ធម៌បាន ភាសិតរបស់ភិក្ខុនោះរមែបឈ្មោះថាពីរោះ ។ ភិក្ខុមានធម៌ជាទីត្រេកអរ ត្រេកអរហើយក្នុងធម៌ ពិចារណាធម៌ រមែងធម៌រឿយ ។ រមែងមិនសាបសូន្យចាកព្រះសទ្ធម្មឡើយ ។

សលាភំ នាតិមញ្ញេយ្យ នាញ្ញេសំ បិហយេ ភវេ
អញ្ញេសំ បិហយំ ភិក្ខុ សមាធិំ នាធិគច្ឆតិ ។
អប្បលាភោបិ ចេ ភិក្ខុ សលាភំ នាតិមញ្ញតិ
តំ វេ ទេវា បសំសន្តិ សុទ្ធាជីវមតន្ទិតំ ។
សព្ពសោ នាមរូបស្មិំ យេស្ស នត្ថិ មមាយិតំ
អសតា ច ន សោចតិ ស វេ ភិក្ខូតិ វុច្ចតិ ។
មេត្តាវិហារី យោ ភិក្ខុ បសន្នោ ពុទ្ធសាសនេ
អធិគច្ឆេ បទំ សន្តំ សង្ខារូបសមំ សុខំ ។
សិញ្ច ភិក្ខុ ឥមំ នាវំ សិត្តា តេ លឃុមេស្សតិ
ឆេត្វា រាគញ្ច ទោសញ្ច តតោ និព្ពានមេហិសិ ។
បញ្ច ឆិន្ទេ បញ្ច ជហេ បញ្ច ឧត្តរិ[1] ភាវយេ
បញ្ចសង្គាតិគោ ភិក្ខុ ឱឃតិណ្ណោតិ វុច្ចតិ ។

---

១ ឧ.ម. បញ្ច ចុត្តរិ ។

ធម្មបទគាថា ភិក្ខុវគ្គ ទី ២៥

ភិក្ខុមិនគប្បីមើលងាយលាភរបស់ខ្លួន (ដែលកើតឡើងដោយធម៌) មិនគប្បីប្រព្រឹត្តបង់បានលាភរបស់ភិក្ខុដទៃ បើបង់បានលាភរបស់ភិក្ខុដទៃវមែងមិនបានសមាធិឡើយ ។ បើភិក្ខុសូម្បីមានលាភតិច មិនមើលងាយលាភរបស់ខ្លួន ទៅតានឹងមនុស្សពាល់ឆ្ងាយ តែឆស់រស៊ៅភិក្ខុនោះឯង ដែលជាអ្នកមានព្យាយាមជាគ្រឿងអាស្រ័យរស់នៅ ដោយបរិសុទ្ធិជាអ្នកមិនខ្ជិលច្រអូស ។

បុគ្គលណា មិនមានសេចក្តីប្រកាន់ក្នុងនាមនឹងរូបថាជារបស់អញ ដោយប្រការទាំងពួង មួយទៀត បុគ្គលណា មិនសោកស្តាយ ព្រោះនាមនឹងរូបដែលមិនមាន បុគ្គលនោះឯងតថាគតហៅថា ភិក្ខុ ។

ភិក្ខុណា ទៅដោយអំណាចមេត្តា ជ្រះថ្លាក្នុងព្រះពុទ្ធសាសនា ភិក្ខុនោះវមែងបានបទដ៏ស្ងប់ ជាទីរម្ងាប់នូវសង្ខារ នាំមកនូវសេចក្តីសុខ ។

ម្នាលភិក្ខុ ចូរអ្នកស្តារទូកគឺអត្តភាពនេះ ទូកដែលអ្នកស្តារហើយ នឹងដល់ត្រើយឆាប់ អ្នកកាត់រាគៈនឹងទោសៈបានហើយ អំពីនោះនឹងអាចដល់នូវព្រះនិព្វាន ។

ភិក្ខុកប្បីកាត់ នូវម្ភាគិយសំយោជនៈ ៥ ផង គប្បីលះបង់នូវម្ភាគិយសំយោជនៈ ៥ ផង គប្បីចំរើនឥន្ទ្រិយ ៥ តទៅ ភិក្ខុអ្នកកន្លងនូវតិលេសជាគ្រឿងចំពាក់ ៥ (រាគៈ ទោសៈ មោហៈ មានៈ ទិដ្ឋិ) បានហើយ ទើបតថាគតហៅថា អ្នកឆ្លងវន្តដ៏បាន ។

ឈាយ ភិក្ខុ មា ច បមាទោ

មា តេ កាមគុណោ ភមស្សុ ចិត្តំ

មា លោហគុឡំ តិលី បមត្តោ

មា កន្ទិ ទុក្ខមិទន្តិ ឌយ្ហមានោ[1] ។

ឆន្តំ ឈានំ អបញ្ញស្ស ឆន្តំ បញ្ញា អឈាយិនោ

យម្ហិ ឈានញ្ច បញ្ញា ច ស វេ និព្ពានសន្តិកេ ។

សុញ្ញាគារំ បវិដ្ឋស្ស សន្តចិត្តស្ស ភិក្ខុនោ

អមានុសី រតី ហោតិ សម្មា ធម្មំ វិបស្សតោ ។

យតោ យតោ សម្មសតិ ខន្ធានំ ខយធម្មយំ

លភតិ បីតិបាមោជ្ជំ អមតំ តំ វិជានតំ ។

តត្រាយមាទិ ភវតិ ឥធ បញ្ញស្ស ភិក្ខុនោ

ឥន្ទ្រិយគុត្តិ សន្តុដ្ឋិ ចាតិមោក្ខេ ច សំវរោ

មិត្តេ ភជស្សុ កល្យាណេ សុទ្ធាជីវេ អតន្ទិតេ ។

បដិសន្ថារវុត្តស្ស អាចារកុសលោ សិយា

តតោ ចាមោជ្ជពហុលោ ទុក្ខស្សន្តំ ករិស្សតិ ។

---

១ ឌយ្ហមានោតិបិ ពហូសុ ។

ម្នាលភិក្ខុ ចូរអ្នកពិនិត្យផង ចូរកុំជាអ្នកប្រមាទផង ចិត្តរបស់អ្នក ចូរកុំ
វិលទៅរកតាមគុណខ្សែយ អ្នកចូរកុំប្រមាទ ចំពោះបុព្វជ្ជាលោហៈ កុំឲ្យ
ជាអ្នកកាលភ្លើងឆេះហើយ តន្តុតក់ន្តេញថា នេះទុក្ខ ដូច្នេះខ្សែយ ។
ការពិនិត្យមិនមានដល់បុគ្គលអ្នកមិននមានប្រាជ្ញា ប្រាជ្ញាមិនមានដល់
បុគ្គលអ្នកមិនពិនិត្យ ការពិនិត្យនឹងប្រាជ្ញា មានក្នុងបុគ្គលណា បុគ្គល
នោះឯង ឈ្មោះថា ឋិតនៅក្នុងទីដិតនៃព្រះនិព្វាន ។
សេចក្តីត្រេកអរ ដែលមិនមែនជារបស់មនុស្ស រមែងមានដល់ភិក្ខុអ្នក
ចូលទៅកាន់ផ្ទះស្ងាត់ អ្នកមានចិត្តរម្ងាប់ អ្នកឃើញធម៌ដោយប្រពៃ ។
ភិក្ខុពិចារណាការកើតឡើងនឹងការវិនាសខន្ធទាំងឡាយ ក្នុងកាលណា
ក្នុងកាលនោះ ភិក្ខុនោះរមែងបានបីតិនឹងបាមោជ្ជៈ បីតិនឹងបាមោជ្ជៈ
នោះ ឈ្មោះថា ជាអមតធម៌ របស់បណ្ឌិតអ្នកដឹងធម៌ទាំងឡាយ ។
គុណ៣ប្រការនេះ គឺការរក្សាឥន្ទ្រិយ ១ សេចក្តីសន្តោស ១ ការសង្រួម
ក្នុងបាតិមោក្ខ ១ ជាមាគ៌ដើមនៃព្រះនិព្វាននោះ តែងមានដល់ភិក្ខុអ្នក
មានបញ្ញាក្នុងសាសនានេះ (ម្នាលភិក្ខុ) អ្នកចូរគប់រកកល្យាណមិត្ត
អ្នកមានព្យាយាមជាគ្រឿងរស់ដោយបរិសុទ្ធិ ជាអ្នកមិនខ្ជិលច្រអូស ។
ភិក្ខុគប្បីជាអ្នកប្រព្រឹត្តធ្លើបដិសន្ថារៈ គប្បីជាអ្នកឈ្លាសក្នុងអាចារៈព្រោះ
ហេតុទាំងពីរនោះ អ្នកនឹងមានបាមោជ្ជៈច្រើន នឹងធ្វើទីបំផុតទុក្ខបាន ។

ធម្មបទគាថាយ បញ្ចវីសតិមោ ភិក្ខុវគ្គោ

វិសុទ្ធិកោ វិយ បុណ្ណោ បន្ថរិនិ[1] បមុញ្ចតិ
យំ អតញ្ច នោសញ្ច វិប្បមុញ្ចេ ភិក្ខវោ ។
សន្តកាយោ សន្តវាចោ សន្តមនោ សុសមាហិតោ[2]
វន្តលោកាមិសោ ភិក្ខុ ឧបសន្តោតិ វុច្ចតិ ។
អត្តនោ ចោទយត្តានំ បដិមំសេតមត្តនា[3]
សោ អត្តគុត្តោ សតិមា សុខំ ភិក្ខុ វិហាហិសិ ។
អត្តា ហិ អត្តនោ នាថោ អត្តា ហិ អត្តនោ គតិ
តស្មា សញ្ញមយ អត្តានំ[4] អស្សំ ភទ្រំវ វាណិជោ ។
អោភោសយមយំ ភិក្ខុ បសន្នោ ពុទ្ធសាសនេ
អធិគច្ឆេ បទំ សន្តំ សង្ខារូបសមំ សុខំ ។
យោ ហវេ ទហរោ ភិក្ខុ យុញ្ជតិ ពុទ្ធសាសនេ
សោមំ លោកំ បភាសេតិ អព្ភា មុត្តោវ ចន្ទិមា ។

ភិក្ខុវគ្គោ បញ្ចវីសតិមោ ។

---

๑ ម. មន្ថរិនិ ។ ๒ ម. សមាហិតោ ។ ๓ ឧ. បដិអាសេ អត្តមត្តនា ។ ប. បដិអាសេថ អត្តនា ។ ๔ ឧ. សញ្ញម យត្តានំ ។ ម. សំយមមត្តានំ ។

ធម្មបទគាថា ភិក្ខុវគ្គ ទី ២៥

ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ គប្បីដុំរះកិលេសនឹងទោសៈចេញ ដូចម្ចុះដុំរះផ្តាច់ទំាងឡាយ ដែលស្ងួតហើយ ដូច្នោះ ។

ភិក្ខុអ្នកមានកាយរម្ងាប់ហើយ មានវាចារម្ងាប់ហើយ មានចិត្តរម្ងាប់ហើយ មានចិត្តតម្កល់មាំហើយ មានអាមិសៈក្នុងលោក ខ្ជាក់ចោលហើយ ទើបគថាគតហៅថា អ្នកស្ងប់រម្ងាប់ ។

អ្នកចូរជាសត្វឹនឯងដោយឯងឯង ចូរពិនិត្យឯងដោយឯងឯង ម្នាលភិក្ខុ អ្នកនោះប៉ះមានស្មារតី រក្សាឯងទុកហើយ នឹងនៅជាសុខ ។

មែនពិត ឯងជាទីពឹងរបស់ឯង ឯងឯងជាគតិរបស់ឯង ព្រោះហេតុនោះ អ្នកចូររាំងឯង ដូចពាណិជរាំងសេះដ៏ល្អ ។

ភិក្ខុអ្នកត្រាស់ដោយសេចក្តីត្រេកអរ ជ្រះថ្លាក្នុងព្រះពុទ្ធសាសនា រមែងបានទទួលបទដ៏ស្ងប់ជាទីរម្ងាប់ទទួលសង្ខារ នាំមកនូវសេចក្តីសុខ ។

ភិក្ខុណានៅកម្ចាស់ ប្រឹងប្រែង ក្នុងព្រះពុទ្ធសាសនា ភិក្ខុនោះរមែងញ៉ាំងលោកនេះឲ្យភ្លឺស្វាងហ្មត់ ដូចព្រះចន្ទដែលរះផុតអំពីពពក ។

ចប់ ភិក្ខុវគ្គ ទី ២៥ ។

ធម្មបទគាថាយ ធម្មដ្ឋវគ្គោ ព្រាហ្មណវគ្គោ

(៣៦) ឆិន្ទ សោតំ បរក្កម្ម កាមេ បនុទ[1] ព្រាហ្មណ
សង្ខារានំ ខយំ ញត្វា អកតញ្ញូសិ ព្រាហ្មណ ។
យទា ទ្វយេសុ ធម្មេសុ បារគូ ហោតិ ព្រាហ្មណោ
អថស្ស សព្ពេ សំយោគា អត្ថំ គច្ឆន្តិ ជានតោ ។
យស្ស បារំ អបារំ វា បារាបារំ ន វិជ្ជតិ
វីតទ្ទរំ វិសញ្ញុត្តំ តមហំ ព្រូមិ ព្រាហ្មណំ ។
ឈាយិំ វិរជមាសីនំ កតកិច្ចំ អនាសវំ
ឧត្តមត្ថំ អនុប្បត្តំ តមហំ ព្រូមិ ព្រាហ្មណំ ។

---

១ ឧ.ម. បនុទ ។

ធម្មបទគាថា ព្រាហ្មណវគ្គ ទី ២៦

(៣៦) ម្នាលព្រាហ្មណ៍ អ្នកចូរទំប៊ីធ្លាត់តណ្ហាដូចខ្សែទឹក ចូរបន្ទោបង់តាមចាំងឡាយចេញ ម្នាលព្រាហ្មណ៍ អ្នកស្គាល់ច្បាស់នូវការអស់សង្ខារចាំងឡាយហើយ ឈ្មោះថាជាអ្នកដឹងព្រះនិព្វានដែលបច្ច័យតាក់តែងមិនបាន ។

ការណា ព្រាហ្មណ៍អ្នកដល់ត្រើយ ក្នុងធម៌ពីរប្រការគឺសមថធម៌និងវិបស្សនាធម៌ ក្នុងការណោះ តិលេស គ្រឿងប្រកបសត្វទុកចាំងអស់របស់ព្រាហ្មណ៍ អ្នកដឹងនោះ រមែងដល់នូវការតាំងនៅមិនបាន ។

ត្រើយក្តី ទីមិនមែនត្រើយក្តី ត្រើយនឹងទីមិនមែនត្រើយក្តី មិនមានដល់បុគ្គលណា (សេចក្តីប្រកាន់អាយតនៈមិនមានដល់បុគ្គលណា) តថាគតហៅបុគ្គលនោះ ដែលជាអ្នកមានសេចក្តីក្រវល់ក្រវាយអស់ហើយ ជាអ្នកប្រាសចាកតិលេស ថាជាព្រាហ្មណ៍ ។

តថាគតហៅបុគ្គលអ្នកចំរើនឈាន មានធូលីគឺតាមអស់ហើយ អ្នកអង្គុយនៅឯកឯង អ្នកមានសោឡសកិច្ចធ្វើស្រេចហើយ មិនមានអាសវៈដល់នូវប្រយោជន៍ដ៏ឧត្តមសង្គ្រោះដោយលំដាប់ហើយនោះ ថាជាព្រាហ្មណ៍ ។

ធម្មបទគាថាយ ធម្មសតំមេ ព្រាហ្មណវត្ថុ

និវា តបតំ អានិញ្ជោ វត្តិមាភាតំ ចន្ទិមា
សន្ធន្ធោ ទិត្តិយោ តបតំ ឈាយី តបតំ ព្រាហ្មណោ
អថ សព្វមហោរត្តំ ពុទ្ធោ តបតំ តេជសា ។

ពាហិតបាបោ ហិ[(២)] ព្រាហ្មណោ
សមចរិយោ សមណោតិ វុច្ចតិ
បព្ភាជយមត្តនោ មលំ
តស្មា បព្ភជិតោតិ វុច្ចតិ ។

ន ព្រាហ្មណស្ស បហរេយ្យ នាស្ស មុញ្ចេថ ព្រាហ្មណោ
ធិ[(១)] ព្រាហ្មណស្ស ហន្តារំ តតោ ធិ[(២)] យស្ស មុញ្ចតិ ។

ន ព្រាហ្មណស្សេតទកិញ្ចិ សេយ្យោ
យទា និសេធោ មនសោ បិយេហិ
យតោ យតោ ហិំសមនោ និវត្តតិ
តតោ តតោ សម្មតិមេវ ទុក្ខំ ។

---

๑ ឱ.ម. ធិ ។ ๒ ពុទ្ធឃោ ចាហ ។

ព្រះអាទិត្យរុងរឿង ក្នុងវេលាថ្ងៃ ព្រះចន្ទរុងរឿង ក្នុងវេលាយប់ ក្សត្រ
ទ្រង់ប្រដាប់ពេញយសហើយ រមែងរុងរឿង សមណព្រាហ្មណ៍អ្នកមាន
ឈាន រមែងរុងរឿង ឯព្រះសម្ពុទ្ធ រមែងរុងរឿងដោយតេជះរហូត
ថ្ងៃនឹងយប់ ។

អ្នកដែលមានបាបបន្សាត់ហើយ ឈ្មោះថា ព្រាហ្មណ៍ អ្នកដែលតថាគត
ហៅថាសមណៈ ព្រោះការប្រព្រឹត្តិរម្ងាប់ អ្នកដែលបណ្តេញមន្ទិលនៃ
ខ្លួន ហេតុនោះទើបតថាគតហៅថា បព្វជិត ។

ព្រាហ្មណ៍ មិនគប្បីប្រហារព្រាហ្មណ៍ទេ (ចំណែក)ព្រាហ្មណ៍ (ដែល
ត្រូវគេប្រហារហើយ) មិនគប្បីចងពៀរចំពោះព្រាហ្មណ៍នោះ តថា-
គតតិះដៀលព្រាហ្មណ៍ ដែលប្រហារព្រាហ្មណ៍ ព្រាហ្មណ៍ណា ចង
ពៀរចំពោះព្រាហ្មណ៍នោះ តថាគតតិះដៀលព្រាហ្មណ៍នោះ ក្រៃ-
លែងជាងនោះទៅទៀត ។

ការហាមឃាត់ចិត្ត ចាកអារម្មណ៍ជាទីស្រឡាញ់ របស់ព្រាហ្មណ៍នោះ
មិនមែនប្រសើរបន្តិចបន្តួចទេ ចិត្តដែលគិតបៀតបៀនគេ ឆាកចេញ
ចាកវត្ថុណា ។ សេចក្តីទុក្ខព្រោះវត្ថុនោះ ។ ក៏រម្ងាប់ទៅហ្មង ។

យស្ស កាយេន វាចាយ មនសា នត្ថិ ទុក្កតំ

សំវុតំ តីហិ ឋានេហិ តមហំ ព្រូមិ ព្រាហ្មណំ ។

យម្ហា ធម្មំ វិជានេយ្យ សម្មាសម្ពុទ្ធទេសិតំ

សក្កច្ចំ តំ នមស្សេយ្យ អគ្គិហុត្តំវ ព្រាហ្មណោ ។

ន ជដាហិ ន គោត្តេហិ ន ជច្ចា ហោតិ ព្រាហ្មណោ

យម្ហិ សច្চញ្ច ធម្មោ ច សោសុចី សោ ច ព្រាហ្មណោ ។

កិន្តេ ជដាហិ ទុម្មេធ កិន្តេ អជិនសាដិយា

អព្ភន្តរន្តេ គហនំ ពាហិរំ បរិមជ្ជសិ ។

បំសុកូលធរំ ជន្តុំ កិសន្ធមនិសន្ថតំ

ឯកំ វនស្មឹ ឈាយន្តំ តមហំ ព្រូមិ ព្រាហ្មណំ ។

អំពើអាក្រក់ ដោយទ្វារកាយ ទ្វារវាចា ទ្វារចិត្ត របស់បុគ្គលណា មិនមានទេ តថាគតហៅបុគ្គល ដែលបានសង្រួមដោយឋានតាំងនោះថាជាព្រាហ្មណ៍ ។

បុគ្គលបេះធម៌អាថ៌ ដែលព្រះសម្មាសម្ពុទ្ធ ទ្រង់សំដែងហើយ អំពីសំណាក់ត្រូណា គប្បីនមស្ការត្រូនោះ ដោយគោរព ដូចព្រាហ្មណ៍ដែលគោរពភាវបូជាភ្លើងដូច្នោះដែរ ។

បុគ្គលដែលឈ្មោះថាព្រាហ្មណ៍ ព្រោះផ្ចឹងសក់ ក៏មិនមែន ព្រោះគាត្រ ក៏មិនមែន ព្រោះជាតិ ក៏មិនមែន សច្ចៈផង ធម៌ផង មានក្នុងបុគ្គលណា បុគ្គលនោះឈ្មោះថា អ្នកស្អាតផង បុគ្គលនោះឈ្មោះថា ព្រាហ្មណ៍ផង ។

នែអ្នកអ័ប្យក្រាជ្ញាអើយ អ្នកមានប្រយោជន៍អ្វី ដោយការខ្ចុតផ្ចឹងសក់ អ្នកមានប្រយោជន៍អ្វី ដោយការទ្រទ្រង់សំពត់ស្បែកខ្លា បើសន្ទានខាងក្នុងរបស់អ្នក សឹងសាំញ៉ាំដោយរាគៈកិលេស អ្នកឈ្មោះថាជ្រុះខាត់តែខាងក្រៅទេ ។

តថាគតហៅ បុគ្គលអ្នកទ្រទ្រង់សំពត់បំសុកូល មានតាយស្គម មានខ្លួនរោមដោយសរសៃ ជាបុគ្គលឯកឯង ចំរើនឈានក្នុងព្រៃនោះ ថាជាព្រាហ្មណ៍ ។

ធម្មបទគាថាយ ធម្មីសតំមោ ព្រាហ្មណវត្ថុ

ន ជាមា ព្រាហ្មណា ព្រូមិ យោនិនំ មត្តិសម្ភវំ[๑]

ភោវាទី នាម សោ ហោតិ ស វេ[๒] ហោតិ សកិញ្ចនោ

អកិញ្ចនំ អនាទានំ តមហំ ព្រូមិ ព្រាហ្មណំ ។

សព្វសំយោជនំ ឆេត្វា យោ វេ ន បរិតស្សតិ

សង្គាតិគំ វិសំយុត្តំ តមហំ ព្រូមិ ព្រាហ្មណំ ។

ឆេត្វា នទ្ធិ[๓] វរត្តញ្ច សន្ទានំ[๔] សហនុក្កមំ

ឧក្ខិត្តបលិឃំ[๕] ពុទ្ធំ តមហំ ព្រូមិ ព្រាហ្មណំ ។

អក្កោសំ វធពន្ធញ្ច អទុដ្ឋោ យោ តិតិក្ខតិ

ខន្តីពលំ ពលានីកំ[๖] តមហំ ព្រូមិ ព្រាហ្មណំ ។

---

๑ ម. បេតិសម្ភវំ ។ ๒ ខ. ឈាយេ ។ ๓ ខ. នទ្ធិំ ។ ๔ ម. សន្ទនំ ។
๕ ខ. ឧក្ខិត្តបលិឃំ ។ ๖ ម. ពលសេនកំ ។

តថាគតនឹងហៅអ្នកកើត រំពីកំណើត អ្នកកើតក្នុងផ្ទៃនៃព្រាហ្មណីជាមាតា ថាជាព្រាហ្មណ៍ ក៏ទេ បុគ្គលនោះគ្រាន់តែបាននាមថា តោវាទី (អ្នកពោលថាចំរើន) ព្រោះបុគ្គលនោះឯង ជាអ្នកមានកិលេសគ្រឿងកង្វល់នៅឡើយ តថាគតហៅបុគ្គលអ្នកមិនមានកិលេសគ្រឿងកង្វល់ អ្នកមិនមានសេចក្តីប្រកាន់មាំនោះឯង ថាជាព្រាហ្មណ៍ ។

បុគ្គលណា កាត់ស្បោងជន: ទាំងអស់បាន មិនតក់ស្លុត តថាគតហៅបុគ្គលនោះ ដែលគ្មានកិលេសជាគ្រឿងចំពាក់ អ្នកឆ្លងស្រឡះចាកកិលេស ថាជាព្រាហ្មណ៍ ។

តថាគតហៅបុគ្គលដែលកាត់សេចក្តីក្រោធ ដូចពួរផង កាត់តណ្ហា ដូចខ្សែត្រផង កាត់ទិដ្ឋិ ៦២ ដូចទីត ព្រមទាំងអនុស័យ ដូចអ្នកដើរតាមផង អ្នកមានអវិជ្ជា ដូចសសរខឿនដកចោលហើយ អ្នកត្រាស់ដឹងសច្ចៈ ៤ នោះឯង ថាជាព្រាហ្មណ៍ ។

បុគ្គលណា មិនប្រទូស្ត អត់ស្តីតំពាក្យដៀវផង ការបៀតបៀនដំណើរការចងផងបាន ទើបតថាគតហៅបុគ្គលដែលមានខន្តិជាពល: មានខន្តិជារហ័ពលនោះឯង ថាជាព្រាហ្មណ៍ ។

អក្កោធនំ វតវន្តំ សីលវន្តំ អនុស្សុទំ[1]

ទន្តំ អន្តិមសារីរំ តមហំ ព្រូមិ ព្រាហ្មណំ ។

វារិ បោក្ខរបត្តេវ អារគ្គេរិវ សាសបោ

(២)

យោ ន លិម្បតិ កាមេសុ តមហំ ព្រូមិ ព្រាហ្មណំ ។

យោ ទុក្ខស្ស បជានាតិ ឥធេវ ខយមត្តនោ

បន្នភារំ វិសញ្ញុត្តំ តមហំ ព្រូមិ ព្រាហ្មណំ ។

គម្ភីរបញ្ញំ មេធាវិំ មគ្គាមគ្គស្ស កោវិទំ

ឧត្តមត្ថំ អនុប្បត្តំ តមហំ ព្រូមិ ព្រាហ្មណំ ។

អសំសដ្ឋំ គហដ្ឋេហិ អនាគារេហិ ចូភយំ

អនោកាសារិំ អប្បិច្ឆំ តមហំ ព្រូមិ ព្រាហ្មណំ ។

---

១ ឱ. អនុស្សុតំ ។ ២ ឱ. លិប្បតិ ។

តថាគតហៅបុគ្គល ដែលមិនមានសេចក្តីក្រោធ មានឆុតគ្គវត្ត មាន
ចតុបច្ចវេក្ខិសីល មិនមានតណ្ហាគ្រឿងប៉ោងចិត្ត មានឥន្ទ្រិយទូន្មាន
ហើយ មានសរីរៈជិតនៅ ក្នុងទីបំផុតនោះ ថាជាព្រាហ្មណ៍ ។

បុគ្គលណា មានចិត្តមិនបានជាប់នៅ ក្នុងតាមពាំងឆ្ងាយ ដូចទឹកលើ
ស្លឹកឈូក ឬដូចគ្រាប់ស្ពៃលើចុងដែកស្រួច តថាគតហៅបុគ្គលនោះ
ថាជាព្រាហ្មណ៍ ។

បុគ្គលណា ក្នុងសាសនានេះឯង ដឹងច្បាស់នូវការអស់ទុក្ខរបស់ខ្លួន
តថាគតហៅបុគ្គលនោះ ដែលមានខន្ធភារៈ ដាក់ចុះហើយ ដែលរួច
ស្រឡះចាកកិលេសពាំងឆ្ងាយ ថាជាព្រាហ្មណ៍ ។

តថាគតហៅ បុគ្គលអ្នកមានប្រាជ្ញាជ្រៅ មានប្រាជ្ញាជាគ្រឿងទំលាយ
កិលេស អ្នកឈ្លាស ក្នុងផ្លូវនឹងមិនមែនផ្លូវ បានសម្រេចប្រយោជន៍
ដ៏ខ្ពង់ខ្ពស់នោះ ថាជាព្រាហ្មណ៍ ។

តថាគតហៅ បុគ្គលដែលមិនច្របូកច្របល់ ដោយជនពាំងឆ្ងាយ ពីរពួក គឺ
គ្រហស្ថ ១ បព្វជិត ១ ជាអ្នកគ្រាប់ទៅដោយមិនមានសេចក្តីអាល័យ
មានសេចក្តីប្រាថ្នាតិចនោះ ថាជាព្រាហ្មណ៍ ។

ធម្មបទគាថាយ ធម្មឹសតំមោ ព្រាហ្មណវគ្គោ

ឯជាយ ឧល្លំ ភូនេសុ តនេសេសុ ថាវរេសុ ច
យោ ន មាន្ធិ ន ឃាតេតិ តមហំ ព្រូមិ ព្រាហ្មណំ ។

អវិរុទ្ធំ វិរុទ្ធេសុ អត្តទណ្ឌេសុ ឯឞុតំ
សាធានេសុ អសាធានំ តមហំ ព្រូមិ ព្រាហ្មណំ ។

យស្ស រាគោ ច ទោសោ ច មានោ មក្ខោ ច បាតិតោ
សាសបោរិវ អារគ្គា តមហំ ព្រូមិ ព្រាហ្មណំ ។

អក្កក្កសំ វិញ្ញាបនិំ(๑) គិរំ សច្ចំ ឧទីរយេ
យាយ នាភិសជេ កញ្ចិ តមហំ ព្រូមិ ព្រាហ្មណំ ។

យោធ ទីឃំ វ រស្សំ វ អណុំ ថូលំ សុភាសុភំ
លោកេ អទិន្នំ នាទិយតិ តមហំ ព្រូមិ ព្រាហ្មណំ ។

អាសា យស្ស ន វិជ្ជន្តិ អស្មិំ លោកេ បរម្ហិ ច
និរាសយំ វិសំយុត្តំ តមហំ ព្រូមិ ព្រាហ្មណំ ។

---

๑ ឧ. វិញ្ញាថាណំ ។ ម. វិញ្ញាបនំ ។

បុគ្គលណា ដាក់ចុះនូវអាជ្ញា ក្នុងសត្វទាំងឡាយ ដែលនៅតក់ស្លុតក្តី ដែលមាំមួន គឺមិនមានតក់ស្លុតក្តី មិនបៀតបៀនដោយខ្លួនឯង មិនប្រើគេឲ្យបៀតបៀន តថាគតហៅបុគ្គលនោះ ថាជាព្រាហ្មណ៍ ។

តថាគតហៅបុគ្គលអ្នកដែលមិនខឹង ចំពោះពួកជនដែលខឹងហើយ អ្នកវិលត់ចំពោះពួកជនដែលមានអាជ្ញាក្នុងខ្លួន អ្នកមិនមានសេចក្តីប្រកាន់ចំពោះពួកជនដែលមានសេចក្តីប្រកាន់នោះ ថាជាព្រាហ្មណ៍ ។

កគៈ ទោសៈ មានៈ និងមក្ខៈ ដែលបុគ្គលណា បានដម្រុះចេញហើយ ដូចគ្រាប់ស្ពៃដែលក្រុះបុះ អំពីចុងដែកស្រួច តថាគតហៅបុគ្គលនោះ ថាជាព្រាហ្មណ៍ ។

បុគ្គលណា ពោលពាក្យមិនអាក្រក់ ពាក្យជាហេតុឲ្យដឹងសេចក្តីបាន ជាពាក្យពិត ជាពាក្យដែលមិនធ្វើអ្នកណា ឲ្យទាស់ចិត្ត តថាគតហៅបុគ្គលនោះ ថាជាព្រាហ្មណ៍ ។

បុគ្គលណា មិនគាន់យកនូវរបស់វែងប្លុំ តូចប្លុំ ល្អប្លុំអាក្រក់ ដែលគេមិនបានឲ្យហើយក្នុងលោកនេះ តថាគតហៅបុគ្គលនោះ ថាជាព្រាហ្មណ៍ ។

អ្នកណា មិនមានសេចក្តីប្រាថ្នាក្នុងលោកនេះផង ក្នុងលោកខាងមុខផង តថាគតហៅបុគ្គលនោះ ដែលមិនមានសេចក្តីប្រាថ្នា ដែលផុតស្រឡះចាកកិលេស ថាជាព្រាហ្មណ៍ ។

យស្សាសវេ ន វិជ្ជន្តិ អញ្ញាយ អកថង្កថី

អមតោគធំ អនុប្បត្តំ តមហំ ព្រូមិ ព្រាហ្មណំ ។

យោធ បុញ្ញញ្ច បាបញ្ច ឧភោ សង្គំ ឧបច្ចគា

អសោកំ វិរជំ សុទ្ធំ តមហំ ព្រូមិ ព្រាហ្មណំ ។

ចន្ទំវ វិមលំ សុទ្ធំ វិប្បសន្នមនាវិលំ

នន្ទីភវបរិក្ខីណំ តមហំ ព្រូមិ ព្រាហ្មណំ ។

យោមំ បលិបថំ ទុគ្គំ សំសារំ មោហមច្ចគា

តិណ្ណោ បារគតោ ឈាយី អនេជោ អកថង្កថី

អនុបាទាយ និព្វុតោ តមហំ ព្រូមិ ព្រាហ្មណំ ។

អ្នកណា មិនមានសេចក្តីអាល័យគឺតណ្ហា មិនមានសេចក្តីសង្ស័យក្នុងអ្វីសោះ ព្រោះដឹងច្បាស់ធម៌ តថាគតហៅបុគ្គលនោះ ដែលមានចិត្តចុះស៊ប់តាន់ព្រះនិព្វាន ដែលមានព្រះអរហត្តផលដល់ហើយ ដោយលំដាប់ ថាជាព្រាហ្មណ៍ ។

បុគ្គលណា ក្នុងលោកនេះ លះបង់បុណ្យនឹងបាបទាំង ២ នឹងកិលេសជាគ្រឿងចំពាក់(មានរាគៈជាដើម)ចេញហើយ តថាគតហៅបុគ្គលនោះ ដែលជាអ្នកមិនមានសេចក្តីសោក មានធូលីគឺកិលេសអស់ហើយ ជាអ្នកបរិសុទ្ធ ថាជាព្រាហ្មណ៍ ។

តថាគតហៅបុគ្គល ដែលមិនមានសេចក្តីសៅហ្មង ដូចព្រះចន្ទ្រឆ្ងាយចាកមន្ទិល ជាអ្នកបរិសុទ្ធ មានចិត្តថ្លៃថ្លា មិនតក់ស្លុត អស់សេចក្តីត្រេកអរក្នុងភពហើយនោះ ថាជាព្រាហ្មណ៍ ។

បុគ្គលណា កន្លងផ្លូវងឹតគឺរាគៈ នឹងកត់ដែលគេឆ្លងបានដោយកម្រ គឺកិលេស នឹងសង្សារវដ្ត នឹងមោហៈទាំងនេះបាន ជាអ្នកឆ្លងអន្ទាក់ទាំង ៦ បានដល់ត្រើយគឺព្រះនិព្វាន ជាអ្នកមានឈាន មិនញាប់ញ័រដោយតណ្ហា មិនមានសេចក្តីសង្ស័យ មិនប្រកាន់មាំ ជាអ្នករលត់កិលេសហើយ តថាគតហៅបុគ្គលនោះ ថាជាព្រាហ្មណ៍ ។

ធម្មបទគាថាយ ឆព្វីសតិមោ ព្រាហ្មណវគ្គោ

យោធ តាបេ បហាន្ត្វាន[1] អគារតាយ បព្វជេ
តាយភវបរិក្ខីណំ តមហំ ព្រូមិ ព្រាហ្មណំ ។
យោធ តណ្ហំ បហាន្ត្វាន[1] អគារតាយ បព្វជេ
តាយភវបរិក្ខីណំ តមហំ ព្រូមិ ព្រាហ្មណំ[2] ។
ហិត្វា មានុសកំ យោគំ ទិព្វំ យោគំ ឧបច្ចគា
សព្វយោគវិសំយុត្តំ តមហំ ព្រូមិ ព្រាហ្មណំ ។
ហិត្វា រតិំ អរតិញ្ច សីតិភូតំ និរូបធិំ
សព្វលោកាភិភុំ វីរំ តមហំ ព្រូមិ ព្រាហ្មណំ ។
ចុតិំ យោ វេទិ សត្តានំ ឧបបត្តិញ្ច សព្វសោ
អាសត្តំ សុគតំ ពុទ្ធំ តមហំ ព្រូមិ ព្រាហ្មណំ ។

---

១ ឧ. បហេត្វាន ។ ២ ឥមាទ្វេ គាថា អញ្ញមញ្ញំ សទិសា តាសុ ឯត ជដិលត្តេរ-ត្តេម្ហិ ទេសិតា ឯត បន ជោតិកត្តេរត្តេម្ហិ ។

ធម្មបទគាថា ព្រាហ្មណវគ្គ ទី ២៦

បុគ្គលណា ក្នុងលោកនេះ បានលះបង់តាមចាំងឡាយ ជាអ្នកមិនមានផ្ទះ គេចចេញចាកកាមបាន តថាគតហៅបុគ្គលនោះ ដែលអស់តាមកតហើយ ថាជាព្រាហ្មណ៍ ។

បុគ្គលណា ក្នុងលោកនេះ បានលះបង់តណ្ហាហើយ ជាអ្នកមិនមានផ្ទះ គេចចេញចាកតណ្ហាបាន តថាគតហៅបុគ្គល ដែលអស់តណ្ហានឹងកតហើយនោះ ថាជាព្រាហ្មណ៍ ។

បុគ្គលណា លះគំលេសជាគ្រឿងប្រកប ដែលជារបស់មនុស្ស កន្ទងគំលេសជាគ្រឿងប្រកប ដែលជារបស់ទិព្វបានហើយ តថាគតហៅបុគ្គល ដែលផុតស្រឡះ ចាកគំលេសជាគ្រឿងប្រកបទាំងពួងនោះ ថាជាព្រាហ្មណ៍ ។

តថាគតហៅបុគ្គល ដែលលះបង់សេចក្តីត្រេកអរ ក្នុងកាមគុណនឹងមិនត្រេកអរក្នុងកិរិយានៅក្នុងព្រៃ ជាអ្នកមានចិត្តត្រជាក់មិនមានឧបក្កិលេសគ្របសង្កត់លោកទាំងពួង មានសេចក្តីព្យាយាមនោះ ថាជាព្រាហ្មណ៍ ។

បុគ្គលណា ដឹងច្បាស់ចុតិនឹងឧបដិសន្ធិរបស់ពួកសត្វ ដោយអាការទាំងពួងបាន តថាគតហៅបុគ្គលដែលជាអ្នកមិនជាប់នៅក្នុងកាម អ្នកមានដំណើរល្អ ដោយសេចក្តីប្រតិបត្តិ អ្នកត្រាស់ដឹងទូវសច្ចៈ ៤ នោះ ថាជាព្រាហ្មណ៍ ។

យស្ស្ត កាយេ ន ជានន្តិ ទេវា គន្ធព្ពមានុសា

ខីណាសវំ អរហន្តំ តមហំ ព្រូមិ ព្រាហ្មណំ ។

យស្ស្ត បុរេ ច បច្ឆា ច មជ្ឈេ ច នត្ថិ កិញ្ចនំ

អកិញ្ចនំ អនាទានំ តមហំ ព្រូមិ ព្រាហ្មណំ ។

ឧសភំ បវរំ វីរំ មហេសិំ វិជិតាវិនំ

អនេជំ ន្ហាតកំ[1] ពុទ្ធំ តមហំ ព្រូមិ ព្រាហ្មណំ ។

បុព្វេនិវាសំ យោ វេទិ[2] សគ្គាបាយញ្ច បស្សតិ

អថោ ជាតិក្ខយំ បត្តោ អភិញ្ញា វោសិតោ មុនិ

សព្ពវោសិតវោសានំ តមហំ ព្រូមិ ព្រាហ្មណំ ។

ព្រាហ្មណវគ្គោ ឆព្ពីសតិមោ ។

---

๑ ខ. ន្ហាតកោ ។ ๒ ខ. វេទី ។

ខេរតា គន្ថ ន ធ្ម្ម ន ទ្ម្ម ន ទ្ម្ម ន ទ

ធម្មបទគាថាយ ទុតិយំ

(១)

[៣៧] យមកំ អប្បមាទំ បុប្ផំ ពាលេន បណ្ឌិតំ
អវហន្តំ សមាសេវេន ចាបំ ឆណ្ហេន តេ ឧភ ។
ជរា អត្តា ច លោកោ ច ពុទ្ធិ សុខំ បិយេន ច
កោធំ មលញ្ច[2] ឆឌ្ឌេដ្ឋំ មក្ខញ្ច បជហេ វិសតិ ។
បកិណ្ណ[3] និរយំ ចាគា តណ្ហំ អក្ខេ ច ព្រហ្មណោ
ឯតេ ឆឌ្ឌេសតី វក្តា នេសំ តាធិច្ចពន្ធនា ។
យមកេ វិសតី តាថ អប្បមាទម្ហិ ទ្វាទស
ឯកាទសា ចិត្តវគ្គេ បុប្ផវគ្គម្ហិ សោឡស
ពាលេ សត្តរសា តាថ បណ្ឌិតម្ហិ ចតុទ្ទស
អរហន្តេ ឆសា តាថ សមាសេ្ស ទោឡ្ហិ សោឡស
តេរសា ចាបវគ្គម្ហិ ឆណ្ហម្ហិ ឧភ សត្ត ច
ឯកាទសា ជរាវគ្គេ អត្តវគ្គម្ហិ ទ្វាទស
ទ្វាទសា លោកវគ្គម្ហិ ពុទ្ធិវគ្គម្ហិ សោឡស
សុខេ ច បិយវគ្គេ ច តាថាយោ ទោឡ្ហិ ទ្វាទស
បុឌ្ឍសា កោធវគ្គម្ហិ បជវគ្គេ វិសតិ
សត្តរសា ច ឆឌ្ឌេដ្ឋេ មក្ខវគ្គម្ហិ សោឡស

---

១ ម. អប្បមាទំ ។ ២ ម. មលញ្ច ។ ៣ បកិណ្ណកំ ។

